01385907

E1/484.1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលពីរ
# សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦**

**ម៉ោង ០៩:០៥នាទី**

**សវនាការលើកទី៤៦៥**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 02-Feb-2017, 08:00
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

កញ្ញា អេវេលីន ខាំផូស សង់ចេស
*(Ms. Evelyn CAMPOS SANCHEZ)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី
*(Mr. Joseph Andrew BOYLE)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វិចទ័រ កូប៉េ*(Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍ *(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

លោកស្រី ស្វ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| កញ្ញា សុង ឆវ័ន្ត | ខ្មែរ |
| លោក ចូសេហ្វ អេនឌ្រូ បិយលី | អង់គ្លេស |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោក វិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោក ជាល ជឿន (2-TCW-960) | ខ្មែរ |
| សាក្សី 2-TCW-1037 | ខ្មែរ |

# ខ្លឹមសារ

**ការសួរសំណួរទៅសាក្សី ÷ លោក ជាល ជឿន** (2-TCW-960)

សួរដោយលោក នីកូឡាស គូមជែន ផ្ដើមពី.............................. ទំព័រ ៣

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី.............................. ទំព័រ ២៤

**ការសួរសំណួរទៅសាក្សី÷** 2-TCW-1037

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី .............................. ទំព័រ ៤២

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្ដើមពី.............................. ទំព័រ ៤៤

សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី ផ្ដើមពី.............................. ទំព័រ ៧៩

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៥:៤៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ជាល ជឿន បញ្ចប់ ហើយនិងផ្តើមស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1037។

ក្រឡាបញ្ជីសវនាការ លោកស្រី សែ កុលវុឌ្ឍី ឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន អវត្តមានភាគី និង បុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។

ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ ហើយសាក្សីដែលនឹងត្រូវមកផ្តល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ គឺលោក ជាល ជឿន។ លោក និងមេធាវីប្រឹក្សាមានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការ។ ហើយសាក្សីបន្ទាប់ដែលត្រូវមកផ្តល់សក្ខីកម្មមានរហស្សនាម 2-TCW-1037។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និង លោក ខៀវ សំផន ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីណាមួយដែលត្រូវទទួលស្គាល់នៅក្នុងរឿងក្តីនេះទេ។ សាក្សីនឹងធ្វើសម្បថនៅចំពោះមុខលោកតាដំបងដែកនាពេលព្រឹកនេះ។ ហើយសាក្សីមានមេធាវីប្រឹក្សា គឺលោកមេធាវី មឿន សុវណ្ណ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គ

ជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្ចង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦។ មេធាវីការពារក្តីរបស់ខ្ញុំ បានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិមិនអាចបកស្រាយថា ជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងកាត់សេចក្តីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះ គ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាលថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈស្ពឹកផ្នែកខាងស្តាំនៃរាងកាយ ឈឺចង្កេះខ្លាំង អង្គុយយូរមិនបាន និងបានផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតនៅក្រោមសាលសវនាការនេះ។

[០៩:០៨:៥០]

ផ្អែកលើមូលដ្ឋាននេះ និងយោងលើបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍រយៈពេលសវនាការពេញមួយថ្ងៃនេះ។ ហើយបង្គាប់ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍អាចចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

ហើយមុននឹងផ្តល់វេទិកាទៅភាគីក្នុងការសួរដេញដោលសាក្សីរូបនេះ អង្គជំនុំជម្រះសូមបញ្ជាក់រំឭកភាគីឡើងវិញ បញ្ហាទី១ នៅពេលដែលមានការជជែកតវ៉ាគ្នារវាងភាគី គឺសូម ឬក៏ជាមួយនឹងចៅក្រមនៃអង្គជំនុំជម្រះ សូមលៃពេលវេលាសមស្រប ដើម្បីទុកលទ្ធភាពឲ្យអ្នកបកប្រែ បកប្រែភាសាបានល្អ ហើយសូមឲ្យនិយាយដោយយឺតៗបានហើយ។

បញ្ហាទី២ ពាក់ព័ន្ធនឹងបញ្ហាឯកសារ E319/52.3.3 និង E319/58.2.4 ដែលជាកំណត់ហេតុ

ស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1066 ដែលបានយកឯកសារនេះ ពីសំណុំរឿង ០០៤នោះ គឺសូមភាគី បើសិនជាករណីចាំបាច់ក្នុងការប្រើប្រាស់ឯកសារទាំងពីរនេះជាមូលដ្ឋានក្នុងការតាំងសំណួរដេញដោលចំពោះសាក្សី សូមប្រើតែរហស្សនាមបានហើយ គឺសាក្សីដែលមានរហស្សនាម 2-TCW-1066។

ហើយដោយសារចៅក្រមអង្គជំនុំជម្រះបានសួរដេញដោលសាក្សីរូបនេះច្រើនហើយ ដូច្នេះជាបន្តទៅនេះ អង្គជំនុំជម្រះផ្តល់វេទិកាទៅភាគីដែលពាក់ព័ន្ធនេះ គឺខាងសហព្រះរាជអាជ្ញា រួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មួយវគ្គនៃថ្ងៃសវនាការ ហើយភាគីការពារក្តីដូចគ្នា។ ហើយដំបូងនេះ ផ្តល់វេទិកាទៅសហព្រះរាជអាជ្ញាដើម្បីតាំងសំណួរដេញដោលចំពោះសាក្សី។

សូមអញ្ជើញ!

[០៩:១១:០៨]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណ។ ដើម្បីបញ្ជាក់ឲ្យបានច្បាស់ លោកប្រធាន បាននិយាយថា យើងមានពេលតែមួយពេលទេ សម្រាប់ខាងយើង។ បាទ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ជម្រាបសួរលោកសាក្សី ខ្ញុំមានបញ្ហាមួយចំនួន ដើម្បីឲ្យលោកបញ្ជាក់បន្ថែមទៅលើអ្វីដែលលោកបានប្រាប់កាលពីសប្តាហ៍មុន។ ខ្ញុំសូមអរគុណដែលលោកបានបញ្ជាក់ឲ្យបានច្បាស់ ហើយលោកបានប្រាប់តែអ្វីដែលលោកបានដឹង ហើយខ្ញុំចង់ឲ្យលោកបន្តអនុវត្តបែបនេះតទៅទៀត។ លោកបានប្រាប់ថា លោកធ្លាប់ជាព្រះសង្ឃ។ តើលោកអាចប្រាប់បានទេ ថាតើលោកចូលបួសជាព្រះសង្ឃនៅពេលណា?

**លោក ជាល ជឿន៖**

**ឆ៖** បាទ ខ្ញុំបួសនៅឆ្នាំ៧០។

**ស៖** មុនពេលលោកចូលបួសហ្នឹង តើលោកមានបានសិក្សានៅក្នុងវត្តទេ?

**ឆ៖** ខ្ញុំរៀននៅក្នុងវត្ត។ ដល់ពេលឆ្នាំ៧០ហ្នឹង កើតសង្គ្រាមហ្នឹង ខ្ញុំក៏បួសនៅក្នុងវត្តដែលខ្ញុំនៅរៀនហ្នឹងទៅ។

**ស៖** តើលោកសិក្សា ឬក៏លោករៀនបានប៉ុន្មានឆ្នាំដែរ មុនពេលដែលលោកចូលបួស?

**ឆ៖** ខ្ញុំរៀនបានបីឆ្នាំ។

**ស៖** តើលោកនៅជាពុទ្ធសាសនិកឬ រហូតមកដល់ពេលនេះ?

**ឆ៖** ខ្ញុំអត់យល់ មិនដឹងពុទ្ធសាសនិកហ្នឹងម៉េច។

**ប្រធានអង្គជំនុំ៖**

លោកនៅតែកាន់ព្រះពុទ្ធសាសនាដដែល ឬក៏យ៉ាងម៉េច រហូតដល់ពេលនេះ?

**លោក ជាល ជឿន៖**

បាទ ខ្ញុំនៅកាន់ពុទ្ធសាសនាដដែល។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមអរគុណលោកសាក្សី។ តើលោកអាចពន្យល់បានទេថា មានមូលហេតុអ្វី ទើបលោកសឹក លែងបួសជាព្រះសង្ឃ?

[០៩:១៣:៣៣]

**លោក ជាល ជឿន៖**

**ឆ៖** បាទ ពេលខ្ញុំសឹក ដែលខ្ញុំលែងបួសហ្នឹង កាលពីឆ្នាំ៧៥ហ្នឹង ដែលសន្តិភាពភ្លាមហ្នឹង ក្រសួងធម្មការគេទៅប្រជុំលោកតាមវត្តឲ្យលោកធ្វើស្រែ និងដាំកប្បាស ត្បាញចីពរ ឧបត្ថម្ភខ្លួនឯង និងធ្វើស្រែឧបត្ថម្ភខ្លួនឯង គឺអត់មានអ្នកណាគេឧបត្ថម្ភទេ។ ដល់អ៊ីចឹង ខ្ញុំបួសអត់កើត ខ្ញុំសឹកទៅ។

**ស៖** នៅពេលដែលលោកក្រសួងសាសនាហ្នឹង ថាតើលោកនិយាយអំពីក្រសួងរបស់រដ្ឋាភិបាល ឬមួយក៏យ៉ាងម៉េចដែរ?

**ឆ៖** អត់ ក្រសួងធម្មការហ្នឹង គឺក្រសួងធម្មការខាងខ្មែរក្រហម។

**ស៖** ដូច្នេះ ចាប់ពីឆ្នាំ៧០ ដល់ពេលចប់សង្គ្រាម គឺឆ្នាំ៧៥ហ្នឹង តើលោកនៅទីណាដែរ?

[០៩:១៤:៥២]

**ឆ៖** ពីឆ្នាំ៧០ ដល់ឆ្នាំ៧៥ ខ្ញុំ អង្កាល់ពីខ្ញុំបួសហ្នឹង ខ្ញុំបួសនៅវត្តបឹងខ្នារ។ ដល់ឆ្នាំ១៩៧២ហ្នឹង គេជម្លៀសម្ដាយខ្ញុំ ខ្មែរក្រហមគេជម្លៀសទៅនៅព្រៃពីឆ្នាំ៧២។ ដល់ខ្ញុំនឹកម្ដាយខ្ញុំ ខ្ញុំតាមទៅរក ទៅជួបក្រសួងធម្មការគេ ក៏គេអត់ឲ្យខ្ញុំវិលត្រឡប់មកវិញ គេយកខ្ញុំទៅដាក់នៅវត្តព្រៃកន្ទួត។ ពេលនោះ ខ្ញុំអត់បានជួបម្ដាយខ្ញុំទេ គេយកទៅដាក់នៅវត្តព្រៃកន្ទួតហ្នឹង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** អ៊ីចឹងខ្ញុំយល់អ៊ីចេះ ខ្ញុំយល់<ពីចម្លើយរបស់លោក គឺថានៅក្នុង>ឆ្នាំ៧២ហ្នឹង លោកបានទៅរកម្ដាយ <ហើយ>ក្រសួងធម្មការរបស់ខ្មែរក្រហម បានបញ្ឈប់ បានឃាត់លោក ហើយឲ្យលោកនៅ<>កន្លែង<មួយ ហើយ>មិនឲ្យលោកទៅៗជួបម្ដាយរបស់លោកទេ។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** តើគេឃាត់លោកទុកហ្នឹង គឺឃាត់ទុកនៅកន្លែងណាដែរ?

**ឆ៖** ពេលខ្ញុំចេញពីវត្តទៅ ដីចម្ងាយប្រហែលជា៣គីឡូម៉ែត្រពីៗវត្ត ហ្នឹងកន្លែងភូមិចាស់ម្ដាយខ្ញុំ។ មកដល់ពេលខ្ញុំទៅរកគាត់ដល់ត្រឹមភូមិចាស់ហ្នឹង គេក៏សួរខ្ញុំ សួរហើយ ខ្ញុំប្រាប់ថា ខ្ញុំនៅវត្តបឹងខ្នារ ទៅរកញោមម៉ែ។ អ៊ីចឹង គេៗអត់ឲ្យវិលមកវិញ ដល់គេឃាត់ខ្ញុំឲ្យនៅត្រឹមឃុំប្រសាទហ្នឹង តែដល់ពេលថ្ងៃរសៀល បានគេនាំខ្ញុំយកទៅដាក់នៅវត្តព្រៃកន្ទួត ចម្ងាយដីប្រហែលជា៣០គីឡូម៉ែត្រ ពីៗភូមិទៅ។

[០៩:១៧:០៣]

**ស៖** អ៊ីចឹងបានន័យថាពីឆ្នាំ៧២ ដល់ ៧៥ហ្នឹង គឺថាលោកនៅបួសជាព្រះសង្ឃ លោកនៅស្លៀកស្បង់នៅឡើយទេ ទោះបីថា ខ្មែរក្រហមឃាត់ឃាំង ឬក៏ទុកលោកនៅមួយកន្លែងហ្នឹងក៏ដោយ អ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** លោកប្រាប់ថា គេហៅលោកទៅចូលរួមប្រជុំ ហើយនៅក្នុងការប្រជុំហ្នឹង គេប្រាប់ថា គេឈប់ឧបត្ថម្ភ ឈប់អីហើយ ឲ្យលោកត្រូវធ្វើស្រែ។ តើគេធ្វើចំពោះព្រះសង្ឃទាំងអស់ ឬមួយក៏យ៉ាងម៉េចដែរ? <តើមានការលើកលែងទេ?>

**ឆ៖** បាទ នៅកន្លែងដែលខ្ញុំរស់នៅក្នុងស្រុកបាកានហ្នឹង គឺទាំងអស់។

**ស៖** តើមានព្រះសង្ឃអង្គណាខ្លះដែលប្រឆាំង ឬក៏តវ៉ាដែលគេផ្សឹកលោកដែរឬទេ?

**ឆ៖** អត់មានអង្គណាប៉ាានផង ដល់អ៊ីចឹងនៅស្ងៀមទាំងអស់គ្នាទៅ ហើយក៏ចេះតែសឹកម្ដងមួយៗ យូរៗទាល់តែអស់ពីវត្តទៅ។

[០៩:១៨:៣៤]

**ស៖** ក្រោយពេលជ័យជម្នះរបស់ខ្មែរក្រហមនៅខែមេសា ៧៥ រហូតដល់ពេលដួលរលំក្នុងឆ្នាំ៧៩។ តើលោកឃើញ មានឃើញព្រះសង្ឃអង្គណាមួយដែលគេអនុញ្ញាតឲ្យបន្តប្រតិបត្តិសាសនាដែរឬទេ នៅក្នុងរបបនោះ?

**ឆ៖** បាទ ពេលហ្នឹង អត់ផង អត់មានលោកទេ អស់រលីង។

**ស៖** ចុះការគោរពប្រតិបត្តិព្រះពុទ្ធសាសនា ឬក៏ប្រពៃណីទំនៀមទម្លាប់ផ្សេងទៀតហ្នឹង នៅក្នុងតំបន់ដែលលោករស់នៅ តើគេអនុញ្ញាតឲ្យប្រជាជនធ្វើការគោរពទៅតាមជំនឿសាសនារបស់ខ្លួន ដូចជា បួងសួង ថ្វាយបង្គំ រៀបការ ឬក៏បុណ្យសពអី តើមានសកម្មភាពនេះទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលជួបប្រទះផង គឺអត់ដែលឃើញគេធ្វើបុណ្យសព ឬក៏គេរៀបការហ្នឹងអីទេ អត់ផង។

**ស៖** តើលោកដឹងទេថា របបនុ៎ង អនុញ្ញាតឲ្យមានការគោរពព្រះពុទ្ធសាសនា ឧទាហរណ៍ ដូចជា ការគោរពទៅតាមព្រះពុទ្ធសាសនា អ៊ីស្លាមសាសនាអីជាដើម។ តើរបបហ្នឹង គេអនុញ្ញាតឲ្យបែបនេះទេ?

[០៩:២០:១៨]

**ឆ៖** អត់ផងពេលហ្នឹង។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះខ្ញុំនឹងបន្តសំណួររបស់ខ្ញុំ <-- លោកបាននិយាយពីបញ្ហានេះច្រើនរួចមកហើយ ខ្ញុំ>មិនសួរទាំងអស់ឡើងវិញទេ ប៉ុន្តែខ្ញុំចង់សួរអំពីពេលដែលគេប្រគល់កាំភ្លើងឲ្យលោក ហើយលោកចូលទៅក្នុងកងអនុសេនាតូច<៣៥>នៃកងវរសេនាធំ<១៨>។ លោកប្រាប់ថា <គេបានបញ្ជូនលោកឲ្យទៅយាមការពារទាហាន ឬអ្នករដ្ឋការ>លន់ នល់។ ដូច្នេះតើលោកអាចប្រាប់បានទេថាតើគេប្រាប់ទាហាន ឬក៏មន្ត្រីរដ្ឋការទាំងអស់នោះយ៉ាងដូចម្ដេចដែរនៅក្នុងក្រុមនោះ?

**ឆ៖** គេអត់មានប្រាប់យ៉ាងម៉េចផង។

**ស៖** តើគេមានប្រាប់ទាហានទាំងអស់នោះថាត្រូវទៅណាទេ?

**ឆ៖** ត្រង់ហ្នឹង ខ្ញុំអត់ដឹងដែរ អត់ដឹងថាគេឲ្យទៅណា ខ្ញុំអត់ដឹង។

**ស៖** លោកបាននិយាយអំពីសម្ដេចសីហនុ។ តើលោកអាចពន្យល់បានទេ ថាតើសម្ដេចសីហនុមានទំនាក់ទំនង ឬក៏មានពាក់ព័ន្ធអ្វីជាមួយហេតុការណ៍នោះ?

**ឆ៖** អត់ ខ្ញុំអត់ដឹងផង ព្រោះអត់ដែលឃើញផង ហើយអត់ដែលឮគេនិយាយពីសម្ដេចផង។

**ស៖** តើទាហានដែលលោកឃើញហ្នឹងគឺថាពួកទាហានទាំងអស់នោះអត់មានអាវុធទេ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ព្រោះអត់មានអាវុធផង។

[០៩:២២:៤៦]

ស៖ តើគេមានចងទាហាននោះទេ?

ឆ៖ គេអត់មានចងមានអីផង គេឲ្យដើរធម្មតា។

ស៖ លោកនិយាយថាមួយក្រុមហ្នឹងមានជាង៥០នាក់ តើតាមដែលលោកដឹង តើមានអ្នកណាដែលនៅរស់រានមានជីវិត <ពីការបាញ់សម្លាប់ដែរ>ទេ?

ឆ៖ ពេលហ្នឹង ឃើញរត់រួចប្រហែលជាបីនាក់អីដែរ ប៉ុន្តែមិនដឹងជារស់ មិនដឹងជាងាប់ទេ ហើយគេក៏អត់មានតាម មានអីដែរ គឺរត់ទៅបាត់រហូតទៅ។

ស៖ អ៊ីចឹងអ្នកផ្សេងទៀតក្រៅពីបីនាក់ដែលរត់ហ្នឹង គឺអ្នកទាំងអស់ផ្សេងទៀតហ្នឹងត្រូវបានគេសម្លាប់ អ៊ីចឹងមែនទេ?

[០៩:២៣:៥២]

ឆ៖ បាទ គេសម្លាប់ទាំងអស់ អ្នកដែលនៅហ្នឹង។

ស៖ តើក្នុងក្រុមហ្នឹងមានសុទ្ធតែបុរស ឬក៏មានទាំងបុរស មានទាំងនារីដែរ?

ឆ៖ បាទ ហ្នឹងខាងទាហាន ឬខាងណា?

ស៖ សូមអរគុណ ខ្ញុំចង់សួរអំពីទាហាន លន់ នល់។ តើក្នុងក្រុមដែលគេយកទៅបាញ់ហ្នឹង តើមាននារីនៅក្នុងក្រុមនោះទេ?

ឆ៖ អត់មានទេនារី មានសុទ្ធបុរសទាំងអស់។

ស៖ លោកនិយាយអំពីឯកសណ្ឋាន។ តើពួកគាត់ទាំងអស់ហ្នឹងពាក់ឯកសណ្ឋានទាំងអស់គ្នា ឬក៏មានតែខ្លះទេដែលពាក់ឯកសណ្ឋាន?

ឆ៖ អ្នកទាំងអស់គ្នាហ្នឹង ស្លៀកពាក់ឯកសណ្ឋានទាហានទាំងអស់។

ស៖ នៅពេលនោះ តើលោកអាចដឹងអំពីឯកសណ្ឋាន ថាជាឯកសណ្ឋានរបស់ទាហានខាងណាៗ ទេ?

ឆ៖ ឯកសណ្ឋានហ្នឹងខោអាវ ប៉ារ៉ា ទាហានលន់នល់។

[០៩:២៥:៣៩]

ស៖ តើលោកមានស្គាល់អ្នកណាម្នាក់នៅក្នុងក្រុមនោះទេ?

ឆ៖ បាទ ខ្ញុំអត់មានស្គាល់ទេ។

**ស៖** លោកនិយាយថា គេទាត់លោកហើយបង្ខំឲ្យលោកបាញ់ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ។

**ស៖** តើលោកមានបានបាញ់កាំភ្លើងតាមគេប្រាប់ទេ?

**ឆ៖** បាទ ពេលដែលគេទាត់ខ្ញុំឲ្យបាញ់ហ្នឹង ពេលហ្នឹង គេអ្នកបាញ់ពីខាងក្រោយ គេបាញ់ដួលអស់ហើយ ព្រោះពេលហ្នឹង កំពុងតែភ័យញ័រ ព្រោះខ្ញុំឃើញអ៊ីចឹង វាតក់ស្លុត។

**ស៖** សូមអរគុណ។ ខ្ញុំសួរលោកមិនច្បាស់ មើលទៅ។ ឥឡូវខ្ញុំសួរលោកអ៊ីចេះវិញ ក្រោយពេលដែលហេតុការណ៍នេះកើតឡើង គឺក្រោយពេលដែលគេសម្លាប់មនុស្សទាំងអស់នេះ តើលោកនៅពេលក្រោយមកហ្នឹង តើលោកធ្លាប់ប្រើកាំភ្លើងបាញ់សម្លាប់មនុស្សផ្សេងទៀតនៅក្នុងសមរភូមិ ឬក៏នៅក្នុងហេតុការណ៍ណាផ្សេងដែរទៀតទេ?

[០៩:២៧:២៩]

**ឆ៖** អត់ ព្រោះពេលហ្នឹងគេឲ្យពួកខ្ញុំហ្នឹងមកនៅហ្នឹងមោង។ ដល់ពេលខ្ញុំមកនៅហ្នឹងមោងហ្នឹង ពេលដែលខ្ញុំឃើញហេតុការណ៍ហ្នឹងកើតឡើងអ៊ីចឹង ខ្ញុំនឹកឃើញ ចុះគេធ្វើបដិវត្តន៍ម៉េចបានយកមនុស្សទៅសម្លាប់អ៊ីចឹង ដល់អ៊ីចឹង ខ្ញុំសួរគេ។ ដល់ពេលខ្ញុំសួរ ឈ្មោះ ឌឿន ដែលខ្ញុំស្គាល់ហ្នឹងគេ បានថាឲ្យខ្ញុំថា -- អំ! ខ្ញុំសួរគេថា ចុះម៉េចបានគេយកទាហានហ្នឹងមកធ្វើអ៊ីចឹង គេអត់ទុកយកកម្លាំងសម្រាប់ពលកម្ម? គេថា មិត្តឯងចង់ដឹងទូលំទូលាយម្ល៉េះ។ ដល់ពេលខ្ញុំសួរគេអ៊ីចឹង ខ្ញុំគិតឃើញខ្លួនខ្ញុំថា ខ្ញុំសួរគេនេះ វាខុសសំណួរខ្ញុំពិតជាខុសហើយ។ អ៊ីចឹង ខ្ញុំលែងហ៊ានសួរ ហើយខ្ញុំនៅឈរស្ងៀម ហើយខ្ញុំគិតថា ហ៊ឺស! មិនដឹងជាថ្ងៃណាមួយ ប្រហែលជាគេ ចាប់ពីពេលនេះទៅ គេតាមដានខ្ញុំហើយយ៉ាង។ ដល់អ៊ីចឹង ខ្ញុំចេះតែមានអារម្មណ៍អត់ស្រួលខ្លួនឯង ចេះតែគិតជារៀងរហូតទើសដល់ថ្ងៃ ប្រហែលជាមួយខែ ឬមិនដល់មួយខែទេ ដែលគេឲ្យខ្ញុំទៅរទេះភ្លើង។ ដល់គេដកខ្ញុំឲ្យទៅធ្វើកម្មកររទេះភ្លើងហ្នឹង ធ្វើកម្មករផ្លូវដែកហ្នឹង--

[០៩:២៩:១៩]

**ស៖** សូមអរគុណ ព្រោះថា នៅសល់ពីរបីចំណុចទៀត នៅក្នុងចម្លើយរបស់លោក ដែលខ្ញុំចង់ឲ្យលោកបញ្ជាក់។ ដំបូងលោកនិយាយថា កងរបស់លោក ត្រូវបានគេផ្ទេរឲ្យទៅធ្វើការនៅកន្លែងណាមួយ <ខ្ញុំគិតថា លោកនិយាយថា មោង។> ប៉ុន្តែខ្ញុំប្រហែល<និយាយ>ឈ្មោះហ្នឹងមិនច្បាស់<ទេ>។ ដូច្នេះខ្ញុំចង់សួរថា តើកងមួយណាដែលគេបញ្ជូនទៅហ្នឹង ហើយតើគេបញ្ជូនកងលោកហ្នឹង គេបញ្ជូនទៅ

កន្លែងណាដែរ?

**ឆ៖** គេ ដល់ពេលអ៊ីចឹង គេជ្រើ អត់មានថាកងហ្នឹងមួយ ពេលគេដកហ្នឹង មិនដឹងគេ ជ្រើពីណាៗទេ មកបញ្ចូលគ្នា ហើយគេបញ្ជូនមកឲ្យធ្វើកម្មកររទេះភ្លើង។

**ស៖** អ៊ីចឹងបានន័យថា ក្រុមទាំងអស់ត្រូវបានគេបញ្ជូនឲ្យទៅធ្វើការជាមួយលោក <ធ្វើផ្លូវ> រថភ្លើង <គឺជា>អតីត<យោធា ឬ>ទាហានខ្មែរក្រហម <ឬ>?

[០៩:៣០:២៥]

**ឆ៖** បាទ គេជ្រើអ្នកដែលនៅជាមួយខ្ញុំពីមុនមកហ្នឹង គេជ្រើបំបែកគ្នាអស់ហើយ។ ដល់អ៊ីចឹង គេឲ្យទៅកម្មករហ្នឹង ដល់ទៅដល់វ៉ារទេះភ្លើងហ្នឹង សុទ្ធតែមកពីកន្លែងផ្សេងៗគ្នា ទៅជួបគ្នាឯនុ៎ង។

**ស៖** តើស្ថានីយរថភ្លើងហ្នឹងនៅក្នុងខេត្តបាត់ដំបង ឬក៏នៅខេត្តផ្សេង?

**ឆ៖** បាទ នៅក្នុងស្ថានីយបាត់ដំបង។

**ស៖** តើ ឌឿន ត្រូវបានគេបញ្ជូនទៅ<ធ្វើផ្លូវ>រថភ្លើងហ្នឹងដែរឬទេ?

**ឆ៖** ឌឿន ហ្នឹងក្រោយមក មិនដឹងគេឲ្យទៅណា ខ្ញុំអត់ដឹងដែរ។

**ស៖** តើលោកអាច<ប្រាប់អំពីអ្វីដែលលោកដឹងអំពី>ប្រវត្តិរូបរបស់ ឌឿន ហ្នឹងដល់អង្គជំនុំជម្រះបានទេ?

**ឆ៖** បាទ ឌឿន ហ្នឹងខ្ញុំជួបរយៈពេលខ្លីដែរ។ ហើយខ្ញុំអត់សូវហ៊ានសួរគេថា គេនៅឯណា ស្រុកទេសឯណា ហើយរស់នៅឯណា។ ខ្ញុំអត់ដែរបានសួរគេផង។ ហើយដល់ រហូតដល់បែកគ្នា បែករហូតទល់មកសព្វថ្ងៃនេះទៅ។

[០៩:៣១:៥៧]

**ស៖** សូមអរគុណ។ តើ ឌឿន ហ្នឹង គឺជាប្រធានកង៣៥មែនទេ?

**ឆ៖** បាទ។

**ស៖** សូមអរគុណ។ តើលោកអាចប្រាប់បានទេ<នូវអ្វីដែលលោកដឹងអំពីការងារផ្លូវ>រថភ្លើងហ្នឹង<ក្នុងអំឡុងឆ្នាំដែលលោកធ្វើការនៅទីនោះ? លោកបាននិយាយថា លោកនៅទីនោះ>រហូតដល់ឆ្នាំ៧៩<ពេលដែលវៀតណាមមកដល់។> តើរថភ្លើង<រត់>ពីទីណា<>ទៅដល់ទីណា? មកពីទីណាមកដល់ទីណាវិញ? លោកដឹងទេ?

**ឆ៖** បាទរថភ្លើងហ្នឹងមិនដឹងជាគេចេញពីបាត់ដំបងហ្នឹងទៅដល់ត្រឹមណា អីត្រឹមណា ហ្នឹងខ្ញុំ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អត់ដឹងទេ ព្រោះខ្ញុំ គេឲ្យធ្វើផ្លូវ ធ្វើផ្លូវដែកពីចន្លោះអូរស្រឡៅមកបាត់ដំបង ពីបាត់ដំបងមកក្បាលខ្មោច។ អ៊ីចឹងពួកខ្ញុំមួយក្រុមហ្នឹងធ្វើតែផ្លូវដែក និងស្ពាន។

**ស៖** តើលោកឃើញរទេះភ្លើង<បើកឆ្លងកាត់ដែរ ឬ>ទេ?

**ឆ៖** បាទ រទេះភ្លើងហ្នឹងឃើញបើករាល់ថ្ងៃទៅមកៗតែអ៊ីចឹងទៅ។ ហើយតែមិនដឹងជាទៅដល់ត្រឹមណា ឬឈប់ត្រឹមណាអី ខ្ញុំអត់ដឹង។

[០៩:៣៣:៥៣]

**ស៖** តើលោកធ្លាប់ឃើញរថភ្លើងហ្នឹងឈប់នៅបាត់ដំបងទេ?

**ឆ៖** បាទ រថភ្លើងហ្នឹងឈប់នៅបាត់ដំបង នៅនឹងវ៉ាហ្នឹង។

**ស៖** តើលោកធ្លាប់ឃើញគេលើកអីវ៉ាន់ដាក់ឡើងរថភ្លើង ឬក៏ទម្លាក់ចុះពីលើរថភ្លើងដែរឬទេ?

**ឆ៖** ខ្ញុំពេលលើកដាក់ ខ្ញុំអត់ដែលឃើញទេ។ តែបើពេលដែលគេដាក់ចុះ ខ្ញុំធ្លាប់បានឃើញខ្លះ។

**ស៖** តើលោកធ្លាប់ឃើញមនុស្សឡើងចុះលើរថភ្លើងហ្នឹងទេ?

**ឆ៖** បាទរថភ្លើងហ្នឹងអត់ដែលឃើញមានមនុស្សជិះច្រើនៗផង ឃើញតែគេបិទទ្វារជិតៗអ៊ីចឹង មានតែអ្នកបើក និងអ្នកមើលថែប្រាំងតាមបារ៉ុង តាមអីហ្នឹងឃើញ តែដល់ពេលមនុស្សជិះ ដូចយើងពីសង្គមរាស្ត្រនិយមអត់ អត់មាន។

**ស៖** តើលោកធ្លាប់ឃើញមនុស្សមកពីតំបន់របស់លោក ត្រូវបានគេបញ្ជូនតាមរថភ្លើង<មកពី>ភូមិភាគបូព៌ា ឬក៏<មកពីទីកន្លែង>ផ្សេងៗទៀតទេ?

[០៩:៣៥:៣៧]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អញ្ជើញលោកមេធាវី វ៉ិកទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជំរាបសួរអស់លោកលោកស្រីទាំងអស់គ្នា ខ្ញុំជំទាស់ទៅហ្នឹងសំណួរនេះ។ ទោះថាមានអ្វីកើតឡើងចំពោះអ្នកមកពីបូព៌ា ឬក៏ប្រជាជនខ្មែរក្រោម ត្រូវបានគេបញ្ជូនពីបូព៌ាក្នុងឆ្នាំ៧៨នេះក៏ដោយ គឺវាស្ថិតនៅក្រៅវិសាលភាពនៃសំណុំរឿង០០២/០២នេះ។ ហើយតាមខ្ញុំយល់គឺថាវាដូចគ្នាទៅនឹងជោគវាសនារបស់ទាហាន លន់ នល់ គឺនៅភ្លាមៗក្រោយពេលជម្លៀសពោធិ៍សាត់ ហើយនិងបាត់ដំបងនោះ។ ប៉ុន្តែចំពោះខ្មែរក្រោម ហើយនិងបូព៌ាវិញ ខ្ញុំគិតថាមានសេចក្ដី

សម្រេចមួយរបស់អង្គជំនុំជម្រះនៅពេលដែលនិយាយអំពីខ្មែរក្រោម។ ដូច្នេះ ខ្ញុំគិតថាសំណួរទាំងអស់របស់ព្រះរាជអាជ្ញា គឺទាក់ទងទៅនឹងប្រធានបទដែលស្ថិតក្រៅវិសាលភាពនៃសំណុំរឿង០០២/០២នេះ សូមអរគុណ។

[០៩:៣៦:៥១]

**លោក នីកូឡាស គូមជែន៖**

លោកប្រធានខ្ញុំមិនបាននិយាយអំពីខ្មែរក្រោមទេ។ ខ្ញុំនិយាយអំពី<ផ្លូវ>រថភ្លើង ហើយនិងតួនាទីជាយុទ្ធសាស្ត្ររបស់<ផ្លូវ>រថភ្លើង។ <នោះជាប្រធានបទដែលខ្ញុំកំពុងតែលើកឡើង។> ចំពោះការសម្លាប់ទាហាន លន់ នល់ វិញ គឺវានៅក្នុងវិសាលភាព ០០២/០១ គឺមានតែការសម្លាប់ទាហាន លន់ នល់ ជាទ្រង់ទ្រាយធំប៉ុណ្ណោះនៅទួលពោធិ៍ជ្រៃ គឺវាជាផ្នែកតែមួយគត់នៃសំណុំរឿង០០២/០១។ <សល់ពីនោះគឺជាផ្នែកនៃសំណុំរឿង ០០២/០២។ ដូច្នេះ ខ្ញុំគ្រាន់តែសួរថាតើគាត់បានឃើញមនុស្សត្រូវបានគេដឹកជញ្ជូន ឬក៏<>បានឮ<ពីប្រជាជនថាពួក>គេ<ត្រូវបាន>ដឹក<ជញ្ជូន>តាមរថភ្លើងដែរឬទេ? គឺវា<អាស្រ័យទៅលើលោក ប៉ុន្តែ>ខ្ញុំគ្រាន់តែនិយាយអំពីតួនាទី ឬក៏មុខងារយុទ្ធសាស្ត្ររបស់រថភ្លើងតែប៉ុណ្ណោះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចៗបដិសេធនូវសេចក្ដីជំទាស់របស់មេធាវីការពារក្ដី។ អង្គជំនុំជម្រះក៏ចង់ត្រូវការស្ដាប់នូវចម្លើយតបរបស់សាក្សីចំពោះសំណួរនេះដែរ។ សាក្សីចាំទេ បើចាំឆ្លើយតបនឹងសំណួរដែលសួរឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិអម្បាញ់មិញនេះ! ទំនងជាភ្លេចហើយសូមលោកសហព្រះរាជអាជ្ញាតាំងសំណួរ រៀបចំសំណួរសាជាថ្មី។

[០៩:៣៨:១៦]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ខ្ញុំនឹងសួរបន្ថែម ប៉ុន្តែខ្ញុំនឹងបន្ថែមបន្តិចទៀត។ ខ្ញុំចង់សួរលោកថា តើលោកធ្លាប់ឮអ្នកណាម្នាក់ប្រាប់លោកទេ អំពីមនុស្សដែលគេដឹកតាមរថភ្លើងពីផ្នែកផ្សេងៗនៅក្នុងប្រទេសកម្ពុជា រួមទាំងជនស៊ីវិល ឬមួយក៏កងទ័ពមកពីខាងនិរតីអីជាដើមហ្នឹង។ តើលោកធ្លាប់ឮថាគេមានដឹកមនុស្សតាមរថភ្លើងហ្នឹងទេ?

**លោក ជាល ជឿន៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ខ្ញុំអត់ដែលឮ អត់ដែលដឹង។

**ស៖** លោកនិយាយថាលោកធ្លាប់ឃើញគេ<>លើកអីវ៉ាន់<ដាក់លើ>រថភ្លើង តើអីវ៉ាន់ហ្នឹង អីវ៉ាន់អ្វីដែរ?

**ឆ៖** ខ្ញុំឃើញអីវ៉ាន់ហ្នឹងគេដាក់ចុះមកហ្នឹងមានតែស៊ីម៉ងត៍ មានតែអំបិលអី អត់មានស្អីទៀតផង។ តែដោយអីវ៉ាន់អីផ្សេងៗ អាហ្នឹងគេមិនដឹងជាមានអីក៏អត់ទេ ព្រោះគេមិនសូវឲ្យយើងទៅជិតបៀត ទៅឈរមើលគេអីផងពេលគេដាក់ចុះហ្នឹង។ ហើយខ្ញុំគ្រាន់តែធ្លាប់ឃើញស៊ីម៉ងត៍ ហើយគេដាក់នៅនឹងឃ្លាំងក្នុងវ៉ារទេះភ្លើងហ្នឹង។

[០៩:៣៩:៥៦]

**ស៖** តើមានទីប្រឹក្សាបរទេសធ្វើការនៅស្ថានីយរថភ្លើងហ្នឹងទេ ឧបមាដូចជា បរទេសហ្នឹងដូចជាចិន ឬក៏ជនជាតិដទៃទៀតហ្នឹង ដែលលោកធ្លាប់ឃើញ តើមានទេ?

**ឆ៖** នៅនុំងវ៉ារថទេះភ្លើងហ្នឹង នៅក្នុងកន្លែងដែលខ្ញុំរស់នៅហ្នឹង ខ្ញុំអត់ដែលឃើញ ចិន។ មិនដឹងគេឲ្យនៅឯណាអីណាផង បាទ បើខ្ញុំនៅហ្នឹងអត់មានទេ។

**ស៖** តើក្នុងរយៈពេល៤ឆ្នាំក្នុងរបបហ្នឹង តើលោកធ្លាប់ឃើញជនជាតិចិនជាទីប្រឹក្សានៅកន្លែងណាមួយក្នុងប្រទេសកម្ពុជាទេ?

**ឆ៖** ឃើញ ប៉ុន្តែខ្ញុំឃើញតែគេនៅក្នុងផ្ទះថ្មមុខវ៉ាហ្នឹង ប៉ុន្តែមិនដឹងជាគេធ្វើអីកន្លែងណា អាហ្នឹងខ្ញុំអត់ដឹងទេ ប៉ុន្តែគ្រាន់តែខ្ញុំបានឃើញពីខ្ញុំមើលពីវ៉ាទៅ ឃើញនៅនុំងម្តុំហ្នឹង ហើយនិងកម្មករដូចគ្នាហ្នឹងនិយាយថា កន្លែងហ្នឹងកន្លែងភ្ញៀវចិន គេគ្រាន់តែថាប៉ុណ្ណឹង។

[០៩:៤១:២៦]

**ស៖** តើលោកដឹងទេថាជនជាតិចិនទាំងអស់នោះ គាត់មានតួនាទីជាអ្វីដែរ ហើយពួកគាត់ធ្វើការងារអ្វីដែរ?

**ឆ៖** ត្រង់ហ្នឹង ខ្ញុំអត់ដឹង មិនដឹងគេធ្វើអី ព្រោះខ្ញុំពេលក្រោយមក តែម៉ោងបួនឡើង គេឲ្យងើបចេញមកធ្វើផ្លូវដែកហើយ។

**ស៖** តើម្ហូបអាហារដែលគេផ្តល់ទៅដល់កម្មករនៅរថភ្លើងហ្នឹង គឺមានភាពគ្រប់គ្រាន់ដែរឬទេ?

**ឆ៖** បាទ ពេលហ្នឹងជីវភាព វាមិនគ្រប់គ្រាន់អីទេ ប៉ុនគ្រាន់តែថាយើងចេះតែហូបទៅ ហើយដូចពួកខ្ញុំមួយក្រុមដែលគេឲ្យដើរធ្វើផ្លូវដែកហ្នឹង ពេលព្រឹកឡើងក្រោកពីម៉ោងបួនហ្នឹង ទៅបើកអង្គរពី

01385923



ការដ្ឋានគេមកហ្នឹង យកទៅធ្វើ -- យកទៅបបរទៅអីតាមកន្លែងការដ្ឋានដែលធ្វើផ្លូវគ្នាខ្ញុំប៉ុន្មាននាក់ហ្នឹង។ បើករបបហ្នឹងមក យកទៅបបរដាក់ត្រួយល្ពៅ ដាក់ផ្លែល្ពៅអីចឹងទៅ ជួនកាលបេះស្លឹកបះស្លឹកអីលាយអីចឹង។

**ស៖** តាមដែលលោកដឹង ដែលលោកឃើញ ឬក៏លោកឮ តើកម្មករ<ផ្លូវ>រថភ្លើងហ្នឹងទទួលបានការរស់នៅដែលប្រសើរជាងកម្មករ<ធម្មតា នៅក្នុងតំបន់ នៅអំឡុងពេលនោះដែរ ឬទេ>?

[០៩:៤៣:៣៣]

**ឆ៖** បាទ កម្មកររទេះភ្លើងហ្នឹង ខ្ញុំបើតាមដែលខ្ញុំរស់នៅយើងអាចរក ដូចជាត្រួយល្ពៅ ផ្លែល្ពៅ ស្លឹកបះ ហើយក៏ចេកអីយកមកលាយបបរលាយអីហ្នឹង អាចៗប្រសើរជាងបន្តិច មិនមែនជាខ្លាំងពេក វាគ្រាន់តែថាវាគ្រាន់ជាងបន្តិចប៉ុណ្ណឹងឯង។ បើគ្រាន់ថាបើហូបឲ្យឆ្អែក វាអត់ឆ្អែតទេ វាគ្រាន់ថាត្រឹមម៉ារស់បាន។

**ស៖** ខ្ញុំចង់សួរអីចេះ គឺថាប្រហែលមានកម្មករដទៃទៀត គាត់មកធ្វើការនៅស្ថានីយរថភ្លើងដែរ តើលោកដឹងទេថា ស្ថានភាពកម្មករដែលរស់នៅស្ថានីយរថភ្លើងហ្នឹង វាប្រសើរជាងកម្មករដែលនៅកន្លែងផ្សេងទៀត ឬមួយក៏យ៉ាងណា? ប្រសិនបើលោកដឹងសូមលោកប្រាប់ បើលោកមិនដឹងទេ លោកគ្រាន់តែឆ្លើយថាមិនដឹងទៅ គឺបានហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប! អីចឹងលោកស្រីមេធាវី អត់តា ហ្គីសសេ!

[០៩:៤៤:៥៨]

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំដូចជា វង្វេងហើយ ក្នុងពេលសហព្រះរាជអាជ្ញាសួរសំណួរទៅកាន់សាក្សីនេះ។ ខ្ញុំសូមជំទាស់ ពីព្រោះថាសំណួរនេះ វាមិនចូលទៅក្នុងវិសាលភាព<សំណុំរឿង០០២/០២នោះ>ទេ ដូចជាការដ្ឋានផ្លូវដែក <នៅខេត្តបាត់ដំបង>ហ្នឹង គឺមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿងយើងនេះទេ។<> អីចឹង ខ្ញុំអត់យល់ពីសំណួររបស់គាត់។ ខ្ញុំសូមជំទាស់។

**លោក នីកូឡាស គូមជែន៖**

លោក លោកស្រីចៅក្រម ដើម្បីពន្យល់ គឺខ្ញុំចង់និយាយអំពីចំណែកដែល ហ្វីលីព ស្សូត បាននិយាយ<នៅក្នុងសៀវភៅរបស់គាត់> ដែលថាមនុស្សមួយចំនួន<ដែលមានតួនាទីទទួលខុសត្រូវ បាន

រស់នៅដោយឡែកពីប្រជាពលរដ្ឋទូទៅ ហើយនិង>ក្រុម<>អាទិភាព ឧទាហរណ៍ដូចជា <>កម្មករ<ផ្លូវ>រថភ្លើង <ដែលមានភក្តីភាពចំពោះរបបនោះ>គឺថាពួកគាត់មិន<ត្រឹមតែ>ទទួលបានគ្រប់គ្រាន់នោះទេ គឺថា<>ទទួលបាន<ល្អប្រសើរ>។ ហេតុដូច្នេះហើយ ទើបខ្ញុំសួរគាត់ទាក់ទងទៅនឹងចំណុចនេះ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ដូច្នេះលោកសាក្សី តើលោកអាចឆ្លើយប្រាប់បានទេ ប្រសិនបើលោកដឹងថា កម្មករ<ផ្លូវ>រថភ្លើងហ្នឹង គាត់មានការរស់នៅដោយប្រសើរជាងកម្មករនៅកន្លែងដទៃទៀត<នៅក្នុងតំបន់នោះ> ឬក៏យ៉ាងម៉េច?

[០៩:៤៦:៣០]

**លោក ជាល ជឿន៖**

**ឆ៖** បាទ ពេលនុ៎ង ខ្ញុំមិនអាចដឹងថា កន្លែងខ្ញុំនៅហ្នឹងប្រសើរជាងកន្លែងដទៃ ឬកន្លែងដទៃប្រសើរជាង។ ខ្ញុំអត់ដឹង ព្រោះគេមិនឲ្យយើងដើរចេញចូលពីមួយទៅមួយ ហើយទាក់ទងពីកន្លែងមួយទៅកន្លែងមួយ ដល់អ៊ីចឹងអត់ដឹង។

**ស៖** មិនអីទេ ខ្ញុំនឹងបន្តទៅប្រធានបទថ្មីមួយទៀត។ លោកបាននិយាយអំពីការជួយថតខ្សែភាពយន្ត<មួយ>។ តើលោកអាចប្រាប់បានទេ <ហេតុអ្វីបានជាលោកធ្វើដូច្នោះ? ហេតុអ្វីបានជា>លោកជួយ<ក្នុង>ការថតភាពយន្តឯកសារនោះ?

**ឆ៖** ថតភាពយន្តឯកសារហ្នឹង ខ្ញុំមិនបានជួយជាស្អីទេ ប៉ុន្តែគ្រាន់តែថា គេហៅទៅបានពីរនាក់គេអ៊ីចឹងទៅ។ អ្នកដែលគេថតហ្នឹង គេឲ្យដើរបានពីរនាក់គេ និងកន្លែងខ្លះគេអត់ដឹង គេហៅខ្ញុំទៅឲ្យបានគ្នា ហើយអាចបង្ហាញផ្លូវគេ ទៅពីត្រង់ណាៗបាន។

**ស៖** សូមអរគុណ។

[០៩:៤៨:១២]

**លោក នីកូឡាស គូមជែន៖**

លោក លោកស្រីចៅក្រម ខ្ញុំមានខ្សែវីដេអូខ្លីៗ ពីរបីដែលគេសម្ភាសសាក្សី ហើយខ្សែវីដេអូនេះគឺនៅក្នុងសក្ខីកម្មកាលពីថ្ងៃសុក្រ <ដែល>គាត់<បាននិយាយអ្វី ដែលគាត់>មិនបាននិយាយ<នៅក្នុងការសម្ភាស>នេះទេ <ហើយ>ខ្ញុំចង់សូមអនុញ្ញាតចាក់បង្ហាញខ្សែវីដេអូនេះ ដើម្បីឲ្យសាក្សីបាន មើ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01385925



ល។ ទី១ គឺទាក់ទងទៅនឹងឈ្មោះដែលគាត់ផ្ដល់ ទាក់ទងទៅនឹងមេបញ្ជាការកងអនុសេនាធំមួយ។ សូមទោស ខ្ញុំកំពុងតែរកឯកសារ គឺនៅទំព័រ៨៨ នៃ<សេចក្ដីព្រាង>ប្រតិចារឹក នៅម៉ោង <១៤:១៣:៣៧> វិនាទី សាក្សីបានអំពីឈ្មោះមេបញ្ជាការអនុសេនាធំមួយ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតចាក់បង្ហាញនៅខ្សែវីដេអូដែលគេសម្ភាសជាមួយសាក្សី <គឺឯកសារ E3/10681 ដែលសាក្សីនិយាយអំពីឈ្មោះនោះ>។ ខ្ញុំគិតថានេះគឺជាខ្សែអាត់សំឡេង<ទី>២។ <វាមានចំណងជើងខ្សែអាត់សំឡេងចំនួនពីរ> ប៉ុន្តែវាខ្លីទេ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតឲ្យចាក់ពីរដង ដើម្បីឲ្យអ្នកបកប្រែគាត់អាចបកប្រែទាន់។ <វានៅនាទីចុងក្រោយ>។ គឺថាខ្ញុំសូមអនុញ្ញាតឲ្យចាក់ពីរដងនោះ ដោយសារតែវាខ្លី ហើយប្រសិនបើយើងចាក់ពីរដងទៅ អ្នកបកប្រែ ក៏ដូចជាសាក្សី គាត់អាចស្ដាប់ឮបានដែរ។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតពីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ហើយផ្នែកខាងសោតទស្សន៍ចាក់ផ្សេងនូវវីដេអូឃ្លីនៅលើអេក្រង់ទូរទស្សន៍ តាមសំណើសុំរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ហើយចាក់ផ្សាយគឺដាក់ពីរដង ពីរសាណ៉ះ!

[០៩:៥១:០១]

*(ការបង្ហាញឯកសារជាសំឡេង)*

"សម័យហ្នឹង ខ្ញុំធ្វើ *(ឮមិនច្បាស់)* ក្នុងចន្លោះហ្នឹង សម្រាប់ខ្ញុំពួកខ្ញុំមួយក្រុម។ សម័យហ្នឹង ខ្ញុំធ្វើគ្រាប់បែក អីចឹងគឺចេះតែប៉ុណ្ណឹង ក្នុងចន្លោះហ្នឹង សម្រាប់ខ្ញុំពួកខ្ញុំមួយក្រុម។"

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង)*

[០៩:៥១:២៥]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថានេះគឺជាខ្សែអាត់ទី២ទេ <ដែលខ្ញុំចង់ឲ្យចាក់បញ្ចាំងផងដែរ>។ ហើយនេះគឺនិយាយពីអ្វីដែលលោកធ្វើនៅ<ផ្លូវ>រថភ្លើងនោះឯង។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមឲ្យមានការបកប្រែ ពីអ្នកបកប្រែ ទាក់ទងទៅនឹងអ្វីដែលនិយាយនៅក្នុងខ្សែអាត់នេះ ដើម្បីឲ្យខ្ញុំអាចយល់នូវការសួរ។ ខ្ញុំគិតថា ខ្សែអាត់ដែលចាក់ហ្នឹង គឺវាលឿនពេក <ខ្ញុំយល់ ប៉ុន្តែវាគួរតែមានការបកប្រែ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ខ្ញុំគិតថា គំនិតនោះគឺចង់ឲ្យ>ចាក់<ឃ្លីបមួយពីរដង។ នោះជាអ្វីដែលខុស។> ប៉ុន្តែខ្ញុំយល់ស្របថា ឥឡូវនេះ វាកំពុងតែធ្វើឲ្យច្របូកច្របល់ហើយ ព្រោះយើងស្តាប់មិនទាន់។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំសូមទោស ព្រោះថាខ្ញុំបានកត់នូវពេលវេលានេះ <ហើយនិងសំណួរ ហើយខ្ញុំមិនបានយកមកជាមួយខ្ញុំ>ទេ។ វាមានខ្សែអាត់ពីរ។ ទី១ គឺទាក់ទងទៅនឹងសាក្សី គាត់ឆ្លើយ<>ថា គាត់ជាអ្នកធ្វើគ្រាប់បែក ហើយខ្ញុំគិតថា អ្វីដែលបានចាក់មុននេះបន្តិចហ្នឹង គឺខ្សែអាត់នោះឯង។ ខ្ញុំមិនដឹងថាតើ<មានអ្នកណាមានលេខសំណួរចម្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយសាក្សីដែរឬទេ។> ខ្ញុំ<គិតថា សំណួរចម្លើយ>លេខទី៤២ <ប៉ុន្តែវាមិនមែនអ៊ីចឹងទេ>។

**ចៅក្រម ក្លូឌា ហ្វេនស័៖**

ប្រហែលជាអាចផ្តល់នៅពេលក្រោយ។ ដូច្នេះ ខ្ញុំចង់ចាក់ឯកសារខ្សែអាត់នេះ <ហើយសុំឲ្យមានការបកប្រែ>។

**លោក នីកូឡាស គូមជែន៖**

គឺថាវាមានចម្លើយពីរ។ ទី១ គឺសំណួរចម្លើយ៤២។ ខ្ញុំគិតថា នេះមិនមែនជាអ្វីដែលចាក់នោះទេ។ ប៉ុន្តែគឺនៅ វាចាប់ផ្តើមនៅម៉ោង -- នៅ១ម៉ោង ១២នាទី នៅក្នុងខ្សែអាត់សំឡេងនោះ។ ហើយទី២ ដែលខ្ញុំគិតថា ជាអ្វីដែលគេបានចាក់រួចហើយ គឺសំណួរចម្លើយ១២១ ដែលចាប់ផ្តើមនៅប្រហែលជា ២ ម៉ោង ១២នាទី និង២០វិនាទី។ <ដូច្នេះ ខ្ញុំមិនដឹងថា តើមួយណាដែលបានចាក់រួចហើយនោះទេ> ខ្ញុំសូមទោស ព្រោះខ្ញុំស្តាប់ភាសាខ្មែរអត់យល់ ប៉ុន្តែយើងអាចឲ្យ សូមឲ្យចាក់ឡើងវិញ នូវខ្សែអាត់សំឡេងហ្នឹង ហើយអ្នកបកប្រែ គាត់អាចបកប្រែ ដើម្បីឲ្យភាគីបានស្តាប់យល់ទាំងអស់គ្នា។

**ប្រធានអង្គជំនុំ៖**

បាទ ផ្នែកខាងសោតទស្សន៍ចាក់ផ្សាយនូវខ្សែអាត់សំឡេង មិនមែនៗជាវីដេអូទេ។ ខ្សែអាត់សំឡេងសក្ខីកម្មរបស់សាក្សី ដែលបានផ្តល់កាលពីពេលធ្វើកិច្ចការនោះ។

[០៩:៥៩:១៨]

*(ការបង្ហាញឯកសារជាសំឡេង)*

“មើល៍ៗ កងអនុសេនាធំហ្នឹង ឈ្មោះ វឿត។ (ភាសាអង់គ្លេស)។ បាទៗ”។

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[០៩:៥៤:៤០]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** នេះគឺសំណួរចម្លើយ៤២ មកពីកំណត់ហេតុស្ដាប់ចម្លើយ។ ខ្ញុំចាំថា គឺនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយ គេថាឈ្មោះ វុធ។ តើមេបញ្ជាការកងអនុសេនាធំរបស់លោកហ្នឹង ឈ្មោះអ្វីដែរ?

**លោក ជាល ជឿន៖**

**ឆ៖** ឈ្មោះ វឿត។

**ស៖** សូមអរគុណ។ ឥឡូវនេះ មានផ្នែកមួយទៀត គឺនៅសំណួរចម្លើយ១២១។ ខ្ញុំសូមអនុញ្ញាតចាក់បង្ហាញ ចាក់នូវខ្សែអាត់នោះដែរ។ គឺលោកនិយាយអំពីការធ្វើការនៅស្ថានីយរថភ្លើងបាត់ដំបង។ ហើយលោកនិយាយថា នៅសម័យនោះ គេឲ្យលោកធ្វើ<ការ>។ ដូច្នេះ ខ្ញុំសូមអនុញ្ញាតចាក់នូវខ្សែអាត់នោះឡើងវិញចំនួនពីរដង ដើម្បីឲ្យអ្នកបកប្រែគាត់អាចបកប្រែទាន់។ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត! ហើយផ្នែកខាងសោតទស្សន៍ចាក់ផ្សាយខ្សែអាត់នៅលើអេក្រង់ទូរទស្សន៍ឲ្យបានពីរដង ហើយអ្នកបកប្រែប្រឹងប្រែងស្ដាប់ ហើយនិងធ្វើការបញ្ជាក់ការបកប្រែបញ្ជាក់ឡើងវិញបញ្ហានេះឲ្យបានច្បាស់លាស់ ដើម្បីភាគីស្ដាប់បាន។

[០៩:៥៦:០៧]

*(ការបង្ហាញឯកសារជាសំឡេង)*

"សម័យនុំង ខ្ញុំធ្វើគ្រាប់បែក អ៊ីចឹងគឺចេះតែប៉ុណ្ណឹង ក្នុងចន្លោះហ្នឹង សម្រាប់ពួកខ្ញុំមួយក្រុម"។

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង)*

[០៩:៥៦:៣១]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី លោកមានបានស្ដាប់ឮខ្សែអាត់សំឡេងដែលយើងចាក់អំមិញទេ?

**លោក ជាល ជឿន៖**

**ឆ៖** បាទ ឮ។

**ស៖** តើលោកឮថា លោកនិយាយថា ក្រុមលោកធ្វើអ្វីដែរឬទេ?

**ឆ៖** បាទ ក្រុមខ្ញុំធ្វើផ្លូវដែក។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើលោកឆ្លើយថា លោកធ្វើអ្វីដែរនៅក្នុងរបបនោះ?

**ឆ៖** ខ្ញុំធ្វើកម្មករផ្លូវដែក។

**ស៖** ឥឡូវនេះ ខ្ញុំសួរលោកអ៊ីចេះវិញ។ ឥឡូវនេះ ខ្ញុំសូមឲ្យលោកសាក្សីស្ដាប់ម្ដងទៀត ដើម្បីឲ្យលោកច្បាស់ ថាតើលោកប្រើប្រាស់ពាក្យអ្វី? ខ្ញុំតាមដែលខ្ញុំយល់ គឺយើងស្ដាប់ឮទៅ គេថាលោកនិយាយថា លោកធ្វើគ្រាប់បែក។ ដូច្នេះ ខ្ញុំចង់ឲ្យលោកបញ្ជាក់ស្ដាប់ឡើងវិញ ហើយបញ្ជាក់ថាលោកនិយាយថាម៉េច?

**ប្រធានអង្គជំនុំ៖**

ផ្នែកខាតសោតទស្សន៍ ចាក់ផ្សាយសាជាថ្មីម្ដងទៀត ផ្នែកខាងផ្នែកខ្សែអាត់សំឡេងចុងក្រោយអម្បាញ់មិញនេះ។

[០៩:៥៨:១៨]

*(ការបង្ហាញឯកសារជាសំឡេង)*

“សម័យនុ៎ង ខ្ញុំធ្វើគ្រាប់បែក។ អ៊ីចឹងគឺចេះតែប៉ុណ្ណឹង ក្នុងចន្លោះហ្នឹង សម្រាប់ពួកខ្ញុំមួយក្រុម”។

*(បញ្ចប់ការបង្ហាញឯកសារជាសំឡេង)*

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** តើលោកស្ដាប់ឮទេថា លោកនិយាយថា លោកធ្វើអ្វីដែរទេ នៅក្នុងខ្សែអាត់នេះ?

**លោក ជាល ជឿន៖**

**ឆ៖** បាទ ខ្ញុំធ្វើផ្លូវដែក។

**ស៖** តើលោកធ្លាប់ធ្វើឧបករណ៍ភ្លោង ឬក៏ធ្លាប់ចូលរួមពាក់ព័ន្ធនឹងការធ្វើឧបករណ៍ភ្លោង ឬក៏សម្ភារៈភ្លោងអីដែរឬទេ?

**ឆ៖** អត់ ខ្ញុំអត់ចេះធ្វើ។

**ស៖** មិនអីទេ ខ្ញុំនឹងបន្តទៅមុខទៀតចុះ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

សុំទោស។ ថាតើគ្រាប់បែក ពាក្យគ្រាប់បែក គេបកប្រែត្រឹមត្រូវដែរឬទេ?

**លោក នីកូឡាស គូមជែន៖**

<បាទ>

**ចៅក្រម ក្លូឌា ហ្វេនស័៖**

<តើស្នួរនោះបានប្រយោជន៍អី?>

**សួរដោយលោក នីកូឡាស គូមជែន៖**

<>ខ្ញុំមិនចេះភាសាខ្មែរទេ ប៉ុន្តែតាមដែលខ្ញុំដឹង គឺថា<ពាក្យនោះមានសំឡេងដូចពាក្យសម្រាប់> ឧបករណ៍ភ្លេង <ខ្សែឧបករណ៍>ភ្លេង។ <ហើយខ្ញុំអាចសួរសាក្សីឱ្យបានត្រឹមត្រូវ។>

**ស៖** តើលោកធ្លាប់ធ្វើឧបករណ៍ភ្លេងជារបៀបខ្សែដែរឬទេ? ខ្ញុំគិតថាគួរតែទុកឱកាសឱ្យសហការីរបស់ខ្ញុំគាត់និយាយភាសាខ្មែរវិញ ទើបវាមានន័យស្តាប់យល់ទាំងអស់គ្នា។

[១០:០០:១១]

**កញ្ញា សុង ឆវ័ន្ត៖**

លោកសាក្សី នៅក្នុងខ្សែអាត់សំឡេងដែលអ្នកស៊ើបអង្កេតបានសម្ភាសលោកហ្នឹង គឺខាងក្រុមការងាររបស់ការិយាល័យសហព្រះរាជអាជ្ញាព្យាយាមស្តាប់ខ្សែអាត់នេះជាច្រើនដង ហើយនៅក្នុងខ្សែអាត់ដែលបានចាក់ឱ្យលោកស្តាប់មុននេះហ្នឹង គឺខាងក្រុមការងារយើងស្តាប់ឮថា ក្រុមរបស់លោកហ្នឹងគឺធ្វើគ្រាប់បែក មិនមែនផ្លូវដែកទេ ហើយយើងចង់ផ្ទៀងផ្ទាត់នូវសំឡេងដែលលោកបានឆ្លើយជាមួយនឹងអ្នកស៊ើបអង្កេតដើម្បីឱ្យច្បាស់ទាំងអស់គ្នានៅក្នុងសវនាការនេះ ថាក្រុមរបស់លោកហ្នឹងធ្វើផ្លូវដែក ឬក៏ធ្វើគ្រាប់បែកពេលនោះ?

**លោក ជាល ជឿន៖**

**ឆ៖** អាក្រុមរបស់ខ្ញុំហ្នឹងធ្វើផ្លូវដែក។

**ចៅក្រម ក្លូឌា ហ្វេនស័៖**

សូមទោស តើលោកបានស្តាប់សំឡេងរបស់លោកផ្ទាល់នៅក្នុងខ្សែអាត់ដែរឬទេ? <តើនេះជាសំឡេងលោកនិយាយឬ?> ថាតើលោកបានប្រើប្រាស់ពាក្យដូចដែលលោកឆ្លើយប្រាប់យើងហ្នឹងមែនទេ?

**លោក ជាល ជឿន៖**

ខ្ញុំឆ្លើយ ខ្ញុំធ្វើផ្លូវដែក។

**ប្រធានអង្គជំនុំ៖**

អញ្ជើញទៅមុខទៀត តទៅមុខទៀត!

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:០១:៥៩]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើលោករៀបការនៅក្នុងរបបខ្មែរក្រហមនោះមែនទេ?

**លោក ជាល ជឿន៖**

**ឆ៖** បាទ។

**ស៖** តើនៅពេលហ្នឹង លោកចង់រៀបការទេ?

**ឆ៖** កាលពីពេលហ្នឹង ខ្ញុំអត់ចង់រៀបការទេ ព្រោះខ្ញុំរស់ម្នាក់ឯងស្រួល បើសិនជាមានប្រពន្ធ វាមានគ្នាដល់ពីរ វាអត់ស្រួល អ៊ីចឹងខ្ញុំអត់ទាន់ចង់រៀបការទេពេលហ្នឹង។

**ស៖** តើលោកចង់ទៅបួសវិញទេ បើសិនបើលោកអាចត្រឡប់ទៅបួសវិញ តើលោកមានបំណងចង់ទៅបួសជាព្រះសង្ឃឡើងវិញទេ?

**ឆ៖** បាទ ចង់។

[១០:០២:៥៥]

**ស៖** ដូច្នេះ តើលោកអាចប្រាប់បានទេថា ហេតុអ្វីបានជាលោករៀបការនៅក្នុងរបបនោះ?

**ឆ៖** ពេលហ្នឹងឈ្មោះ ភាព ដែលគាត់គ្រប់គ្រងខ្ញុំនៅក្នុងកន្លែងកម្មករហ្នឹង គាត់ប្រាប់ថាអង្គការកំណត់ ហើយខ្ញុំថាខ្ញុំអត់ទាន់ចង់បានប្រពន្ធទេបង នៅម្នាក់ឯងស្រួល បើសិនជាមានប្រពន្ធទៅ ខ្ញុំខ្លាចពិបាក ដល់អ៊ីចឹងគាត់ថាមិត្តឯងប្រកែកមិនបានទេ ព្រោះពេលនេះ អង្គការកំណត់ហើយ ដល់អ៊ីចឹងខ្ញុំក៏នៅស្ងៀមទៅ។

**ស៖** តើៗលោកអាចពន្យល់បានទេថាមានអ្វីកើតឡើងនៅពេលនោះ ប្រសិនបើ -- ហេតុអីក៏លោកមិនបដិសេធ ឬក៏លោកមិនហ៊ាននិយាយថាលោកមិនចង់រៀបការទេ?

**ឆ៖** ខ្ញុំអត់ហ៊ាននិយាយ ព្រោះឮសូរថាពាក្យអង្គការកំណត់មួយម៉ាត់គឺខ្ញុំខ្លាច បើសិនជាខ្ញុំមិនទទួល ខ្ញុំខ្លាចងាប់ អ៊ីចឹងខ្ញុំនៅស្ងៀមទៅ។ ដល់ពេលក្រោយមក ក៏គេរៀបការឲ្យទៅ។

**ស៖** លោកនិយាយអំពីមនុស្សបាត់ខ្លួននៅក្នុងរបបនោះ តើលោកអាចប្រាប់បានទេ ថាតើបាត់ខ្លួនហ្នឹង បាត់ខ្លួននៅពេលណា? ថាតើលោកអាចពន្យល់បានទេ អំពីការបាត់ខ្លួនរបស់មនុស្សនេះ?

[១០:០៤:៥២]

**ឆ៖** បាទ ពេលបាត់ខ្លួនរបស់មនុស្សហ្នឹង បើខ្ញុំដឹងច្បាស់ ដូចជាឈ្មោះ ភាព ហ្នឹង គេអត់មាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ហៅទៅរៀន ទៅអីទេតែដល់ពេលវេលាដែលយើងមកពីធ្វើការល្ងើយដេកលក់គ្រប់គ្នាទៅ ព្រឹកឡើងស្រាប់តែឮក្រុមគ្រួសារគាត់ថា ហ៊ឺ! យប់មិញ គេចាប់ប្តីគាត់ទៅបាត់ហើយ។ គ្រាន់តែឮតែប៉ុណ្ណឹង។

**ស៖** តើលោកធ្លាប់ឮ -- តើធ្លាប់ឃើញមេដឹកនាំខ្មែរក្រហមពីភ្នំពេញទៅទស្សនកិច្ចនៅតំបន់ដែលលោករស់នៅទេ?

**ឆ៖** អត់ ខ្ញុំអត់ដែលឃើញ។ ព្រោះកាលពីសម័យហ្នឹង ឲ្យតែឮពាក្យដែលគេថា រថភ្លើងពិសេស គឺគេអត់ឲ្យយើងទៅជិតថ្នល់រថភ្លើងទេ។ ឲ្យតែគេនិយាយប្រាប់ថា ថ្ងៃហ្នឹងរថភ្លើងពិសេស វត់មក អ៊ីចឹងគេអត់ឲ្យយើងទៅធ្វើផ្លូវទេ គេសុខចិត្តឲ្យទៅជួយដកស្នៅស្រូវ ឬក៏ទៅជួយធ្វើស្មៅចម្ការអីគេអ៊ីចឹងមួយថ្ងៃទៅ។

**ស៖** តើមានសន្តិសុខពិសេសអីដែរឬទេ នៅ<ផ្លូវ>រថភ្លើងនៅពេលនោះ?

[១០:០៦:៣០]

**ឆ៖** បាទ ពេលនោះ ខ្ញុំអត់បានដឹងថា មានឬអត់ដែរ ព្រោះពេលអ៊ីចឹងតែព្រលឹមឡើង គេឲ្យចេញពីផ្ទះទៅ បើថាគេឲ្យទៅដកស្នៅស្រូវនៅតាមវាលស្រែ ដឹងតែទៅគេនាំទៅឲ្យដកស្នៅហ្នឹងទៅ។ បើគេនាំឲ្យទៅធ្វើស្មៅចម្ការហ្នឹង គឺព្រលឹមងងឹតៗឡើងចេញទៅធ្វើស្មៅចម្ការអស់ទៅផុតពីផ្លូវរទេះភ្លើងទៅ ផុតពីវ៉ា ផុតពីអីទៅ។ ដល់អ៊ីចឹង ខ្ញុំអត់បានឃើញមានស្អីជាស្អីនៅកន្លែងហ្នឹងទេ អត់ដឹងអីទាំងអស់។

**ស៖** តើលោកធ្លាប់ឮឈ្មោះ នួន ជា ទេក្នុងរបបនោះ?

**ឆ៖** កាលពីនៅក្នុងរបបហ្នឹង ខ្ញុំអត់ដែលឮឈ្មោះដែរ ខ្ញុំឮត្រឹមវៀតណាមចូល ព្រោះកាលនោះអ្នកគ្រប់គ្រងប្រទេស ខ្ញុំអត់មានឮឈ្មោះអ្នកណា ហើយខ្ញុំអត់ដែលស្គាល់អ្នកណាម្នាក់ទៀត។ បើនិយាយរួមឲ្យខ្លីទៅខ្ញុំស្គាល់តែគ្នាខ្ញុំ នៅក្នុងកម្មកររទេះភ្លើងប៉ុន្មាននាក់ហ្នឹង ព្រោះគេមិនដែលប្រកាសឲ្យយើងដឹង យើងឮ អ្នកណាធ្វើអីៗ អត់។

**ស៖** តើលោកធ្លាប់ឮឈ្មោះ ខៀវ សំផន ទេ?

**ឆ៖** បាទ ខៀវ សំផន ហ្នឹងខ្ញុំធ្លាប់ឮឈ្មោះកាលពីខ្ញុំនៅរៀន នៅឆ្នាំ៦៨, ៦៩ ហ្នឹងខ្ញុំធ្លាប់ឮឈ្មោះ តែឃើញអត់ដែលឃើញដែរ។

**ស៖** តើលោកធ្លាប់ចូលរួមវគ្គអប់រំនយោបាយដែរឬទេ ហើយប្រសិនបើធ្លាប់ចូល តើ<ញឹកញាប់>ដែរ< ឬទេ>?

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:០៨:៥២]

**ឆ៖** ខ្ញុំគ្រាន់តែជាកម្មករតូចមួយអ៊ីចឹង កំប៊ិកកំប៉ុកអ៊ីចឹងៗ សូម្បីតែគេប្រជុំត្រឹមថ្នាក់មេក្រុម ក៏គេអត់ឲ្យដូចខ្ញុំអីទៅជិតបៀត ហើយទៅឮថាគេប្រជុំពីស្អីដែរអត់។ ហើយក៏ចូលរៀននយោបាយអី គឺអត់ដែរ និយាយរួមគឺអត់ដែលទាំងអស់បណ្ដោយ ដឹងថា គេអ្នកគ្រប់គ្រងគេទៅ គេថា គេទៅរៀន បើសិនជាគេត្រឡប់មកវិញ គេដឹង គេឲ្យយើងធ្វើស្អីចេះតែធ្វើតាមតែគេអ៊ីចឹង។ គេឲ្យធ្វើផ្លូវ ធ្វើផ្លូវ។ បើគេប្រាប់ថា ថ្ងៃនេះមិត្តឯងដកកម្លាំងមិត្តឯងប្រាំនាក់ទៅធ្វើស្ពាន អាហ្នឹងដឹងតែទៅប្រាំនាក់ទៅធ្វើស្ពានអ៊ីចឹងទៅ។ អត់មានដឹងអីទៀត។

**ស៖** អ៊ីចឹងលោកអត់ចាំថាលោកធ្លាប់ចូលរួមវគ្គនយោបាយ ឬក៏ការអប់រំណាមួយដែលនិយាយអំពីខ្មាំងទេ មែនទេ?

[១០:០៩:៥៩]

**ឆ៖** បាទ អត់។

**ស៖** ខ្ញុំគិតថាឥឡូវនេះដល់ពេលឈប់សម្រាកហើយ លោកប្រធាន តើយើងគួរបន្តឬក៏យ៉ាងម៉េច? សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

ម៉េចដែរ ក្រុមសហមេធាវីនាំមុខមានសំណួរសួរសាក្សីរូបនេះដែរឬទេ?

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ យើងខ្ញុំអត់មានសំណួរទេ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់ផ្ដល់កន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងដប់កន្លះ។

បាទ សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១០:១១ នាទី ដល់ម៉ោង ១០:៣៣ នាទី)*

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:៣២:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះសម្រេចផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី ដើម្បីឲ្យមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។ ដំបូងនេះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី លោក នួន ជា។ ហើយអង្គជំនុំជម្រះក៏សូមរំឭកបញ្ជាក់បន្ថែមដែរ ព្រឹកមិញបញ្ជាក់មិនអស់គឺអង្គជំនុំជម្រះសូមជម្រាបថា បើសិនបើភាគីយកឯកសារ E3/10638 -- 688 និង E3/14 -- 684 មកសួរដេញដោលសាក្សី--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំអំមិញអត់ទទួលបានការបកប្រែ<ជាភាសាអង់គ្លេសទេ> លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ ហើយអង្គជំនុំជម្រះប្រកាសបើកបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយសវនាការតទៅនេះអង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សីរូបនេះ។ ហើយដំបូងនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី លោក នួន ជា ហើយអង្គជំនុំជម្រះសូមរំឭកបញ្ជាក់បន្ថែមថា កាលពីព្រឹកមិញបញ្ជាក់អំពីការប្រើប្រាស់រហស្សនាមចំពោះសាក្សី 2-TCW-1066 ក្នុងករណីភាគីដកស្រង់នូវកំណត់ហេតុស្តាប់សក្ខីកម្មរបស់សាក្សីរូបនេះមកសួរដេញដោលសាក្សីរូបនេះ។ ដោយបញ្ជាក់បន្ថែមទៀតថា ប្រសិនបើប្រើប្រាស់ឯកសារ E10683 និង E10684 បើសួរជាមូលដ្ឋានក្នុងការសួរដេញដោលសាក្សីរូបនេះ សូមប្រាប់មកអង្គជំនុំជម្រះ ដោយអង្គជំនុំជម្រះនិងធ្វើសវនាការជាអសាធារណៈ បើសិនបើត្រូវការដកស្រង់នៅផ្នែកពាក់ព័ន្ធនៅក្នុងកំណត់ហេតុនោះមកជាមូលដ្ឋានសួរដេញដោលសាក្សីរូបនេះ។

បាទសូមអញ្ជើញលោកមេធាវីការពារក្តី លោក នួន ជា។

[១០:៣៥:២៩]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ជាក់ស្តែងទៅ--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដឹកាបង្គាប់ គឺវាហាក់ដូចជាមិនច្បាស់លាស់។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ខ្ញុំស្តាប់បានច្បាស់ហើយលោកស្រីចៅក្រម។ យើងៗប្រើឈ្មោះសាក្សី ដោយប្រើរហស្សនាមតែប៉ុណ្ណោះ។ នៅពេលដែលខ្ញុំតទល់ជាមួយនឹងសាក្សីរូបនេះ ហើយយើងនឹងធ្វើជាអសាធារណៈ។ ដូច្នេះ ហើយខ្ញុំនឹងទុកសំណួរដែលពាក់ព័ន្ធនឹងសាក្សីដែលថាយកមកតទល់ជាមួយនឹងសាក្សីរូបនេះនៅចុងបញ្ចប់។ ហើយចំណុចសម្គាល់មួយដែលខ្ញុំសូមលើកឡើង គឺសំណួរដែលខ្ញុំសួរទៅកាន់សាក្សី និងអត្ថបទដកស្រង់ ហើយខ្ញុំនឹងយកមកតទល់ជាមួយនឹងសាក្សីរូបនេះ ប្រហែលជាអាចពាក់ព័ន្ធទៅនឹងតុលាការកំពូល។ ដូច្នេះប្រសិនបើយើងធ្វើសវនាការជាអសាធារណៈ អ្នកទាំងឡាយដែលគាត់ចូលរួមក្នុងនាមអង្គជំនុំជម្រះតុលាការកំពូល និងមិនទទួលបានចម្លើយសក្ខីកម្មនោះទេ។ ហើយខ្ញុំមិនដឹងថាតើចម្លើយដែលឆ្លើយពីសាក្សីរូបនេះ នឹងពាក់ព័ន្ធនឹងតុលាការកំពូលឬក៏យ៉ាងណានោះទេ។ ខ្ញុំដែលគ្រាន់តែចង់បញ្ជាក់ចំណុចនេះឲ្យបានច្បាស់លាស់។

[១០:៣៦:៥៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកទុកទៅសួរដល់ចុង ទុកសំណួរនេះសួរនៅចុងក្រោយទៅ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីខ្ញុំមិនមានសំណួរច្រើនចំពោះលោកនោះទេ គ្រាន់តែសួរសំណួរមួយចំនួនបន្តពីសំណួរដែលភាគីដំបូងបានសួរ។ នៅពេលនេះខ្ញុំសូមសួរទៅកាន់លោកសាក្សី តើលោកអាចចេះសរសេរនិងអានដែរឬទេ?

**លោក ជាល ជឿន៖**

**ឆ៖** ខ្ញុំចេះសរសេរខ្លះ ប៉ុន្តែមិនជាច្បាស់លាស់ទេ និងអានក៏អានដាច់ខ្លះ មិនដាច់ខ្លះ។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញអត្ថបទដកស្រង់មួយជូនសាក្សី ចេញពីឯកសារE3/1170, អង់គ្លេស ERN គឺ 00602544 ហើយនិងទំព័របន្ទាប់ ខ្មែរគឺ 00443016 ដល់ 17, បារាំងគឺមានលេខ

06544895។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សីខ្ញុំបង្ហាញនូវដ្យាក្រាម ឬក៏តារាងមួយដែលហៅថា កងទ័ពព្រៃសាន ហៅខុសដាក់ឈ្មោះខុសនោះទេ តាមពិតទៅកងទ័ពខាងពាយ័ព្យតែប៉ុណ្ណោះ។ អ្វីដែលខ្ញុំចង់បង្ហាញនេះមិនពាក់ព័ន្ធតែឈ្មោះលើកឡើងនៅក្នុងហ្នឹងនោះទេ ក៏ប៉ុន្តែនៅក្នុងឯកសារនេះគឺមានដាក់ឈ្មោះខេត្តរួមទាំងភូមិ<នៅភូមិភាគពាយ័ព្យ ដូចជា>ខេត្តប៉ៃលិន <ក្រែង ជាដើម។ ដូច្នេះ>អ្នកដែលរៀបចំឯកសារដ្យាក្រាមនេះ គឺមានកំហុស ដាក់ថាកងទ័ពព្រៃសាន តាមពិតទៅមិនមែនទេ គឺកងទ័ពពាយ័ព្យទេ លោកប្រធាន។

[១០:៣៩:៥៩]

លោកសាក្សី សូមលោកមើលឯកសារនេះ ហើយខ្ញុំសូមណែនាំលោកបន្តិចពាក់ព័ន្ធនឹងឯកសារនេះ។ ឯកសារនេះគឺលើកឡើងសរសេរថា កងពលធំ១ និងកងពលធំលេខ២។ នៅពេលនេះ ខ្ញុំសូមចាប់ផ្តើមឈ្មោះ ដែលលោកមើលឃើញនៅក្នុងឯកសារនេះ នៅក្រោមកងពលធំលេខ២។ ខ្ញុំសូមអានឈ្មោះជាភាសាអង់គ្លេស ដាក់ថាទី១ គឺក្លែង, <> ទី២ គឺ <ខូយ> ហើយនិងទី៣ <រ៉េន>។ សំណួរដែលខ្ញុំចង់សួរលោកគឺដូចតទៅ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក៥៨ ចម្លើយសំណួរលេខ៥៨ លោកបានលើកឡើងហៅដាក់ឈ្មោះថា <សារឿន> ឬក៏ <រ៉េន> មេបញ្ជាការ <រ៉េន>។ តាមពិតទៅឈ្មោះនៅក្នុងឯកសារ <រ៉េន> នេះ <>លោកចង់សំដៅលើបុគ្គលហ្នឹងមែនដែរឬទេ? <សារឿន> ហ្នឹងហៅ <រ៉េន>ហ្នឹង តើជាបុគ្គលហ្នឹងដែលមាននៅក្នុងឯកសារហ្នឹងមែនដែរឬទេ?

**ឆ៖** ខ្ញុំអត់--

**អ្នកបកប្រែ៖**

សូមកែតម្រូវឈ្មោះលោកសាក្សី សារឿន ហៅ រ៉េន។

[១០:៤១:៣២]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមសួរលោកសាក្សីបញ្ជាក់សិន។ លោកសាក្សី តើលោកអាចយល់ មើលយល់ទេ ដ្យាក្រាមហ្នឹង។ លោកថាលោកចេះអានខ្លះ អ៊ីចឹងពេលដែលលោកមើលឯកសារនៅចំពោះមុខលោកនេះ តើ

01385936



លោកមើលដាច់ទេ មើលយល់ទេ ឬក៏លោកអត់យល់ទេ?

**លោក ជាល ជឿន៖**

មើលអានេះ សារឿន ហៅ រ៉េន។ គ្រាន់តែឃើញឈ្មោះហ្នឹង។ ខ្ញុំឈ្មោះនេះ ខ្ញុំឃើញ ប៉ុន្តែខ្ញុំអត់--

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** បាទ ខ្ញុំយល់ វាពិបាកបន្តិច។ នៅពេលនេះ យើងខ្ញុំសួរមួយវគ្គៗម្តង។ នៅក្នុងកំណត់ហេតុរបស់លោក គឺ<E3/10681 នៅក្នុងសំណួរចម្លើយ៥៨> លោកបានលើកឡើង<អំពី>មេបញ្ជាការកងពលធំ ហើយលោកនៅក្នុងហ្នឹង គឺលោកហៅឈ្មោះ សារឿន លោកលើកឡើងឈ្មោះ សារឿន ហៅ រ៉េន។ នៅពេលនេះ លោកសូមមើលឯកសារដែលខ្ញុំផ្តល់លោកអម្បាញ់មិញនេះ នៅក្នុងកងពលក្រោមកងពលធំលេខ២ហ្នឹង មានឈ្មោះ រ៉េន នៅក្នុងហ្នឹងដែរ។ បាទ នៅក្នុងឯកសារ នៅក្នុងដែររបស់លោកហ្នឹង គឺទី១ ក្តែង <ជាលេខាកងពលធំលេខ២>, ទី២ គឺ <ខូយ> អនុលេខា ហើយនិងទី៣ គឺ រ៉េន ដែលជាសមាជិកកងពលធំលេខ២។ <តើគាត់ជាមនុស្សដែលលោកនិយាយនោះ ឬឈ្មោះ> រ៉េន <>គឺបុគ្គលដែលលោកលើកឡើងនៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក<ថា>ជាមេកង មេបញ្ជាការកងវរសេនាធំ<៧0> <នៅខាងក្រោម> ឬក៏<មាន រ៉េន>ក្រោម<នោះបន្តិច មានមូលដ្ឋាន> នៅប៉ៃលិន? អ៊ីចឹងខ្ញុំសូមសួរលោក នៅពេលដែលលោក<និយាយអំពីមេបញ្ជាការរបស់លោក>ឈ្មោះ សារឿន ហៅ រ៉េន តើ<លោកឃើញ>ឈ្មោះនៅក្នុងជ្យាក្រោម ដែល<ខ្ញុំបានបង្ហាញលោក>ដែរឬទេ?

[១០:៤៤:១៨]

**លោក ជាល ជឿន៖**

**ឆ៖** ត្រូវ។

**ស៖** សារឿន ហៅ រ៉េន គឺជាសមាជិកនៅក្នុងកងពលលេខ២ មែនដែរឬទេ? ស្ថិតនៅក្នុងក្រុមជួរដឹកនាំកងពលធំលេខ២ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទត្រង់ហ្នឹង ខ្ញុំអត់ដឹងថាគាត់នៅកងពលលេខប៉ុន្មាន អីលេខប៉ុន្មានទេ ព្រោះខ្ញុំបានដឹងតែពេលដែលព្រឹត្តិការណ៍ដែលឈ្មោះ រ៉េន ហ្នឹង ប្រព្រឹត្តទៅហ្នឹង ខ្ញុំដឹងបានតែប៉ុណ្ណឹងទេ។ ហួសពីហ្នឹងទៅទៀត ខ្ញុំអត់ដឹងគាត់ថា កងពលលេខប៉ុន្មាន ហើយគាត់ទៅនៅឯណា អីណា អត់ដែលជួបដែលអីទាំងអស់។

**ស៖** តើលោកដឹងទេ តើថាកងពលហ្នឹង ដាក់ឈ្មោះថា កងពលធំលេខ២ហ្នឹង គេដាក់ឈ្មោះឲ្យ

នៅពេលណាដែរ?

**ឆ៖** ត្រង់ហ្នឹង ក៏ខ្ញុំអត់ដឹង។ អត់ដឹងគេដាក់ពីពេលណាមកដែរ អត់ដឹងទាំងអស់។

**ស៖** សូមអរគុណលោកសាក្សី។ នៅលើទំព័រ ទំព័រដដែល នៅខាងឆ្វេង សូមលោកមើលខាងឆ្វេង មានឈ្មោះដែលជាអ្នកនៅក្រោមកងពលលេខ១ នង <សារឹម> ហៅ <សាន> ជាលេខាកងពលលេខ១, នៅ អនុលេខា ហើយនិង<លេខ៣> ឈន សមាជិក។ តើលោកឃើញឈ្មោះទាំងបីហ្នឹងដែរឬទេ?

[១០:៤៦:៤២]

**ឆ៖** បាទ ឈ្មោះនេះ នៅក្នុងក្រដាសនេះ ខ្ញុំឃើញ។ ប៉ុន្តែដល់គាត់នៅក្នុងកងពលណាអីណាហើយ ប៉ុន្តែនិយាយទៅ ពេលហ្នឹង ខ្ញុំអត់ដែលស្គាល់គាត់ផង។ គ្រាន់តែបានឃើញក្នុងក្រដាសនេះ នេះដល់ពេលពីមុនមក ខ្ញុំអត់ដែលស្គាល់។

**ស៖** ដើម្បីឲ្យខ្ញុំយល់ច្បាស់បន្តិច ខ្ញុំចង់ឲ្យលោកមើល គឺឈ្មោះទី៣ ឈន ហៅ <ឈុន>។ តើបុគ្គលហ្នឹង លោកអត់ដែលស្គាល់ទេ តាំងពីមុនហ្នឹង ហើយក្រោយមក<ក៏លោកមិនស្គាល់ដែរ តើត្រឹមត្រូវទេ?>

**លោក នីកូឡាស គូមជែន៖**

តើខ្ញុំឮ ឈន ហើយបន្ទាប់មក ហៅឈ្មោះមួយទៀត។ តើឈ្មោះ<ហៅក្រៅ>ហ្នឹង គាត់យកមកពីណា? <គាត់និយាយថា ឈន ហៅ ឈុន។ ខ្ញុំមិនឃើញវានៅក្នុងឯកសារទេ។>

**លោក វ៉ិចទ័រ កូប៉េ៖**

<ត្រឹមត្រូវហើយ វាមិនមាននៅក្នុងឯកសារទេ។> ឈ្មោះហ្នឹង<>ខ្ញុំយកមកពីបញ្ជីរបស់ចៅក្រមស៊ើបអង្កេត ហើយ<បើ>ខ្ញុំ<ត្រូវ>ដក<ផ្នែកនោះ>ចេញទៅ ក៏បានដែរ បើសិនជាអ៊ីចឹង។ នៅក្នុងបញ្ជីចៅក្រមអង្កេតហ្នឹង គឺលេខ<៦៣៣៦ ឈ្មោះគាត់> អ៊ុក <ឈឿង> ហៅ ឈន <មេបញ្ជាការកងពលទី១>។ បាទ អ៊ីចឹង គឺខ្ញុំយកឈ្មោះហ្នឹង ឈ្មោះហៅក្រៅហ្នឹង មកពីបញ្ជីចៅក្រមស៊ើបអង្កេត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី នៅក្នុង នៅក្រោមកងពលធំលេខ១ហ្នឹង មានឈ្មោះបុគ្គលទី៣ហ្នឹង ដាក់ឈ្មោះថា ឈន។ តើបុគ្គលហ្នឹង លោកមិនដែលស្គាល់តាំងពីមុនមក ហើយក៏ក្រោយមកក៏លោកអត់

ដែលស្គាល់ដែរ តើត្រឹមត្រូវដែរឬទេ?

[១០:៤៨:៣៣]

**លោក ជាល ជឿន៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** ខ្ញុំសូមសួរបន្តទៅមុខទៀត។

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ លោក វ៉ិចទ័រ កូប៉េ។ អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សោកស្ដាយដែលខ្ញុំកាត់ផ្ដាច់ ប៉ុន្តែដើម្បីប្រតិចារឹកសវនាការ។ អ៊ីចឹង លោកអាចបញ្ជាក់បានទេ អ្នកណាជាអ្នកធ្វើអង្គការលេខហ្នឹង? ហើយគេធ្វើឡើងនៅពេលណាដែរ? ហើយលោកបានឯកសារហ្នឹងមកពីណា?

[១០:៤៩:១៧]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនដឹងច្បាស់នោះទេ ប្រហែលជា<ឯកសារដើម>ចេញមកពីកម្មាភិបាល ស-២១ មួយរូប យើងបានពិភាក្សាគ្នាលើឯកសារហ្នឹង អង្គការលេខហ្នឹងរួមកហើយ។ ខ្ញុំជឿថា ប្រហែលជាយើងធ្លាប់ជជែកជាមួយនឹង ឌុច ប៉ុន្តែខ្ញុំមិនច្បាស់នោះទេ។ អង្គការលេខ ឯកសារនេះ ចេញមកពីកំណត់ -- ចេញមកពីសៀវភៅកំណត់ហេតុមួយ ក៏ប៉ុន្តែខ្ញុំអត់ដឹងច្បាស់<ថាអ្នកណាជាអ្នកនិពន្ធនោះទេ>។ បន្ថែមលើចំណុចហ្នឹង កំណត់ហេតុ សៀវភៅកំណត់ហេតុហ្នឹង <ប្រហែល>ជាសៀវភៅកំណត់ហេតុក្រោយឆ្នាំ៧៩។ បានន័យថា គេរៀបចំឡើងក្រោយឆ្នាំ៧៩ ដែលចំណុចនេះគឺមជ្ឈមណ្ឌលឯកសារកម្ពុជាបញ្ជាក់ថាអ៊ីចឹង។ <វាអាច>ឯកសារនេះ ចេញមកពីកម្មាភិបាលមួយ<រូប ឬអាច>មកពីមជ្ឈមណ្ឌលឯក-សារកម្ពុជា។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

បើសិនយើងអាចបញ្ជាក់ឲ្យបានច្បាស់ លោកមេធាវី។ នៅពេលដែលលោក<បើក>ឯកសារហ្នឹង គឺវាមានបញ្ជាក់ថា មជ្ឈមណ្ឌលឯកសារកម្ពុជា ហើយ<>ជា<ទស្សនាវដ្ដីខ្មៅ>របស់ខ្មែរក្រហម <>។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ជាៗជាទូទៅ គឺអ៊ីចឹងមែន។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ការពិពណ៌នានៅក្នុងហ្នឹង គឺយ៉ាងម៉េចដែរ?

[១០:៥១:០១]

**លោក វ៉ិចទ័រ កូប៉េ៖**

<ការពិពណ៌នានៅក្នុង>ឯកសារនេះ <គឺថាខ្ញុំមិនច្បាស់ថា តើវាគឺជាឯកសាររបស់> មជ្ឈ-មណ្ឌលឯកសារកម្ពុជា <ឬក៏ ពិតប្រាកដនោះ> វាជាឯកសាររបស់កម្មាភិបាលមួយរូប។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំនឹងសួរលោកអំពីបញ្ហាមួយដែលបានជជែកជាមួយនឹងលោក កាលពីថ្ងៃព្រហស្បតិ៍។ គេបានអានចំណុចដកស្រង់មួយចេញមកពីសៀវភៅរបស់លោក ថេត សម្បត្តិ និង ជីណា ចន ហើយចំណុចដកស្រង់ដែលបានអានជូនលោកនោះ គឺបានលើកឡើងថាសម្ដីហ្នឹង គឺចេញពីលោក។ ក៏ប៉ុន្តែដូចដែលខ្ញុំបានបញ្ជាក់ច្បាស់ហើយ កាលពីថ្ងៃ លើកកាលពីសវនាការលើកមុន រ៉ូប៊ីត លឹមគិន គឺបានលើកឡើងថា កំណាត់ចំណុចដកស្រង់ហ្នឹង មិនមែនចេញមកពីសម្ដីលោកនោះទេ។

**លោក នីកូឡាស គូមជែន៖**

សូមអធ្យាស្រ័យលោកប្រធាន ខ្ញុំជំទាស់។ មេធាវីកំពុងតែមកផ្ដល់សក្ខីកម្មដោយមិនត្រឹមត្រូវ។ <ខ្ញុំមិនដឹងថា>អ៊ីម៉ែលមកពីលោក លឹមគិន នោះ តើវាជាអ៊ីម៉ែលសម្ងាត់ ឬក៏យ៉ាងណានោះទេ។ <ប៉ុន្តែខ្ញុំមិនជំទាស់>នឹងអ៊ីម៉ែលនេះ<ទេ ដើម្បីកំណត់ត្រាប្រតិចារឹក។ ហើយមេធាវីគាត់>បកស្រាយ<អ៊ីម៉ែលនោះ ហើយខ្ញុំក៏មានដែរ។ ចំពោះខ្ញុំ វាហាក់ដូចជាច្បាស់ណាស់ថា លោក លឹមគិន បាននិយាយថា គេបានសន្យារក្សាការ>សម្ងាត់<ដល់អ្នកទាំងនោះ ហើយមិនគួរបញ្ចេញឈ្មោះពួកគេនោះទេ។ ប៉ុន្តែវាមិនបាននិយាយច្បាស់ -- ខ្ញុំភ្លេចពាក្យ>ដែលមេធាវីបាន<ប្រើនោះហើយ -- សាក្សីនេះមិនដែលនិយាយបែប>នោះទេ។ <នេះ មិនជាអ្វីដែលគាត់និយាយ>នៅក្នុងអ៊ីម៉ែល<>។

[១០:៥២:៥៤]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសន្មតថា អនុស្សរណៈរបស់លោក <ដោយស្វ័យប្រវត្តិ>គឺជាផ្នែកមួយ<នៃ>សំណុំរឿង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដូច្នេះហើយ ខ្ញុំអាចអាននៅក្នុងប្រតិចារឹកតែម្តងទៅ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំដឹងថាជាសំណុំរឿង ក៏ប៉ុន្តែ<សំណួរនោះ តើ>វាសម្ងាត់ ឬក៏ជាៗសាធារណៈ? <ពេលនេះខ្ញុំអត់មានអ៊ីម៉ែលនោះទេ ប៉ុន្តែលោកពិតជាមានវានៅចំពោះមុខលោក។>

**លោក វ៉ិចទ័រ កូប៉េ៖**

<ខ្ញុំមិនគិតថា>វា<>សម្ងាត់នោះ<>ទេ។ <វាមិនបានសរសេរបែបនោះឡើយ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ពីព្រោះថា>ឈ្មោះ<នោះគឺ -- សូមទោស>

**លោក វ៉ិចទ័រ កូប៉េ៖**

អនុស្សរណៈហ្នឹងជារបស់អង្គជំនុំជម្រះ អ៊ីចឹងអង្គជំនុំជម្រះអាចបញ្ជាក់ថាតើសម្ងាត់ ឬក៏យ៉ាងម៉េច ជាសាធារណៈ ឬសម្ងាត់។

[១០:៥៣:៥៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងពេលចំណុចហ្នឹង យើងនឹងពិនិត្យមើលនៅពេលបន្តិចទៀត ហើយលោកប្រើប្រាស់ឯកសារផ្សេងទៀតសិនទៅ ហើយនិងការសួរសំណួរផ្សេងទៀត សិនទៅ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ដូចដែលខ្ញុំបានលើកឡើងអ៊ីចឹង គេអានចំណុចដកស្រង់មួយចេញមកពីសៀវភៅ ថេត សម្បត្តិ ហើយចៅក្រមបានសួរថា៖ "តើលោកបាននិយាយទេសម្តីហ្នឹង?" ហើយលោកឆ្លើយនៅពេលនោះថា៖ "អត់ទេ ខ្ញុំអត់បាននិយាយទេ។" ហើយចំណុចដកស្រង់ហ្នឹង បានលើកឡើងឈ្មោះ <ចែលឈឿន> ជាមេបញ្ជាការកងពលធំ។ ខ្ញុំសូមថយក្រោយបន្តិច។ តើលោកមានវត្តមានទេ <នៅពេលដែលមនុស្សម្នាក់ដែលមានឈ្មោះ>នៅត្រង់<ទំព័រ១០៦ ក្នុងសៀវភៅរបស់ ថេត សម្បត្តិ> ERN 00757532, ខ្មែរ 00858342, បារាំង <00849437> <ត្រូវបានគេលើកមកនិយាយនោះ?> ហើយ<នៅក្នុងសៀវភៅនោះ>មានឈ្មោះថា ចាន់ សារុត ដែលជាប្រធានពេទ្យនៅតំបន់បាត់ដំបង។ លោកខ្លួនឯងលើកឡើងអំពីបុគ្គលឈ្មោះ ចាន់ សាមុត ត្រង់សំណួរចម្លើយ១៦៣ តើនៅពេលដែល លឹមគិន

ហើយនិង ថេត សម្បត្តិ សម្កាស <ចាន់ សារុត ឬ> ចាន់ សាមុត ហ្នឹង តើនៅពេលហ្នឹងលោកនៅកន្លែងហ្នឹងដែរឬទេ?

**លោក ជាល ជឿន៖**

**ឆ៖** ខ្ញុំអត់ដឹង។

[១០:៥៥:៥៥]

**ស៖** នៅពេលដែលអ្នកថតខ្សែភាពយន្តនោះសួរសំណួរទៅ ចាន់ សាមុត ឬ ចាន់ សារុត ហ្នឹង តើលោកមាននៅក្នុងបន្ទប់ជាមួយនឹងពួកគេដែរឬទេ?

**ឆ៖** អត់ ខ្ញុំអត់មាននៅជាមួយទេ។

**ស៖** ដូច្នេះខ្ញុំសួរលោកដែលលោកខ្លួនឯងនេះនិយាយអំពីឈ្មោះ ចាន់ សាមុត។ សំណួរចម្លើយត្រង់លេខ១៦៣ នៃឯកសារកំណត់ហេតុរបស់លោក "ចាន់ សាមុត រស់នៅភូមិរំលេច ឃុំរំលេច ស្រុកបាកាន ខេត្តពោធិ៍សាត់។ គាត់ហ្នឹងនៅជាមួយខ្ញុំហ្នឹង តែគេយកឪពុកម្ដាយគាត់ទៅសម្លាប់ចោល ព្រោះពេលនោះគាត់នៅបាត់ដំបង។ តើ ចាន់ សាមុត បាននិយាយអំពីរឿងរ៉ាវណាមួយដែល<បាន>កើតឡើងនៅស្រុក<>បាកានប្រាប់<>មុនពេលដែលគាត់ទៅបាត់ដំបងទេ? <លោកឆ្លើយថា៖ ទេ គាត់អត់បានប្រាប់ទេ។"> តើលោកនឹកឃើញទេ លោកធ្លាប់បានឆ្លើយអំពី ចាន់ សាមុត ហ្នឹងប្រាប់អ្នកស៊ើបអង្កេតរបស់តុលាការនេះ។ តើលោកនឹកឃើញទេ?

[១០:៥៧:២១]

**ឆ៖** បាទ ខ្ញុំនឹកឃើញ ចាន់ សាមុត ហ្នឹង។ ពេលដែលគេដកខ្ញុំទៅធ្វើកម្មកររទេះភ្លើងហ្នឹងហើយក៏ទៅជួប ចាន់ សាមុត នៅឯរ៉ាហ្នឹងដែរ អត់ដឹងថាគេទៅពីថ្ងៃប៉ុន្មាន ខែប៉ុន្មានក៏អត់ដឹងដែរ ស្រាប់តែជួបគ្នានៅនុ៎ង តែខ្ញុំគ្រាន់តែដឹងថា ចាន់ សាមុត ហ្នឹងអ្នករំលេច ហើយជាប់គុកពីសម័យសង្គ្រាម លន់ នល់ ដល់ពេលចប់សង្គ្រាម គាត់ចូលទៅជាកម្មកររទេះភ្លើង ហើយគាត់ជាកម្ពុជាក្រោមនៅរំលេច។ ដល់ពេលក្រោយមកទៀត គាត់ក៏មិនដែលមកស្រុកភូមិអីដូចតែខ្ញុំអ៊ីចឹងដែរ ហើយពេលកម្ពុជាក្រោមដែលគេបោសសម្អាតអស់ហ្នឹងក៏ខ្ញុំក៏អត់ដឹង គាត់ហ្នឹងក៏អត់ដឹង ទើសតែពេលយួនវិលត្រឡប់ -- យួនចូលរំដោះបានវិលត្រឡប់មកស្រុកទេសវិញបានដឹងថា ឪពុកម្ដាយគេយកទៅសម្លាប់អស់ ហ្នឹងបានដឹងតែប៉ុណ្ណឹងទេ។ ហើយ ចាន់ សាមុត ហ្នឹងគឺត្រឹមឆ្នាំ៧៥ ពេលគេដកខ្ញុំទៅធ្វើជាកម្មករហ្នឹងគឺបានទៅជួបគ្នាពេលនុ៎ងបណ្ដោយ ហើយធ្វើផ្លូវដែកជាមួយគ្នារហូត ទើសរៀតណាមចូល។

**ស៖** សូមអរគុណលោកសាក្សី។ ចំណុចនោះហើយដែលវាពាក់ព័ន្ធទាំងអស់ទៅនឹងបញ្ហា ចាន់ សាមុត នេះឯង។ តើនៅពេលណាមួយមាន ចាន់ សាមុត ហ្នឹងមានដែលធ្លាប់ប្រាប់លោកថា គាត់ធ្លាប់ទៅធ្វើជាប្រធានពេទ្យនៅតំបន់ខេត្តបាត់ដំបងដែរឬទេ?

[១០:៥៩:២៣]

**ឆ៖** បាទ អត់ទេ ចាន់ សាមុត ហ្នឹងគាត់អត់ដែលធ្វើជាពេទ្យធ្វើជាអីទេ ចាន់ សាមុត ដែលនៅជាមួយខ្ញុំហ្នឹងគឺគាត់នៅនឹងហ្នឹង ខ្ញុំដឹងថាគាត់កម្ពុជាក្រោមហើយ គាត់កេះខ្ញុំ ហើយធ្លាប់ប្រាប់ខ្ញុំថាមិនបាច់មាត់ប្រាប់គេថា គាត់កម្ពុជាក្រោមទេ អាហ្នឹងគាត់ធ្លាប់ប្រាប់អ៊ីចឹងមែន។ ហើយគាត់មិនដែលទទួលតួនាទីជាមេក្រុម ឬមេកង មេអីដូចខ្ញុំអ៊ីចឹងដែរ គឺជាកម្មករសុទ្ធសាធជារៀងរហូតមក ចាន់ សាមុត ហ្នឹង។

**ស៖** ដូច្នេះ ចាន់ សាមុត ដែលលោក<>ស្គាល់ហ្នឹង <មិន>ដែលប្រាប់លោកថាគាត់ជា<វេជ្ជ-បណ្ឌិត> ឬក៏ជា<ប្រធានពេទ្យយោធា> នៅបាត់ដំបង ឬក៏<>ថាគាត់ជាអ្នកដែលមានឋានន្តរក្រម<ខ្ពស់>នៅក្នុងខ្មែរដឹកនាំនៅក្នុងកងពលធំលេខ១នោះទេ តើមែនដែរឬទេ ត្រឹមត្រូវទេចំណុចហ្នឹង?

**ឆ៖** បាទ គាត់អត់ដែលជម្រាប ហើយបើតាមខ្ញុំធ្លាប់ស្គាល់គាត់ដែលគាត់នៅស្រុកភូមិជិតខ្ញុំហ្នឹង គឺគាត់អត់ដែលធ្វើអីមែន ពេទ្យក៏អត់ អីក៏អត់។ ដែលពេលគេបញ្ជូនទៅកម្មកររទេះភ្លើងហ្នឹង មិនដឹងជាគាត់រស់នៅឯណាទេ ស្រាប់ពេលឃើញគាត់ធ្វើកម្មករដែរ ហើយខ្ញុំទៅ ក៏នៅកម្មករក្នុងជួរជាមួយគាត់ហ្នឹងរហូតទៅ។

**ស៖** សូមអរគុណលោកសាក្សី។ ដើម្បីឲ្យខ្ញុំយល់ច្បាស់ត្រង់ចំណុចនេះ លោកបានលើកឡើងថា លោកអត់ដែលធ្លាប់នៅជាមួយនឹង លឹមគិន ហើយនិង ថេត សម្បត្តិ នៅពេលដែលពួកគាត់សម្លាស ចាន់ <សារុត > នោះទេ។ តើនៅពេលដែលលោកជួប<>ជាមួយនឹង លឹមគិន ហើយនិង ថេត សម្បត្តិ <តើពួកគេធ្លាប់និយាយអំពី ចាន់ សារុត ថាគាត់បានប្រាប់ពួកគេ>ថា រស់ ញឹម <បានបញ្ជាឲ្យឈឿន> ដែលជាមេកងពលធំលេខ១ ដែលមានឈ្មោះនៅក្នុងអង្គការលេខ ខ្ញុំបានសួរលោកអម្បាញ់មិញនោះ ឲ្យទៅទាក់ទងជាមួយនឹងជនកុម្មុយនីស្តថៃ ហើយចាប់ផ្តើមព្យាយាមសង្គ្រាមចិត្តសាស្ត្រ... ។ល។ នោះ តើអ្វីដែលខ្ញុំយល់នោះ ថេត សម្បត្តិ ហើយនិង លឹមគិន មិនដែលធ្លាប់បាននិយាយជាមួយនឹងលោកអំពីបញ្ហា ចាន់ សារុត <>អំពី<អ្វីដែល រស់ ញឹម បាន>ណែនាំទៅដល់<មេបញ្ជាការកងពលលេខ១របស់>គាត់<ឈ្មោះ ឈឿន នោះ>ទេ?

[១១:០២:៣៨]

**ឆ៖** បាទ អត់។

**ស៖** លោកប្រធាន ឥឡូវនេះ ខ្ញុំនឹងលើកយកអនុស្សរណៈរបស់អង្គជំនុំជម្រះ<ដែលបាន>ដកស្រង់ចេញពីសារអេឡិចត្រូនិករបស់ លីមគិន ហើយខ្ញុំ<ចង់ដឹង>ថាតើខ្ញុំអាច<ប្រើប្រាស់>បាន ឬក៏អត់?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ចាំមួយភ្លែត។> នេះជាឯកសារសម្ងាត់ ប៉ុន្តែ -- តើមានការជំទាស់<ពីសហព្រះរាជអាជ្ញា> ទេ ប្រសិនបើយើងចាត់ចំណាត់ថ្នាក់ឡើងវិញទៅជាឯកសារសាធារណៈ?

**លោក នីកូឡាស គូមជែន៖**

អត់មានការជំទាស់ទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ចុះសហមេធាវីនាំមុខ? អត់ទេ។ ចុះក្រុមមេធាវីការពារក្តី? អត់ទេ។> គ្មានទេៗមេធាវីការពារក្តីអត់ទេ ប្រាកដណាស់ គឺអត់មានទេ។

[១១:០៣:៣២]

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសម្រេចថាឯកសារនេះ គឺយើងចំណាត់ថ្នាក់ទៅជាឯកសារជាសាធារណៈវិញគឺE29/489/1នេះ ហើយភាគីអាចប្រើប្រាស់ឯកសារនេះជាសាធារណៈបានចាប់ពីពេលនេះតទៅ។

**លោក វ៉ិចទ័រ កូប៉េះ៖**

សូមអរគុណ លោកប្រធាន។ គឺថាមានការឆ្លើយ -- សួរឆ្លើយរួចទៅហើយ ប៉ុន្តែដើម្បីជាកំណត់ត្រាប្រតិចារឹក និងសម្រាប់សាធារណជន គឺអនុស្សរណៈថ្ងៃ២៧ ខែកញ្ញា ២០១៦ គឺនៅក្នុងកថាខណ្ឌ២ អង្គជំនុំជម្រះបានយោងទៅលើអ៊ីម៉ែលមួយ ដែលបានផ្ញើទៅអង្គភាពគាំពារសាក្សី និងអ្នកជំនាញ<នៅថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០១៦> ដែលផ្ញើដោយ រ៉ូប៊ីត លីមគិន។ ខ្ញុំសូមដកស្រង់ "សូមអរគុណ សម្រាប់ការផ្ញើអ៊ីម៉ែល សម្រាប់សំអាងហេតុដែលបានផ្តល់ជាច្រើនដងមក<>អង្គជំនុំជម្រះ<ពីមុនមក> គឺថាខ្ញុំមិនអាច<យល់ព្រមទៅនឹង>ស្នើសុំ<>បង្ហាញអត្តសញ្ញាណរបស់ W-4 ហើយក៏មិនអាច<ផ្តល់>នូវ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ខ្សែអាត់សំឡេងវីដេអូ។" <ហើយបន្ទាប់មកទៀតគេសរសេរថា> "ពាក់ព័ន្ធទៅនឹងសំណើលើកទី២របស់<លោក សំណើសុំថ្មីៗជាច្រើន>ទាក់ទងទៅនឹង <អ៊ុន ធឿន និង ចែល ឈឿន គឺត្រូវបានដាក់> ឈ្មោះមិនត្រឹមត្រូវនៅទំព័រ១០៤ និង១០៦។ នៅក្នុងសៀវភៅ "នៅពីក្រោយវាលពិឃាត" គឺជាសៀវភៅដែលខ្ញុំមិន<មានអ្វីត្រូវធ្វើនោះទេ។ ខ្ញុំមានការប្រុងប្រយ័ត្នក្នុងការនិយាយថា> W-1 នៅក្នុង<កំណត់សម្គាល់ខាងដើមរបស់ខ្ញុំ> គឺជាឈ្មោះ អ៊ុន ធឿន នៅទំព័រ១០៤ ដែលមិនមែនឈ្មោះពិត<របស់គាត់> ទេ ហើយខ្ញុំក៏មិន<មានសេរីភាពក្នុងការបញ្ចេញ>ឈ្មោះពិត<របស់គាត់>ដែរ។ <ប៉ុន្តែ>ខ្ញុំគិតថាខាងផ្នែកស៊ើបអង្កេត<បានទទួល>នូវតម្រុយជាច្រើន ហើយ<ខ្ញុំជឿថា>ពួកគេអាចនឹង<ធ្វើការស៊ើបអង្កេតដោយខ្លួនគេ>។" សូមបញ្ចប់ការដកស្រង់នេះ។

[១១:០៥:៥៦]

សម្រាប់ជាកំណត់ត្រាប្រតិចារឹកវិញ គឺថាប្រសិនបើយើងអាននូវការដកស្រង់ទាំងស្រុងនេះ គឺថាខាង<ការពារក្តី>យល់ឃើញថា <មិនអាចមានការយល់ច្រឡំថា ឈឿន> ដែល ចាន់ សារុត បាននិយាយយោងនេះ គឺមិនមែន ជឿន ដែលមកផ្តល់សក្ខីកម្មនៅពេលនេះទេ ប៉ុន្តែជា <ឈន> ដែលជាមេបញ្ជាការរបស់កងពលលេខ១ ដែលយើងអាចឃើញឈ្មោះ ដែលមិនត្រឹមតែនៅក្នុងបញ្ជីរបស់ ក.ស.ច.ស ប៉ុណ្ណោះទេ សូម្បីតែនៅក្នុងអង្គការលេខនេះក៏មានឈ្មោះនេះដែរ។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំគិតថាយើងមានពេលវេលាដើម្បីសួរដេញដោល <>នៅពេលចុងបញ្ចប់នៃសំណុំរឿង។<ប៉ុន្តែទ្រឹស្តីរបស់មេធាវីមិនបានគាំទ្រ>នោះទេ គឺថា បុគ្គលដែលគាត់និយាយអំពីបញ្ជី ក.ស.ច.ស គឺមានឈ្មោះថា <អ៊ុក ឈឿង>។ <>គឺឈ្មោះ ផ្សេងពីនេះទេ។ ដូច្នេះហើយ ខ្ញុំគិតថា គាត់មិនពេញចិត្តនឹងអ្វីដែលសាក្សីឆ្លើយ។ <ប៉ុន្តែអ្វីដែលយើងដឹងគឺថា> អ្វីដែល<បាន>និយាយ<នៅក្នុងសៀវភៅនោះ គឺ> សាក្សីរូបនេះ <ជាល ជឿន មិនបាន>និយាយ<នោះ>ទេ<>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំគិតថាវាមិនមែនជារឿងសំខាន់ណាស់ណាទេ ប៉ុន្តែសាធារណជនគួរតែដឹងថាបុគ្គលម្នាក់ដែលសម្ភាស<>ទាំង ចាន់ សារុត និងសាក្សីនេះ គឺច្បាស់ណាស់ថា ចាន់ សារុត មិនមែននិយាយអំពីសាក្សីរូបនេះ<ថា>ជាមេបញ្ជាការកងពលនោះឡើយ ប៉ុន្តែគឺគាត់និយាយអំពីមេបញ្ជាការ ពិតប្រាកដរបស់កងពលលេខ១។ យ៉ាងណាក៏ដោយ ខ្ញុំសូមបន្តទៅសំណួរបន្តរបស់ខ្ញុំទៀត លោកប្រធាន។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១១:០៧:៤០]

**ប្រធានអង្គជំនុំ៖**

រ៉ិចទ័រ កូប៉េ -- អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី លោកសំដៅទៅលើអ្នកណា នៅពេលដែលលោកនិយាយថា អ្នកដែលសម្ភាសសាក្សីនៅទីនេះ លោកសំដៅលើ ថេត សម្បត្តិ ឬក៏ រ៉ប លឹមគិន។

**លោក រ៉ិចទ័រ កូប៉េ៖**

គឺពួកគាត់ទាំងពីរនាក់ ធ្វើការជាមួយគ្នា។ <សាក្សីរូបនេះ -->

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

លោកមេធាវី កូប៉េ បើតាមខ្ញុំដឹង សម្រង់វីដេអូដែលបានចាក់ផ្សាយកាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុននោះ ពាក់ព័ន្ធនឹងកិច្ចប្រជុំដែលប្រព្រឹត្តទៅនៅប្រទេសថៃ ហើយយើងដឹងច្បាស់ទាំងអស់គ្នាហើយ សាក្សីបាននិយាយថា ពេលនោះគឺ រ៉ប លឹមគិន មិនមានវត្តមានទេ។ អ៊ីចឹង<ខ្ញុំមិនដឹងថាតើ>លោក<ទាញការសន្និដ្ឋាន>ថា រ៉ប លឹមគិន ហ្នឹងជាអ្នកសម្ភាសសាក្សីរូបនេះ<ដោយរបៀបណា>នោះ<ទេ។ តើលោកអាចបំភ្លឺបានទេ>?

[១១:០៨:៥០]

**លោក រ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនប្រាកដ១០០ភាគរយទេ លោកសាក្សី ថាតើលោកបាននិយាយយ៉ាងម៉េចទាក់ទងទៅនឹងកិច្ចសហការជាមួយ ថេត សម្បត្តិ ហើយនិង រ៉ប លឹមគិន នេះ។ ដូច្នេះ ខ្ញុំសួរលោកឲ្យច្បាស់តែម្តងទៅ។

**សួរដោយលោក រ៉ិចទ័រ កូប៉េ៖**

**ស៖** តើលោកអាចប្រាប់បានទេថា តើលោកធ្វើដំណើរជាមួយ ថេត សម្បត្តិ ហើយនិង រ៉ប លឹមគិន ប៉ុន្មានដងដែរ? ជារួមហ្នឹងប៉ុន្មានដងដែរ? ហើយតើលោក ខ្លួនលោកផ្ទាល់ធ្លាប់ត្រូវបានពួកគាត់សម្ភាសដែរឬទេ?

**ឆ៖** បាទ ខ្ញុំគាត់មិនដែលសម្ភាសខ្ញុំផង។ តែបើពេលទៅជាមួយ ថេត សម្បត្តិ ហ្នឹង អាហ្នឹងគ្រាន់តែទៅនៅថៃហ្នឹង អាហ្នឹងទៅជាមួយ ថេត សម្បត្តិ ហ្នឹងមែន។

**ស៖** <ដូច្នេះ>--

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក នីកូឡាស គូមជែន៖**

សូម<សូមទាញចំណាប់អារម្មណ៍>លោកប្រធាន <និងលោក កូប៉េ ពាក់ព័ន្ធទៅនឹងទ្រឹស្ដីរបស់គាត់ ដែលថា បុគ្គលដែល>ថេត សម្បត្តិ ហើយនិង រ៉ប លឹមគិន បានសម្គាស<ហើយនិងដកស្រង់> នៅទំព័រ១០៦ នៅក្នុងសៀវភៅ "នៅពីក្រោយវាលពីឃាត" នោះគឺ អ៊ុក <ឈឿង> លេខ<៦៣៣៦> នៅក្នុងបញ្ជី ក.ស.ច.ស <ហើយ>មេធាវីក៏អាចយោងទៅលើឯកសារ D108/26.86 នៅភាសាអង់គ្លេសមានលេខ 00873643, លេខ<១១០> នៅក្នុងបញ្ជីនេះ គឺអ្នក<ទោស>ដែលត្រូវគេសម្លាប់ថ្ងៃ ១៨ តុលា ៧៧ គឺ <អ៊ុក ឈឿង>។ ដូច្នេះខ្ញុំគិតថា ទ្រឹស្ដីរបស់មេធាវី<គឺ>ថា <គេបាន>សម្គាស បុគ្គលម្នាក់ដែលត្រូវបានគេសម្លាប់នៅស-២១។ <ខ្ញុំគិតថា ខ្សែភាពយន្តនោះគឺត្រូវបានផលិតឡើងយ៉ាងយូរក្រោយឆ្នាំ១៩៧៩>។

**លោក វ៉ិចទ័រ កូប៉េ៖**

<បើសិនជាលោកប្រុងប្រយ័ត្នបន្តិចចំពោះ>ជាអ្វីដែលខ្ញុំ<បាន>និយាយ<នោះ លោកព្រះរាជអាជ្ញា> ខ្ញុំក៏<ដឹង>ផងដែរថា លឹមគិន ហើយនិង ថេត សម្បត្តិ មិនអាចសម្គាសអ្នកដែលស្លាប់រួចហើយនោះទេ។ <ពួក>គេ<បាន>សម្គាស ចាន់ សារុត។ ចាន់ សារុត ជាប្រធានមន្ទីរពេទ្យនៅក្នុងតំបន់បាត់ដំបង ដែលយោងតាមសៀវភៅ។ ហើយវាជាការត្រឹមត្រូវ គឺបាននិយាយថា "រស់ ញឹម បញ្ជាដល់ <ចែល ឈឿន> ដែលជាមេបញ្ជាការកងពលឲ្យទាក់ទងជាមួយកុម្មុយនីស្ដថៃ។" ហើយក្នុងសៀវភៅហ្នឹង គឺថាតាមជំហររបស់យើង គឺថាវាមានភស្តុតាងដែលគួរឲ្យជឿជាក់បាន គឺមិនមែន ជឿន នេះទេ ប៉ុន្តែជាមេបញ្ជាការ <ឈឿន> – ជាមេបញ្ជាការ <ឈឿន> ដែលខ្ញុំទើបតែនិយាយរួចមកហើយ ព្រោះគាត់បានស្លាប់រួចទៅហើយ គឺមាននៅក្នុងបញ្ជី ក.ស.ច.ស។ ដូច្នេះប្រាកដណាស់ថា ថេត សម្បត្តិ ហើយនិង រ៉ប លឹមគិន មិនអាចទៅសម្គាស <ឈឿន> ដែលជាមេបញ្ជាការកងពល<លេខ> មួយនោះទេ។ ប៉ុន្តែគេសម្គាស ចាន់ សារុត ដែល ចាន់ សារុត ហ្នឹងគាត់និយាយយោងទៅដល់ <ឈឿ ន>។ យើងដឹងហើយថា ថេត សម្បត្តិ គាត់មិននិយាយអង់គ្លេសទេ ប៉ុន្តែអ្នកសរសេរភាសាអង់គ្លេសហ្នឹងគឺ ជីណា ចន។ ជីណា ចន គាត់ធ្វើឲ្យច្របូកច្របល់<នូវ> ជឿន មួយនេះជាមួយនឹង <ឈឿន> ជាមេបញ្ជាការកងពល។ <នេះជាអ្វីដែលបានកើតឡើង សម្រាប់យើងគឺវាច្បាស់ខ្លាំងណាស់។>

[១១:១២:២៤]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោក នីកូឡាស គូមជែន៖**

សូមអភ័យទោស។ មេធាវី ឥឡូវនេះគឺគាត់ផ្ដល់សក្ខីកម្មថា ថេត សម្បត្តិ មិននិយាយភាសាអង់គ្លេស។ ប៉ុន្ដែនៅក្នុងខ្សែភាពយន្ដ ថេត សម្បត្តិ ក៏គាត់និយាយអង់គ្លេសដែរ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<ហើយលោកក៏បានលើកឡើងដែរថា អ្វីដែលលោកគិត ជាកំហុសដែលបានបង្កើតឡើង។ តើយើងអាចបញ្ឈប់ការរកលេសការពារទៀតបានទេ? ការពិតគឺនៅទីនេះហើយ។ ឯកសារពាក់ព័ន្ធមាននៅទីនេះហើយ។ អង្គជំនុំជម្រះនឹងសម្រេចលើរឿងនេះ>។

**អ្នកបកប្រែ៖**

លោកប្រធាន ស្នើសុំឲ្យលោកមេធាវី ហើយនិងលោកស្រីទុកគម្លាតបន្ដិច។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<យើងអាចជជែកតវ៉ាគ្នានៅវគ្គក្រោយ។>

**លោក វ៉ិចទ័រ កូប៉េ៖**

<នេះជាអ្វីដែលសហព្រះរាជអាជ្ញាធ្វើរាល់ពេលដែលគេអានពីឯកសារ ស-២១។ នេះជាអ្វីដែលពួកគេធ្វើគ្រប់ពេល។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<យើងបានអនុញ្ញាពេលខ្លះដែរ ដូចដែលលោកបានកត់សម្គាល់ហើយ។>

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** នេះជាការជំទាស់ដែលមិនត្រឹមត្រូវ។ លោកសាក្សី ឥឡូវនេះ ខ្ញុំសួរលោកអ៊ីចេះវិញ លោកថា លឹមគិន ហើយនិង សម្បត្តិ មិនដែលសម្លាសលោកទេ ប៉ុន្ដែលោកអាចប្រាប់បានទេថា តើលោកធ្វើដំណើរជាមួយពួកគាត់ប៉ុន្មានដងដែរ? ធ្វើដំណើរតែម្ដងទៅថៃ ឬមួយក៏លោករួមដំណើរជាមួយគាត់ច្រើនដង?

[១១:១៣:២៨]

**លោក ជាល ជឿន៖**

**ឆ៖** ធ្វើដំណើរទៅថៃតែម្ដងហ្នឹង ហើយនិងបើនៅទៅកន្លែងណាទៀត អត់ទេ។ តែគ្រាន់តែនៅកៀនៗហ្នឹង គាត់សួររកកន្លែងដែលគាត់ត្រូវការធ្វើការថតកុនថតអីហ្នឹង អាហ្នឹងខ្ញុំប្រាប់ ហើយគាត់ថា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

01385948



កន្លែងណាដែលស្ងាត់ស្រួលធ្វើការ ខ្ញុំក៏ប្រាប់ ហើយនាំគាត់ទៅប្រាប់កន្លែងក្រៅ ខាងក្រៅភូមិដែលគាត់ត្រូវថតត្រូវអីហ្នឹង។ អ៊ីចឹងប្រាប់ទៅ ក៏គាត់ឲ្យជូនគាត់ទៅជិតៗភូមិហ្នឹងចម្ងាយប្រែជា២០០ម៉ែត្រ ៣០០ម៉ែត្រពីកន្លែងដែលខ្ញុំរស់នៅហ្នឹង។ ហើយគាត់ទៅថតខ្សែភាពយន្តហ្នឹង។ អាហ្នឹងខ្ញុំបានជូនគាត់ទៅប្រាប់អ៊ីចឹងមែន តែបើថាឲ្យទៅណាទៅណីជាមួយទៀត អត់ ខ្ញុំអត់ដែល ដែលតែទៅថៃម្តង។

**ស៖** សូមអរគុណលោកសាក្សី។ មុនពេលដែលខ្ញុំឈានទៅប្រធានបទបញ្ចប់ ខ្ញុំមានសំណួរបន្តិចទាក់ទងទៅនឹងការងាររបស់លោកនៅស្ថានីយរថភ្លើង។ ហើយព្រះរាជអាជ្ញាគាត់ហាក់ដូចជាចាប់អារម្មណ៍ត្រង់ចំណុចនេះខ្លាំង។ លោកបាននិយាយអំពីរថភ្លើងដែលលោកជួយរើអីវ៉ាន់ចុះហ្នឹង។ ប៉ុន្តែលោកអាចប្រាប់បានទេថា រថភ្លើងហ្នឹងធ្វើដំណើរពីណា ហើយតើអីវ៉ាន់ដែលគេដឹកហ្នឹងគេដឹកយកទៅណា ឬក៏យកទៅឲ្យទៅឲ្យអ្នកណាដែរ?

[១១:១៥:០៨]

**ឆ៖** បាទ កន្លែងនែថាខ្ញុំជួយរើអីវ៉ាន់ហ្នឹង គឺខ្ញុំមិនបានជួយរើទេ។ តែគ្រាន់តែខ្ញុំជួសជុលផ្លូវជួនកាលទៅខ្ញុំជួសជុលក្នុងស្ថានីយហ្នឹង ឃើញរថភ្លើងហ្នឹងទៅពីភ្នំពេញទៅវិញ ហើយដឹកដូចស៊ីម៉ងត៍ដូចអី គេលីដាក់ឃ្លាំងដាក់អីហ្នឹង អាហ្នឹងចំណែកគេផ្សេងខាងពាណិជ្ជកម្មអីផ្សេងទេ ពួកខ្ញុំអត់មានពាក់ព័ន្ធអីទៅខាងលីសែងអ៊ីចឹងៗទេ ហើយអត់មានបានជួយរើជួយទុកដាក់អីគេទេ។ ពួកខ្ញុំធ្វើផ្លូវដែក គ្រាន់តែខ្ញុំមើលទៅឃើញ តែគ្រាន់តែបើស៊ីម៉ងត៍ជួនកាលក៏គេដាក់ផ្ទេរពីប៉ារុងរទេះភ្លើងដាក់ឡានដឹកទៅបាត់ទៅ មិនដឹងដឹកទៅណា។ តែជួនកាលទៅក៏គេមានឃ្លាំងគេនៅហ្នឹង វ៉ាហ្នឹងគេជញ្ជូនចេញប៉ារុងរទេះភ្លើងដាក់ចូលឃ្លាំងហ្នឹងទុកទៅ គ្រាន់តែប៉ុណ្ណឹងទេ អាហ្នឹងគ្រាន់ដឹងប៉ុណ្ណឹងទេ។

**ស៖** ប៉ុន្តែ<ដើម្បីឲ្យច្បាស់> អ៊ីចឹងលោកមិនដឹងទេថា កងមួយណា ឬក៏ភូមិភាគមួយណាដែលគេបញ្ជូនទំនិញហ្នឹងទៅ ហើយតើគេបញ្ជូនហ្នឹងបញ្ជូនទៅឲ្យអ្នកណាទេ តើអ៊ីចឹងមែនទេ?

**ឆ៖** អត់ដឹង ខ្ញុំអត់ដឹងទេ។

**ស៖** ឥឡូវនេះ ខ្ញុំគិតថាប្រហែលជាយើងត្រូវបន្តជាអសាធារណៈហើយ ព្រោះខ្ញុំត្រូវដកស្រង់នៅសក្ខីកម្មរបស់ <TCW-10600>*(ស៊ីក)*។

[១១:១៧:០៣]

**ប្រធានអង្គជំនុំ៖**

បាទ ហើយតទៅនេះអង្គជំនុំជម្រះធ្វើសវនាការអសាធារណៈ ហើយបង្គាប់ឲ្យបុគ្គលផ្នែកសោត

ទស្សន៍ផ្តាច់ការផ្សព្វផ្សាយសំឡេង ដែលផ្សាយចេញពីបន្ទប់សវនាការនេះទៅកាន់សាលសវនាការធំ សម្រាប់សាធារណជនទៅបន្ទប់ផ្សព្វផ្សាយសម្រាប់អ្នកសារព័ត៌មាន ហើយនិងទៅបុគ្គលិក អ.វ.ត.ក ផ្សេងទៀតសម្រាប់ តាមរយៈវីដេអូសម្រាប់ផ្ទៃក្នុងសវនាការ។ ហើយលើកលែងតែបុគ្គលិកនៃភារកិច្ច ដែលមានចូលរួមពាក់ព័ន្ធក្នុងកិច្ចដំណើរការសវនាការនេះ ដូចត្រូវនៅបន្តការផ្សាយផ្ទាល់សម្រាប់ដល់មន្ត្រីគាំទ្រកិច្ចការកិច្ចដំណើរការសវនាការ។

[១១:១៨:១៣]

*(សវនាការសម្រាកនៅម៉ោង ១១:១៨ នាទី)*

*(សវនាការអសាធារណៈចាប់ផ្តើមពីម៉ោង ១១:១៨ នាទី និងបញ្ចប់នៅម៉ោង ១១:២២ នាទី)*

*(សវនាការសាធារណៈបន្តនៅម៉ោង ១១:២២ នាទី)*

**ប្រធានអង្គជំនុំ៖**

អរគុណ ហើយសូមឲ្យធ្វើការចាក់ផ្សាយតាមធម្មតាឡើងវិញ ជាសាធារណៈ ធ្វើសវនាការជាសាធារណៈឡើងវិញ ខាងផ្នែកសោតទស្សន៍។

[១១:២២:៣៦]

បាទ តទៅនេះ ជូនវេទិកាជូនទៅសហមេធាវីការពារក្តីលោក ខៀវ សំផន។

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន សូមគោរពលោកគោរពលោកប្រធាន លោក លោកស្រីចៅក្រម និងភាគីទាំងអស់។ យោងទៅតាមគោលជំហរដែលយើងបានបង្ហាញជូនក្នុងពេលចៅក្រម ឡាវ៉ែន៍ សួរនោះ ខ្ញុំគិតថាសាក្សីរូបនេះមិនមានអ្វីពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង០០២/០២ ទេ។ ដូច្នេះ ខ្ញុំមិនសួរទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណមេធាវី។ អង្គជំនុំជម្រះអរគុណលោក ជាល ជឿន សវនាការស្តាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនាពេលនេះដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោកនឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។ វត្តមានរបស់លោកនៅ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅ

បានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ ហើយបានសេចក្ដីសុខសេចក្ដីចម្រើន។ អង្គជំនុំជម្រះអរគុណលោកស្រីមេធាវី សុក សុជាតា មេធាវីប្រឹក្សាសាក្សី នាពេលនេះសវនាការស្ដាប់សក្ខីកម្មរបស់លោក ជាល ជឿន បានចប់ហើយ ដូច្នេះលោកស្រីអាចសម្រាកបានហើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សី ជូនលោក ជាល ជឿន ត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណា ដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយពេលនេះ ដល់ពេលសម្រាកអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀលនេះ សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១១:២៥ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:១៤]

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅរសៀលនេះ អង្គជំនុំជម្រះផ្ដើមធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1037។ ហើយមុននឹងអញ្ជើញសាក្សី មកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការ អង្គជំនុំជម្រះចេញសេចក្ដីសម្រេចផ្ទាល់មាត់លើសំណើសុំអនុលោមតាមវិធាន៨៧(៣) និង ៨៧(៤)នៃវិធានផ្ទៃក្នុង ដែលបានធ្វើឡើងនៅក្នុងអំឡុងពេលសវនាការ។ អង្គជំនុំជម្រះយោងទៅលើសំណើរបស់សហមេធាវីការពារក្ដី នួន ជា អនុលោមតាមវិធាន៨៧(៤) និងវិធាន៩៣នៃវិធានផ្ទៃក្នុង។ ឯកសារ E445/1 ដែលបានដាក់ជាឯកសារសម្ងាត់នៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ សុំឲ្យទទួលយកឯកសារចំនួនប្រាំបី និងឲ្យបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងឯកសារចំនួនពីរ។ សវនាការស្ដាប់សេចក្ដីសន្និដ្ឋានផ្ទាល់មាត់ ឆ្លើយតបទៅនឹងសំណើនេះដោយបានធ្វើឡើងកាលពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៦។ អនុលោមតាមវិធន៨៧(៤)នៃវិធានផ្ទៃក្នុង អង្គ

ជំនុំជម្រះទទួលយកឯកសារទី១ ដល់ឯកសារទី៧ និងបដិសេធមិនទទួលយកឯកសារទី៨ ដោយហេតុថា អង្គជំនុំជម្រះបដិសេធមិនទទួលយកឯកសារទី៨ ហេតុដូច្នេះហើយសំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យទទួលយកឯកសារចំនួនបីផ្សេងទៀត លែងមានភាពចាំបាច់ទៀតហើយ។

[១៣:៣៣:០៥]

ពាក់ព័ន្ធនឹងឯកសារទី១ អង្គជំនុំជម្រះបង្គាប់ឱ្យមេធាវីការពារក្តី នួន ជា បង្ហាញនូវផ្នែកទាំងឡាយនៃឯកសារដែលមានចំនួន២១៥ទំព័រ ដែលពាក់ព័ន្ធបំផុតទៅនឹងសក្ខីកម្មរបស់អ្នកជំនាញ E-TCE-98 ដែលពួកគាត់មានបំណងយកមកប្រើប្រាស់។ ចំពោះសំណើសុំអនុលោមតាមវិធាន៨៣នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះបានស្នើឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ទាក់ទងជាមួយនឹងអ្នកជំនាញដើម្បីស្នើសុំឱ្យគាត់ផ្តល់នូវសំណៅពេញលេញនៃឯកសារទី១។ អង្គជំនុំជម្រះបដិសេធសំណើសុំអនុលោមវិធាន៨៣នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងឯកសារទី២។ សំអាងហេតុជាលាយលក្ខណ៍អក្សរពេញលេញសម្រាប់សេចក្តីសម្រេចនេះ នឹងចេញក្នុងពេលសមស្របឆាប់ៗខាងមុខនេះ។

ជាបន្តទៅនេះ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សីដែលមានរហស្សនាម 2-TCW-1037 ហើយសាក្សីនេះ មានមេធាវីប្រឹក្សាសាក្សីលោក មឿន សុវណ្ណ។ ហើយអង្គជំនុំជម្រះ កត់សម្គាល់ថា សាក្សីរូបនេះ ត្រូវបានស្តាប់ចម្លើយនៅក្នុងកិច្ចស៊ើបអង្កេតដែលកំពុងដំណើរការនៅក្នុងសំណុំរឿងផ្សេង។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកំណត់សាក្សីរូបនេះ ស្ថិតនៅក្នុងក្រុម “ក” នៃក្រុមទាំងបីប្រភេទនៅក្នុងអនុស្សរណៈរបស់ខ្លួន សូមមើលឯកសារ E19/35 ហើយបានស្នើថា សាក្សីរូបនេះ គួរប្រើរហស្សនាម ក្នុងគោលបំណងការពារនូវភាពសម្ងាត់នៃកិច្ចដំណើរការស៊ើបអង្កេត។ អង្គជំនុំជម្រះយល់ឃើញថា វិធានការដែលមានកម្រិតបែបនេះ គឺត្រឹមត្រូវ សមស្របតាមច្បាប់ ក្នុងករណីបែបនេះ។ ហើយការបង្គាប់ គឺត្រូវធ្វើឱ្យមានតុល្យភាពគ្នា រវាងតម្រូវការនៃសាធារណភាពនៃសវនាការជាមួយនឹងការការពារសុចរិតភាពនៃការងារស៊ើបអង្កេត។ ហើយអង្គជំនុំជម្រះក៏សូមរំឭកដល់ភាគីផងដែរថា ឱ្យគោរពឱ្យបានខ្ជាប់ខ្ជួននូវសេចក្តីណែនាំនៅក្នុងឯកសារ E319/7 ក្នុងការប្រើប្រាស់ឯកសារដាក់បង្ហាញពីសំណុំរឿងផ្សេង។

បង្គាប់ឱ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សី 2-TCW-1037 រួមទាំងមេធាវីប្រឹក្សាសាក្សីគឺលោក មឿន សុវណ្ណ ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៣:៣៧:២៣]

**ប្រធានអង្គជំនុំ៖**

សួស្តីលោកសាក្សី នៅក្នុងកិច្ចដំណើរការសវនាការនៅចំពោះមុខអង្គជំនុំជម្រះ តាមសំណើសុំរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺយើងនឹងប្រើប្រាស់តែរហស្សនាមរបស់លោកតែប៉ុណ្ណោះ ហើយលោកមានរហស្សនាម 2-TCW-1037 ហើយជាទូទៅភាគីតែងតែប្រើប្រាស់ហៅលោកថា លោកសាក្សីប៉ុណ្ណោះ អ៊ីចឹងហើយសូមលោកយល់ថា អង្គជំនុំជម្រះនឹងមិនអនុញ្ញាតឲ្យភាគីពាក់ព័ន្ធរួមទាំងចៅក្រមនៃអង្គជំនុំជម្រះខ្លួនឯងផង មិនឲ្យប្រើប្រាស់នាមត្រកូល និងនាមខ្លួនរបស់លោកជាសាធារណៈនៅក្នុងសវនាការនេះឡើយ។

ហើយមន្ត្រីរដ្ឋបាលតុលាការទៅយក -- ទទួលឯកសារ E3/9580 យកទៅជូនលោកសាក្សីពិនិត្យ។

*(មន្ត្រីតុលាការយកឯកសារជូនសាក្សី)*

[១៣:៣៨:៣៤]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** លោកសាក្សី តទៅនេះអង្គជំនុំជម្រះសូមឲ្យលោកបញ្ជាក់អំពីអត្តសញ្ញាណរបស់លោកដែលមាននៅក្នុងឯកសារ E3/9580 ដែលមានលេខ ERN ភាសាខ្មែរ 00951901, ERN ជាភាសាអង់គ្លេស 00978416 និង ERN ជាភាសាបារាំង 01004431។ សូមលោកសាក្សីពិនិត្យមើលកន្លែងដែលមានហាយឡាយពណ៌ទឹកក្រូចត្រង់ចំណុចនាមត្រកូល នាមខ្លួន សញ្ជាតិ ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត មុខរបរ ឪពុក ឈ្មោះឪពុក ឈ្មោះម្តាយ ឈ្មោះប្រពន្ធរបស់លោក និងចំនួនកូនរបស់លោក។ តើការសរសេរដូចនេះត្រឹមត្រូវដែរឬទេ? លោកសាក្សីគ្រាន់តែឆ្លើយថា ការសរសេរនេះពិតជាត្រឹមត្រូវ ឬមិនត្រឹមត្រូវទៅបានហើយ។ ហើយលោកសាក្សី តើលោកមានឯកសារនៅក្នុងដៃនោះ លោកមើល តើត្រឹមត្រូវដែរឬទេ?

**2-TCW-1037៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** បាទ អរគុណលោកសាក្សី។ ហើយតាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការកាលពី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ព្រឹកមិញនេះថា តាមសមត្ថភាពដែលលោកអាចដឹងគឺលោកមិនមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ក៏ដូចជាបុគ្គលទាំងឡាយដែលទទួលយកជាភាគដើមបណ្តឹងរដ្ឋប្បវេណីក្នុងរឿងក្តីនេះទេ តើពិតមែនដែរឬទេ?

**ឆ៖** បាទ ពិតហើយរឿងនេះ។

[១៣:៤០:២៤]

**ស៖** ទុកឯកសារហ្នឹងម្តុំចុះ លែងត្រូវការប្រើប្រាស់វាទៀតហើយណ៎ះ! លោកសាក្សី តើលោកបានធ្វើសម្បថរួចហើយ ឬនៅ មុននឹងចូលមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** បាទ រួចហើយ។

**ស៖** តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោកក្នុងឋានៈលោកជាសាក្សីដែលត្រូវផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ។ លោកសាក្សី ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬក៏សុំឲ្យលោកធ្វើអត្ថាធិប្បាយរៀបរាប់ណាដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង មានន័យថាដោយសារតែចម្លើយ ឬសេចក្តីរៀបរាប់នោះនាំឲ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។ អំពីករណីយកិច្ច លោកសាក្សីក្នុងឋានៈលោកជាសាក្សី លោកត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលសួរឡើងដោយភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក លើកលែងតែសំណួរណាដែលនាំឲ្យចម្លើយតបរបស់លោក ឬការធ្វើអត្ថាធិប្បាយរបស់លោកដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិអម្បាញ់មិញនេះរួចហើយ។ ហើយក្នុងឋានៈលោកជាសាក្សី ត្រូវតែឆ្លើយតែការណ៍ណាដែលពិតដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ នូវហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។ លោកសាក្សី តើលោកធ្លាប់ផ្តល់សក្ខីកម្ម ឬក៏ផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេក្នុងរយៈពេលកន្លងមកនេះ ប្រសិនបើធ្វើៗប៉ុន្មានដង? ធ្វើនៅទីកន្លែងណា?

[១៣:៤២:១១]

**ឆ៖** រឿងនេះ ខ្ញុំបានចូលឆ្លើយក្នុងការដែលខាងតុលាការចុះស៊ើបអង្កេតនៅនឹងផ្ទះខ្ញុំតែម្តង។

**ស៖** ហើយប៉ុន្មានលើក លោកគេធ្វើហ្នឹង ផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតនោះប៉ុន្មាន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លើក?

**ឆ៖** ចំនួនពីរលើក។

**ស៖** បាទ អរគុណ។ ហើយនៅមុនពេលចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកសាក្សីបានពិនិត្យមើល បានអាន ឬក៏ស្តាប់ការអានទូវកំណត់ហេតុដែលលោកបានផ្តល់កិច្ចសម្ភាសន៍កាលពីពេលមុននៅនឹងផ្ទះរបស់លោកដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** ខ្ញុំចាំមិនបានទាំងអស់ទេ ព្រោះវាយូរឆ្នាំដែរហើយ ទើបមករំឭកនៅពេលនេះ អ៊ីចឹងចាំបានតែចំណុចសំខាន់ៗបានមួយចំនួនធំបាទ។

**ស៖** បាទ អរគុណ។ ហើយតាមសមត្ថភាពដែលលោកអាចដឹង និងចងចាំថាតើលោកអាចបញ្ជាក់បានដែរទេថាកំណត់ហេតុដែលស្តាប់ចម្លើយដែលលោកបានអានដើម្បីរំឭកការចងចាំនោះ គឺវាពិតជាត្រឹមត្រូវ សមស្រប ស៊ីសង្វាក់គ្នាទៅនឹងចម្លើយ សក្ខីកម្មដែលលោកបានផ្តល់កិច្ចសម្ភាសន៍នៅនឹងផ្ទះរបស់លោកកាលពីពេលមុននោះដែរឬទេ?

**ឆ៖** បាទ ចម្លើយដែលខ្ញុំបានឆ្លើយក្នុងពេលដែលស៊ើបអង្កេត ស្រាវជ្រាវ សួរនាំនោះគឺថាពិនិត្យមើលទៅឃើញថាខុសតិចតួចត្រង់ចំណុចថា រវាងដូចជានឹងថ្ងៃខែឆ្នាំ ខ្ញុំមិនបានចាំជាក់លាក់ប៉ុន្មានទេបាទ វាមានការខុសខែ ខុសថ្ងៃអីតិចតួច។

[១៣:៤៤:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយក្នុងការសួរដេញដោលសាក្សីរូបនេះអនុវត្តតាមវិធាន៩១ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅសហមេធាវីការពារក្តី នួន ជា សួរដេញដោលសាក្សីរូបនេះមុនភាគីដទៃទៀតនៃរឿងក្តី។ សូមបញ្ជាក់ថាសហមេធាវីការពារក្តី នួន ជា រួមទាំងសហមេធាវីការពារក្តី ខៀវ សំផន មានរយៈពេលសរុបពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម។

[១៣:៤៥:០៤]

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំគឺជាមេធាវីអន្តរជាតិការពារក្តី នួន ជា ហើយខ្ញុំមានសំណួរមួយចំនួនដើម្បីសាកសួរលោកនៅរសៀលនេះ។ នេះជាសំណួរចាប់ផ្តើមមួយដែលថា លោកឆ្លើយថា គេសម្ភាសលោកពីរដង គឺអ្នកស៊ើបអង្កេតបានសម្ភាសលោកពីរដង។ តើត្រឹមត្រូវដែរឬទេ ដែលថានៅក្នុងឆ្នាំ២០១៣ លោកត្រូវបានអ្នកស៊ើបអង្កេតរបស់តុលាការនេះចុះទៅសម្ភាស ហើយឆ្នាំ២០១៦ គឺមាន -- ២០០៦ គឺមានអ្នកតំណាងម្នាក់មកពីមជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានធ្លាប់សម្ភាសលោកដែរ។ តើត្រឹមត្រូវទេ?

**2-TCW-1037៖**

**ឆ៖** បាទ ត្រឹមត្រូវ។

**ស៖** សូមអរគុណលោក។ ឥឡូវនេះ ខ្ញុំចង់សួរលោកថាតើលោកអាចប្រាប់តុលាការបានទេថា តើលោកចូលបដិវត្តន៍នៅឆ្នាំណាដែរ?

[១៣:៤៦:១៩]

**ឆ៖** តាមខ្ញុំចាំ ដែលខ្ញុំចូលធ្វើបដិវត្តន៍នៅឆ្នាំ១៩៧០ រហូតដល់ឆ្នាំ៧៥ ថ្ងៃរំដោះ ១៧ មេសា។

**ស៖** តើលោកអាចប្រាប់បានទេ មុន<ថ្ងៃទី១៧> ខែមេសា ៧៥ ហ្នឹងតើលោកមានតួនាទីអ្វីដែរ ហើយតើលោកបោះទីតាំងនៅកន្លែងណាដែរ លោកអាចប្រាប់បានទេ?

**ឆ៖** បាទ រឿង ហ្នឹងតាមដែលខ្ញុំចាំក្នុងឆ្នាំ១៩៧០ រហូតដល់ ៧៥ ខ្ញុំបាន ដំបូងខ្ញុំចូលធ្វើជាកងទ័ពរំដោះជាតិ ហើយក្រោយមកបានខ្ញុំ រយៈពេល៣ឆ្នាំបានខ្ញុំឈប់ពីធ្វើទ័ព ខ្ញុំមកទទួលភារកិច្ចខាងផ្នែកសេដ្ឋកិច្ចរបស់យោធាភាគ។

**ស៖** តើនៅពេលណាដែលលោកចាប់ផ្តើមធ្វើការឲ្យខាងភស្តុភារ ហើយនិងសេដ្ឋកិច្ចរបស់ខាង <ភូមិភាគ>ពាយ័ព្យដែរ?

**ឆ៖** និយាយរួម ចំណុចហ្នឹង ខ្ញុំចាប់ផ្តើមធ្វើពីឆ្នាំ១៩៧៣។

**ស៖** តើលោកមានតួនាទីអ្វីដែរ នៅពេលដែលលោកធ្វើការនៅផ្នែកភស្តុភារ ហើយនិងសេដ្ឋកិច្ចនោះ តើលោកធ្វើការងារអ្វីដែរ?

**ឆ៖** ភារកិច្ចចំពោះមុខរបស់ខ្ញុំ គឺការងារគ្រប់គ្រងស្បៀងអាហារ និងគ្រាប់រំសេវ ហើយនិងមន្ទីររបស់ក្រសួងយោធាភាគ។

[១៣:៤៩:១៥]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**សៈ** តើត្រឹមត្រូវទេ ដែលមាន នៅពេលមួយនោះលោកក្លាយទៅជា ប្រធានខាងភស្តុភារសេដ្ឋកិច្ចនៅក្នុងភូមិភាគពាយ័ព្យនោះ?

**ឆៈ** ខ្ញុំមិនមែនជាប្រធានទេ តែខ្ញុំជាដូចថា ជាផ្នែកមួយសម្រាប់បម្រើឲ្យសមរភូមិមុខ ការផ្តល់ស្បៀងអាហារ និងសម្លៀកបំពាក់ គ្រាប់រំសេវទៅឲ្យសមរភូមិមុខ។

**សៈ** ប្រហែលជាមានការបកប្រែមិនត្រឹមត្រូវនៅក្នុងឯកសារលោក <ខ្ញុំមិនច្បាស់ប៉ុន្មានទេ> ប៉ុន្តែ ខ្ញុំសូមអាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក <E3/9580> គឺសំណួរ-ចម្លើយលេខ២ លោកបាននិយាយថា៖ "ខ្ញុំចូល<ធ្វើយោធា>ខ្មែរក្រហមនៅក្នុងឆ្នាំ៧០ ហើយក្នុងឆ្នាំ៧៣ ខ្ញុំឈប់ទៅច្បាំងទៀតហើយ គឺខ្ញុំធ្វើជាប្រធានគ្រប់គ្រងភ័ស្តុភារ <និង>សេដ្ឋកិច្ចរបស់យោធាភូមិភាគពាយ័ព្យ។ ខ្ញុំនៅមានតួនាទីដដែលរហូតដល់ថ្ងៃទី១៧ មេសា ឆ្នាំ៧៥ តែខ្ញុំប្តូរទីតាំងមកនៅផ្សារលើទីរួមខេត្តបាត់ដំបង។" តើត្រឹមត្រូវទេ ដែលលោកបានឆ្លើយបែបនេះ<ទៅអ្នកស៊ើបអង្កេត> នៅក្នុងឯកសារ E3/9580?

**ឆៈ** បាទ ឯកសារដែលចម្លើយលើកមុនន៉ុង គឺខ្ញុំបាននិយាយអ៊ីចឹងមែន ប៉ុន្តែភ័ស្តុភារហ្នឹង មិនមែនខ្ញុំជាប្រធានទេ។ កាលហ្នឹងខ្ញុំធ្វើជាប្រធានហ្នឹង ប្រធានដឹកជញ្ជូនផ្នែកៗសេដ្ឋកិច្ច ផ្តល់ស្បៀងអាហារ និង សម្ភារៈយុទ្ធភណ្ឌ គ្រប់រំសេវអីហ្នឹង គឺទៅឲ្យសមរភូមិមុខនៅលើខ្ញុំអ្នកគ្រប់គ្រង តែខាងភ័ស្តុភារ គឺជាផ្នែកមួយរបស់សេនាធិការរបស់យោធាដោយឡែកផ្សេង។

[១៣:៥១:៥៥]

**សៈ** ឥឡូវនេះ ខ្ញុំចង់សួរបន្តទៀត។ បើដូច្នេះ <តើត្រឹមត្រូវទេនៅពេល>លោកធ្វើការខាងភ័ស្តុភារសេដ្ឋកិច្ចដឹកជញ្ជូនអាវុធគ្រាប់រំសេវទៅឲ្យទាហាន <ដែល>លោកនៅក្រោមកងពលធំមួយដែលក្រោយមកគេហៅថា ជាកងពលធំលេខ២ហ្នឹង អ៊ីចឹងមែនទេ?

**ឆៈ** បាទ អ៊ីចឹងមែន។

**សៈ** តើលោកអាចប្រាប់បានទេថា មេបញ្ជាការផ្ទាល់របស់លោកជាអ្នកណា នៅពេលដែលលោកនៅក្រោមកងពលធំលេខ២ នោះ?

**ឆៈ** បញ្ជាការ មេបញ្ជាការកងពលធំលេខ២ហ្នឹង គឺនិយាយឈ្មោះ គឺឈ្មោះ រ៉េន។

**សៈ** សូមអញ្ជើញលោក ខ្ញុំសូមទោស។

**ឆៈ** បាទៗ ហើយឈ្មោះ តាហំ មួយទៀត។ តាហំ និង តាក្លែង។ តាក្លែង, តាហំ ហ្នឹងគឺជាប្រធានសេនាធិការកងពលលេខ២ ហ្នឹងបណ្តោយ។

**ស៖** តើលោកដឹងទេថា មានអនុលេខាកងពល២ ឈ្មោះ ខូយ <ឬឈ្មោះ កឹ>ដែរឬទេ? តើលោកស្គាល់ឈ្មោះ ខូយ <ឬ កឹ>នេះទេ?

**ឆ៖** ខូយ ធ្លាប់ឮឈ្មោះ ប៉ុន្តែខ្ញុំមិនដឹងថា គាត់នៅហ្នឹង ឬមិនដឹងនៅ។ ខ្ញុំអត់ដឹងដែរ។

[១៣:៥៤:១៥]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតបង្ហាញឯកសារដដែល ដែលខ្ញុំបានបង្ហាញជូនសាក្សីពីព្រឹកមិញនេះ គឺE3/1170 គឺជាអង្គការលេខរបស់កងពល<ចំនួនពីរ>នៅខាងកងពលពាយ័ព្យ សូមឯកឧត្តមប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកអាចមើលឃើញអ្វីដែលសរសេរនៅលើនោះទេ?

**2-TCW-1037៖**

**ឆ៖** បាទ ឃើញ។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សុំអភ័យទោស ដើម្បីឲ្យមានការបញ្ជាក់ តើ ERN ភាសាអង់គ្លេសមានប៉ុន្មានដែរ?

**លោក វ៉ិចទ័រ កូប៉េ៖**

ឲ្យខ្ញុំសុំទោសផងគឺ 00602544, ខ្មែរមានលេខ 00443016, បារាំងមានលេខ 06544895។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី នៅពេលដែលយើងនិយាយអំពីកងពលទី២ <ដែលលោកជាសមាជិក> នោះគឺលោកឃើញឈ្មោះ<មេបញ្ជាការចំនួន>បី គឺ ក្លែង, ខូយ <ឬកឹ>, ហើយនិង រ៉េន។ តើលោកឃើញឈ្មោះទាំងពីរនេះទេ -- ទាំងបីនេះទេ?

**2-TCW-1037៖**

**ឆ៖** បាទ ឃើញទាំងបីហ្នឹង។

[១៣:៥៦:៤០]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើឈ្មោះទី២ធ្វើឲ្យលោកនឹកឃើញទេ គឺឈ្មោះ ខូយ ហ្នឹងជាឈ្មោះដែលយើងទើបតែជជែកគ្នាមុនហ្នឹងបន្តិចមែនទេ?

**ឆ៖** បាទ ខ្ញុំនឹកមិនឃើញឈ្មោះ ខូយ ហ្នឹងគឺមានឈ្មោះមែន តែខ្ញុំមិនដឹងថាគាត់ជាតួនាទីអីទេ គឺបើឈ្មោះ ខ្លែង ហើយនិងឈ្មោះ រ៉េន ហ្នឹងគឺខ្ញុំចាំមុខគាត់ច្បាស់ ហើយនិងឈ្មោះ ហំ មួយទៀត។

**ស៖** យើងនឹងពិភាក្សាអំពីឈ្មោះ ហំ នៅពេលក្រោយបន្តិចទៀតនេះ។ ប៉ុន្តែឥឡូវនេះយើងនឹងមើលទៅលើជារួម។ នៅពេលដែលលោកមើលចុះទៅក្រោមបន្តិចគឺលោកឃើញកង<វរសេនាធំ>៧០ គឺលោកឃើញឈ្មោះ រ៉េន, រឿត និង សែ។ តើឈ្មោះ រ៉េន ហ្នឹងគឺជាឈ្មោះដែលលោកនិយាយ ឬមួយក៏ឈ្មោះ រ៉េន ដែលជា<មេ>បញ្ជាការ<មួយរូប> តើមែនទេ?

**ឆ៖** បាទ រ៉េន នេះគឺនៅក្នុងបញ្ជាការកងពល។ ហើយឈ្មោះ រឿត ហ្នឹងតាមខ្ញុំស្គាល់ គឺជាកងវរសេនាធំ។

**ស៖** តើលោកនិយាយឈ្មោះ <>រឿន <> ឬក៏ រឿត?

**ឆ៖** ឈ្មោះ រឿត – ឈ្មោះ រឿត ហ្នឹងគឺ តាមខ្ញុំស្គាល់គឺប្រធានកងវរសេនាធំ ក្នុងកងពលទី២ ហ្នឹង លេខ២ហ្នឹង។

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំឲ្យលោកទៅទំព័រម្ខាងទៀត នៅទីនោះលោកឃើញថា មានមេបញ្ជាកកងពលលេខ១។ យើងឃើញមានឈ្មោះ នង សារឹម ហៅ សាន។ ចំណែកអនុលេខា ឈ្មោះ <នៅ>។ ហើយសមាជិកកងពលហ្នឹងគឺឈ្មោះ ឈន។ តើលោកឃើញឈ្មោះទាំងបីនេះទេ? ប្រសិនបើបានឃើញ តើលោកធ្លាប់ស្គាល់ឈ្មោះនេះទេ? តើលោកធ្លាប់ស្គាល់មនុស្សទាំងបីនាក់នេះទេ?

[១៣:៥៩:៥៤]

**ឆ៖** បាទ ខ្ញុំមើលឃើញ។ តែឈ្មោះនេះ ខ្ញុំស្គាល់មួយ ស្គាល់ឈ្មោះ ឈួន ហើយពីរឈ្មោះ សារឹម មួយ សារឹម និង ឈួន ហ្នឹងធ្លាប់ស្គាល់ តែអត់ដឹងថាតួនាទីភារកិច្ចរបស់គេប៉ុនណាខ្ញុំអត់ដឹង។

**ស៖** សូមអរគុណលោកសាក្សី។ តើលោកអាចប្រាប់បានទេនៅពាយ័ព្យហ្នឹង គឺកងពលលេខ២ ដូចជាកងពលរបស់លោកហ្នឹង គេបោះទីតាំងនៅកន្លែងណាដែរ? ចុះៗ<ទី>បញ្ជាការរបស់កងពលលេខទី១វិញ តើនៅកន្លែងណាដែរក្នុងភូមិភាគពាយ័ព្យនោះ?

**ឆ៖** តាមខ្ញុំដឹងទីតាំងបញ្ជាការកងពលទី១ និងទី២នេះ កាលហ្នឹងគឺនិយាយពីរឿងទ័ពរបស់កងពល។ កងពលលេខ១ តាមខ្ញុំដឹងគឺនៅមួយជួរផ្លូវជាតិលេខ៥ បាទទៅប៉ោយប៉ែត។ ហើយកងពលលេខ

២ នៅផ្លូវជាតិលេខ១០ បាទអតីតផ្លូវជាតិលេខ១០ ចាស់មុនហ្នឹង ចាប់ពីយើងទីរួមខេត្តបាត់ដំបងរហូតទៅដល់ប៉ៃលិន។ ហើយទីបញ្ជាការកងពលនៅឃុំត្រែងបាទ នៅត្រែងយើងសព្វថ្ងៃនេះក្នុងខេត្តនៅក្នុងស្រុករតនៈមណ្ឌលបច្ចុប្បន្ន។

[១៤:០២:១២]

**សៈ** ឥឡូវនេះខ្ញុំសូមសួរបន្តបន្ទិចទៀត ឥឡូវនេះសួរទាក់ទងទៅនឹងកំណត់ហេតុស្ដាប់ចម្លើយ E3/9580 គឺសំណួរ៤៦ គឺលោកនិយាយថាបញ្ជា គឺមូលដ្ឋានធំរបស់កងពលលេខ២ នៅឃុំត្រែង ស្រុកសំឡូត សព្វថ្ងៃនេះស្រុករតនៈមណ្ឌល។ តើត្រឹមត្រូវទេ?

**ឆៈ** ក្រោយឆ្នាំ១៩៧៥ គឺខ្ញុំឃើញមេបញ្ជាការកងពលនិងវរសេនាតូច វរសេនាធំអីហ្នឹង គឺតែងតែទៅជួបជុំប្រជុំទទួលផែនការនៅកន្លែងហ្នឹង។

**សៈ** សូមអរគុណ។ នៅពេលនេះសូមឲ្យលោកមើលអង្គការលេខតារាង ដ្យាក្រាមដែលខ្ញុំបានបង្ហាញលោកអម្បាញ់មិញ ហើយមូលដ្ឋានរបស់ រ៉េន នៅក្នុងហ្នឹងគេដាក់ថានៅប៉ៃលិន ហើយ ឿតនៅ<ក្រែង>។ ថាតើពួកគាត់ហ្នឹងមួយនៅប៉ៃលិន ហើយមួយទៀតនៅ<ក្រែង> ត្រឹមត្រូវដែរឬទេ?

**ឆៈ** ខ្ញុំចង់និយាយថា វរសេនាធំលេខប៉ុន្មានៗទៅនៅកន្លែងណាគឺខ្ញុំអត់ដឹងទេ ខ្ញុំដឹងតែកងពលលេខ២ហ្នឹងគឺឃើញរាយទ័ពនៅបាត់ដំបងផង នៅរោងចក្រស្ករសកំពង់គល់ផង នៅត្រែងផង នៅប៉ៃលិនផង។

**សៈ** ហើយតាមខ្ញុំយល់មិនខុសនោះទេ កងពលធំលេខ១ ឋិតនៅកន្លែងផ្សេងៗ ក៏នៅថ្មគោលផងដែរ នៅតាមបណ្ដោយផ្លូវជាតិលេខ៥។ តើត្រឹមត្រូវដែរឬទេ?

**ឆៈ** បាទ ត្រឹមត្រូវ។

[១៤:០៤:៥០]

**សៈ** ខ្ញុំមានសំណួរពាក់ព័ន្ធទៅនឹងទីតាំងភូមិសាស្ត្រចំនួនពីរ។ លោកសាក្សី តើលោកធ្លាប់បានឮកន្លែងមួយឈ្មោះថា "ផ្សារត្រែង" ដែរឬទេ?

**ឆៈ** ផ្សារត្រែង កាលសម័យមុន៧៥ កន្លែងនុំង គឺជាកន្លែងប្រជុំជនមួយមានផ្សារអ៊ីចឹងមែនដូចលោកបានថាអ៊ីចឹង។

**សៈ** ចាតើលោកដឹងទេ ថាកងពលលេខ១ ហើយនិង<កងពលលេខ>២នេះ ធ្លាប់បានទៅប្រជុំនៅផ្សារត្រែងដែរទេ?

**ឆ៖** តាមខ្ញុំដឹង គឺប្រជុំតាមវរៈ តាមកងពល គឺប្រជុំនៅៗបាត់ដំបងផង នៅត្រែងផង។ បាទ នេះបើតាមខ្ញុំដឹង ក៏ប៉ុន្តែទីបញ្ជាការធំរបស់សេនាធិការរបស់ភូមិភាគ គឺនៅបាត់ដំបងតែម្តង។

**ស៖** ហើយទីតាំងទី២ ដែលខ្ញុំចង់សួរ គឺភូមិស្តៅ។ តើលោកស្គាល់ទេ?

**ឆ៖** បាទ ស្គាល់។

**ស៖** តើលោកដឹងទេ គេធ្លាប់ទៅប្រជុំនៅភូមិស្តៅទេ?

**ឆ៖** ខ្ញុំមិនដឹងដែរកាលនុ៎ង ខ្ញុំដឹងតែកន្លែងទ័ពឈរជើងធំៗ។

[១៤:០៦:៥២]

**ស៖** បាទ សូមអរគុណ ហើយសំណួរមួយទៀត ទាក់ទងទៅនឹងទីតាំង វាយចាប ភ្នំវាយចាប។ តើលោកស្គាល់ទេ ហើយនៅកន្លែងណាដែរ?

**ឆ៖** បាទ ស្គាល់តើ ភ្នំវាយចាប។ សព្វថ្ងៃភ្នំវាយចាបស្ថិតក្នុងស្រុករតនមណ្ឌល ហើយក៏ជាទីតាំងដីរបស់កងពល ដែលយកភ្នំវាយចាបនេះជាសម្បត្តិរបស់រដ្ឋ បង្កើតជាកន្លែងកងហ្វឹកហ្វឺនសម្រាប់ទ័ព។

**ស៖** សូមអរគុណលោកសាក្សី។ នៅពេលនេះខ្ញុំសូមសួរលោកឈ្មោះ ហំ – តាហំ ដែលលោកទើបតែលើកឡើងអម្បាញ់មិញ។ តើគាត់ជាអ្នកណាដែរ? ហើយមានមុខងារអ្វីដែរ មុនឆ្នាំ៧៥ និងក្រោយឆ្នាំ៧៥?

**ឆ៖** មុនឆ្នាំ៧៥ ឈ្មោះ ហំ នេះគាត់នៅកាន់ខាងកងទ័ពតំបន់ ដល់ក្រោយមកយកគាត់មកចូលក្នុងកងទ័ពភាគ ហើយតួនាទីរបស់គាត់ គាត់គ្រប់គ្រងអនុប្រធានរបស់ តាខ្លែង ហ្នឹងតែម្តង។

[១៤:០៨:៥២]

**ស៖** តើ ហំ មានធ្វើការពាក់ព័ន្ធទៅនឹងភស្តុភារខាងភូមិភាគទេ គាត់មានមុខងារកាន់កាប់ខាងភស្តុភារភូមិភាគទេ?

**ឆ៖** គាត់មានមុខងារកាន់ខាងភស្តុភាររបស់យោធាភាគហ្នឹង។

**ស៖** ខ្ញុំចង់សួរអំពីមនុស្សម្នាក់ដែរ ប្រហែលជាគាត់ហ្នឹងដែរ លោកសាក្សី។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតសូមបង្ហាញរូបថតដូចគ្នាដែលមកពីវេបសាយ គេហទំព័រ អ.វ.ត .ក ហើយខ្ញុំបានបង្ហាញទៅសាក្សី<មុនមកពីភូមិភាគពាយ័ព្យ>ដែរ ដែលថាគាត់ហ្នឹងជាកងការពារ

របស់ រស់ ញឹម។ <ខ្ញុំជឿថា>រូបនេះ<បានចូលទៅក្នុងសំណុំរឿងហើយ គឺរូបថតដែល>បានភ្ជាប់ជាមួយនឹងសេចក្ដីព្រាងប្រតិចារឹក ថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៦។ ឈ្មោះបុគ្គលនេះ គឺលេខ <2-TCW-1036> ហើយត្រង់ម៉ោង១១:២៣។

**ចៅក្រម ក្លូឌា ហ្វេនស័៖**

ជាការពិត យើងមានឈ្មោះរហស្សនាម លេខសម្គាល់ហើយ <ប៉ុន្តែ-->

[១៤:១០:២៧]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ យើង<បាន>ផ្ទៀងផ្ទាត់<រួចហើយ ប៉ុន្តែយើងរកវាមិនឃើញនោះទេ។ ដូច្នេះ>សុំអនុញ្ញាតពីលោកប្រធាន។ លោកប្រធាន សូមចាក់នៅលើ អេក្រង់ផង។

**ចៅក្រម ក្លូឌា ហ្វេនស័៖**

អ៊ីចឹង គឺលោកបញ្ជាក់ថា វាភ្ជាប់ជាមួយនឹងប្រតិចារឹកផងដែរ ដើម្បីឲ្យយើងដឹងថាប្រតិចារឹកនៅថ្ងៃណា។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត ហើយប្រើខាងសោតទស្សន៍ ចាក់ផ្សាយរូបថតនេះនៅលើអេក្រង់ទូរទស្សន៍ តាមសំណើរបស់មេធាវីការពារក្ដី។ ហើយឯកសារនេះ ខ្ញុំសូមបញ្ជាក់ថា គឺឯកសារមានលេខ -- រូបថតនេះ គឺមានលេខ E3/10698។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកសូមមើលលើអេក្រង់ ហើយនិងរូបថត ដែលបញ្ចាំងលើអេក្រង់នេះ។ តើនេះ ជា ហំ ដែលលោកលើកឡើងឈ្មោះអម្បាញ់មិញហ្នឹង មែនដែរឬទេ?

[១៤:១១:៣១]

**2-TCW-1037៖**

**ឆ៖** មិនមែនទេ។

**ស៖** បាទ ជាចម្លើយដែលខ្ញុំមិន<រំពឹងទុក>។ ក៏ប៉ុន្តែខ្ញុំសូមសួរលោកអ៊ីចេះវិញ តើលោកស្គាល់ទេ អ្នកដែលនៅក្នុងរូបថតហ្នឹង?

**ឆ៖** ខ្ញុំអត់ស្គាល់។

**ស៖** តើ តាហំ ដែលលោកបានទើបតែលើកឡើងឈ្មោះអម្បាញ់មិញ ហើយនិងលើកឡើងឈ្មោះញ៉ឹកញាប់នៅក្នុងកំណត់ហេតុរបស់លោកផងដែរនោះ តើលោក<ស្គាល់>ទេ <បើគាត់នៅរស់ដល់>សព្វថ្ងៃ?

[១៤:១២:៤៥]

**ឆ៖** តាមខ្ញុំចាំបាន ដឹងព័ត៌មាន នៅក្នុងឆ្នាំ១៩៧៧ ចុងឆ្នាំ៧៧ហ្នឹង គឺ ឈ្មោះ ហំ ហ្នឹង ត្រូវបាន ប៉ុល ពត ចាប់ តែមិនដឹងយកទៅខាងណាទេ។

**ស៖** តើមានន័យថា លោកជឿជាក់ថា ហំ ហ្នឹងអត់នៅមានរស់រានមានជីវិតទៀតទេ មែនដែរឬទេ?

**ឆ៖** បាទ ខ្ញុំជឿថាមិននៅរស់ទេ។

**ស៖** ខ្ញុំព្យាយាមសួរមួយបែបផ្សេងវិញម្តង។ តើលោកស្គាល់បុគ្គលម្នាក់ឈ្មោះ ទាត់ ធឿន ទេ?

**ឆ៖** ទាត់ ធឿត ឬ ទាត់ ធឿន?

**ស៖** បាទ សំណួរល្អ--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

តើឲ្យសូមឲ្យខាងជាតិ អាចជួយប្រកបឈ្មោះឲ្យបានច្បាស់ទេ?

**លោក លីវ សុវណ្ណា៖**

គាត់ឈ្មោះ ទាត់ ធឿត។

[១៤:១៤:៥២]

**2-TCW-1037៖**

**ឆ៖** បាទ ទាត់ ធឿត ហ្នឹងនៅខាងខ្ញុំនោះគឺមានឈ្មោះ តែសព្វថ្ងៃគាត់ស្លាប់ហើយ ទាត់ ធឿត គាត់អ្នកធ្វើការងារធំដុំដែរ។ បាទ ហើយឥឡូវគាត់ទើបតែខូចបានប្រហែលជាមិនទាន់បានមួយឆ្នាំស្រួលបួលផង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ជាការពិតគឺអ៊ីចឹងមែន នេះប្រហែលជាស្លាប់ប៉ុន្មានខែមុនហ្នឹង។ តើ ទាត់ ធឿត ដែលលោកនិយាយអម្បាញ់មិញនេះ គាត់គឺជាឧត្តមសេនីយ៍នៅក្នុងជួរកងទ័ពសព្វថ្ងៃមែនដែរឬទេ?

**ឆ៖** បាទ អ៊ីចឹងមែន។

**សៈ** ដើម្បីឲ្យខ្ញុំយល់ឲ្យច្បាស់ រូបថត រូបមនុស្សដែលនៅក្នុងរូបថតៗហ្នឹងមិនមែន ទាត់ ធឿត ទេអ៊ីចឹងមែនដែរឬទេ? ប្រហែលជាខ្ញុំនេះ ខ្ញុំវិលដែរ ខ្ញុំអត់យល់អត់ច្បាស់ដែរ។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលើ៖**

អម្បាញ់មិញនេះ<នៅពេលយករូបថតមកសួរសាក្សី> គាត់សួរថា តើជា ហំ ដែលសាក្សីស្គាល់ដែរឬទេ? <ដូច្នេះ>គាត់ប្រហែលជាចង់បានចម្លើយផ្សេង<ពីថា នេះជា ទាត់ ធឿត>។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងរៀបចំសំណួរឡើងវិញ។

[១៤:១៦:២៩]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**សៈ** អ្នកដែលលោកឃើញនៅក្នុងរូបថតអម្បាញ់មិញ។ មិនមែន ទាត់ ធឿត ដែលជា -- ដែលធ្លាប់ជាឧត្តមសេនីយ៍នោះទេ តើត្រឹមត្រូវដែរឬទេ?

**2-TCW-1037៖**

**ឆៈ** រូបថតហ្នឹង?

**សៈ** ជាការត្រឹមត្រូវហើយ។

**ឆៈ** ខ្ញុំមើលប្រហាក់ប្រហែលដែរ ព្រោះ ទាន់ ធឿត ដែលខ្ញុំធ្លាប់ស្គាល់គឺរាងខ្មៅជាងនេះ តែមុខមាត់រាងប្រហាក់ប្រហែលហ្នឹង។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលើ៖**

ដើម្បីឲ្យប្រតិចារឹកច្បាស់ទាំងអស់គ្នា រូបថតនេះបង្ហាញនូវរូបបុគ្គលម្នាក់ដែលឈ្មោះលើកឡើងដោយមេធាវី។ ហើយបានកំណត់អត្តសញ្ញាណនៅពេលដែលចូលខ្លួននៅតុលាការកំពូល។ យើងមាននៅក្នុងកំណត់ហេតុរបស់តុលាការកំពូល។ គឺជាការពិតណាស់ បុគ្គលឈ្មោះហ្នឹងហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

<ពិតហើយ ប៉ុន្តែ>នៅក្នុងសក្ខីកម្ម<របស់គាត់>ហ្នឹង<>បញ្ជាក់ថា គាត់ឈ្មោះ ហំ ហើយ <អ្នកធ្វើការនៅសេនាធិការ ហើយ>ជាៗប្រធានខាងផ្នែកភស្តុភារ<>។ ប្រហែលជាយើងអាចមានស្ថានភាពមួយដែលថា<បុគ្គលនៅក្នុងរូបនេះបាននិយាយថា> គាត់<គឺ>ជា ហំ <ប៉ុន្តែជាការពិត គាត់គឺមិនមែនទេ។ នោះជាការបញ្ហា>។ ក៏ប៉ុន្តែខ្ញុំ<មិនមានពេលវេលាច្រើនទេ> ដូច្នេះហើយខ្ញុំសូមបន្តទៅ

មុខទៀត។ <វាមិនច្បាស់ទេ> ហើយខ្ញុំនឹងសួរបញ្ហាហ្នឹងឡើងវិញក្រោយពេលសម្រាក។ ដោយសារតែអ្វីដែលលោកឆ្លើយនេះ វាធ្វើឱ្យខ្ញុំនេះចង់សួរបញ្ជាក់លើចំណុចមួយចំនួនទៀត។

[១៤:១៨:២៣]

**ស៖** ខ្ញុំសូមសួរលើបុគ្គល ចំពោះបុគ្គលមួយទៀតដែលលោកបានលើកឡើងឈ្មោះ តាក្លែង។ គាត់ជាប្រធានខាងសេនាធិការ<យោធា>នៅខាងពាយ័ព្យមែនដែរឬទេ?

2-TCW-1037៖

**ឆ៖** បាទ មែន។

**ស៖** នៅក្នុងសក្ខីកម្ម ឬក៏កំណត់ហេតុសម្ភាសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាលោកបានលើកឡើងឈ្មោះ <តាវ៉ាញ>។ តើ <តាវ៉ាញ> ជានរណាដែរ?

**ឆ៖** ដូចជាមិនមែនឈ្មោះ តាវ៉ាន់ ទេ។

**ស៖** ប្រហែលជាខ្ញុំប្រកបឈ្មោះមិនត្រឹមត្រូវ ហើយខ្ញុំប្រកបឈ្មោះនេះមិនចំ។ លោកសាក្សីនៅក្នុងឯកសារ E3/10666, អង់គ្លេសគឺ 01330497 ហើយខ្ញុំជឿថាដូចជាមិនមានភាសាបារាំងទេ ERNហ្នឹង។ ហើយចំពោះខ្មែរ ERN ត្រង់លេខ 01326301 លោកបានលើកឡើងថា "នៅដើមឆ្នាំ៧៧ គេចាប់ <តាវ៉ាញ> ជាប្រធានខាងពាណិជ្ជកម្ម ហើយដោយសារគេចោទគាត់ថា<បំពាក់អាវុធឱ្យកងទ័ព>រើបកទៅលើអង្គការ។" ប្រហែលជាខ្ញុំប្រកបឈ្មោះមិនត្រឹមត្រូវ ប៉ុន្តែលោកនៅចាំទេ លោកបាននិយាយអំពីបុគ្គលម្នាក់ឈ្មោះ <តាវ៉ាញ>?

[១៤:២០:៤៤]

**ឆ៖** បាទ ខ្ញុំចាំបានតើ។ មិនមែនឈ្មោះ តាវ៉ាន់ ទេ ឈ្មោះ តាវ៉ាញ។

**ស៖** បាទ សូមអរគុណ។ តើគាត់ហ្នឹងគឺជាបុគ្គលតែមួយដែលលោកបានឆ្លើយនៅត្រង់ ERN ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា 01330517, ខ្មែរ 01326314 ដែលលោកបានលើកឡើងថា តាវ៉ាញ កាន់កាប់ខាងកងទ័ព ហើយនិងខាងតំបន់ផងដែរ។ តើជាបុគ្គលតែមួយ ឬក៏យ៉ាងម៉េចដែរ?

**ឆ៖** តាវ៉ាញ ហ្នឹង តាមខ្ញុំដឹងប្រវត្តិគាត់ មុនឆ្នាំរំដោះ ១៩៧៥ គាត់នៅគណៈតំបន់២។ គាត់អត់មានតួនាទីកាន់ទ័ពអីទេ។

**ស៖** បាទ ខ្ញុំសូមសួរមនុស្សពីរនាក់សំខាន់ពីរទៀតនៅខាងពាយ័ព្យ រស់ ញឹម ប្រធានខាងភូមិភាគពាយ័ព្យ។ លោកបានលើកឡើងថា តាញឹម គឺជាលេខាភូមិភាគ តើលោកស្គាល់គាត់ដោយផ្ទាល់ទេ

ហើយធ្លាប់ជួបគាត់ ឃើញគាត់ផ្ទាល់ទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់ឃើញគាត់ផ្ទាល់ ហើយធ្លាប់បានទៅរៀនបណ្តុះបណ្តាលផ្នែកអប់រំនយោបាយសតិអារម្មណ៍ចាត់តាំងអីនៅសាលានយោបាយជាមួយគាត់ម្តង ពីរដងដែរ។

[១៤:២៣:០៦]

**ស៖** ហើយសូមសួរសំណួរអមមួយទៀត។ តើក្រោយឆ្នាំ៧៥ លោកធ្លាប់ដែលឃើញរូបថតរស់ ញឹម ដែរឬទេ មិនថានៅកន្លែងណាទេ?

**ឆ៖** ខ្ញុំអត់ដែលឃើញទេ តាំងពីបែកពីគាត់ទៅថាគាត់ហ្នឹងត្រូវ ប៉ុល ពត បានធ្វើឃាតចាប់យកទៅសម្លាប់ហ្នឹង ក៏មិនដែលមានរូបថតអីបន្សល់ទុកនៅកន្លែងណា អត់ដែលឃើញ។

**ស៖** សូមអរគុណ។ សំណួរចុងក្រោយរបស់ខ្ញុំពាក់ព័ន្ធនឹងរចនាសម្ព័ន្ធនៅខាងភូមិភាគពាយ័ព្យ។ មានមនុស្សម្នាក់ទៀតដែលលោកនិយាយពីរបីដងដែរឈ្មោះគាត់ ហើយខ្ញុំសង្ឃឹមថាខ្ញុំប្រកបឈ្មោះហ្នឹងត្រឹមត្រូវ។ តា<ហេងទាវ> ហៅ តាប៉ែត តើលោកធ្លាប់ស្គាល់គាត់ទេ គាត់ជានរណាដែរ ហើយលោកធ្លាប់បានជួបគាត់ផ្ទាល់ដែរឬទេ?

**ឆ៖** បាទ ឈ្មោះហ្នឹងមិនមែន ហេង ទាប ទេ ហេង ទាវ។ បាទ តាប៉ែត ហ្នឹងហៅ ហេង ទាវ។ ខ្ញុំធ្លាប់ស្គាល់គាត់តាំងពីសម័យយើងនៅសង្គ្រាមមិនទាន់រំដោះឆ្នាំ១៩៧៥ម្ល៉េះ។

[១៤:២៤:៤៤]

**ស៖** សូមអរគុណ។ លោកសាក្សី ខ្ញុំសូមសួរអំពី តាហំ ឡើងវិញ។ នៅក្នុងសំណួរចម្លើយ២៨ត្រង់ឯក -- លើឯកសារE3/9580 ជាអនុប្រធានសេនាធិការ<យោធា>ភូមិភាគ បានន័យថាជាអនុរបស់ តាក្លែង។ លោកបានលើកឡើងឈ្មោះ តាហំ ថា តាហំ គេចាប់គាត់នៅឆ្នាំ៧៧ តើលោកដឹងមូលហេតុទេ ហេតុអ្វីគេចាប់គាត់?

**ឆ៖** បាទ តាមខ្ញុំដឹងខ្លះថា ថ្នាក់ដឹកនាំកម្មាភិបាលក្នុងជួរកងទ័ពរបស់ភាគហ្នឹងគឺ ជាខ្សែរយៈរបស់ សេ.អ៊ី.អា របស់ ឌឺ.បេ អាមេរិកាំងអីចឹងទៅ ហើយគេចោទប្រកាន់ករណីថាគាត់មានការឃុបឃិត ដឹកគ្រាប់រំសេវទៅ កាំភ្លើង គ្រាប់អីទៅលាក់ទុកសម្រាប់ធ្វើសកម្មភាពរើបកអីចឹង។ នេះតាមខ្ញុំក្តាប់បាន ពីមេភាគមួយចំនួនដែលនៅក្នុងជួរកងទ័ព។

**ស៖** សូមអរគុណ។ លោកសាក្សីនៅពេលនេះ ខ្ញុំសូមអាននូវចម្លើយដែលលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតពាក់ព័ន្ធទៅនឹងការចាប់ខ្លួន តាហំ។ ត្រង់ចម្លើយ សំណួរចម្លើយលេខ២៩ លោកលើក

ឡើងឆ្លើយដូចតទៅ៖ “តាហំ ក៏គេចាប់ដែរ គឺចាប់ក្នុងពេលជាមួយគ្នានោះ។ តាមខ្ញុំក្តាប់ព័ត៌មានគឺថា កងពលទាំងពីររបស់ភូមិភាគពាយ័ព្យគឺ មានផែនការចង់វាយបកទៅខាង ប៉ុល ពត តែត្រូវបែកការណ៍ ដោយសារតែមានភ្នាក់ងារពីមជ្ឈិមគេដឹងពីរឿងនេះ។ ដូចនេះហើយបានជាគេចាប់ខាងយោធា។ តាហំ គេចាប់ដោយសារគេចោទថា គាត់បានដឹកសម្ភារៈយោធាទៅទុកនៅភ្នំវាយចាប។ ហើយខ្ញុំដឹងរឿងនេះ នៅក្រោយឆ្នាំ១៩៧៩ ពីអ្នកដែលបើកឡានដឹកសម្ភារៈយោធានោះតែម្តង។ មានយោធាផ្សេងទៀត ប្រាប់ខ្ញុំថា គាត់បានឮ បានស្តាប់ឮពីមេៗគេប្រជុំគ្នា។ មានយោធាផ្សេងទៀតប្រាប់ខ្ញុំថា គាត់បានស្តាប់ឮពី មេៗគេប្រជុំ គ្នានិយាយថា ប្រសិនបើមិនធ្វើអ្វីពួកភូមិភាគពាយ័ព្យ ភូមិភាគនេះនឹងបះបោរដូចគ្នានឹងភូមិ ភាគបូព៌ាដែរ។” បញ្ចប់ការដកស្រង់សម្តីរបស់លោក។ តើចម្លើយនេះហើយ គឺជាចម្លើយដែលលោក ប្រាប់ខាងអ្នកស៊ើបអង្កេតរបស់ចៅក្រមស៊ើបអង្កេតនាពេលនេះ ហើយតើចំណុចនេះត្រឹមត្រូវដែរឬទេ?

[១៤:២៨:០៩]

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលើ៖**

<ខ្ញុំជំទាស់នឹងការសួរសំណួរនេះ។ វាជា>ប្រភេទសំណួរ<>ផ្សំគ្នា។ <លោកអាច>សួរ <គាត់>ថាតើ<នោះជាអ្វីដែលគាត់បានប្រាប់ពួកគេ ហើយបន្ទាប់មកលោកអាចសួរថាតើវា>ត្រឹមត្រូវ ដែរឬទេ ហើយចំពោះចំណុចហ្នឹង ដែលថាបើសិនសួរអ៊ីចឹង ធ្វើឲ្យចម្លើយឆ្លើយពីសាក្សីមានភាពច្របូក ច្របល់។

**លោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណ។ តើចម្លើយនេះ លោកធ្លាប់បាននិយាយប្រាប់ទៅអ្នកស៊ើបអង្កេតអ៊ីចឹងដែរ ឬទេ?

**ឆ៖** បាទ ចម្លើយនេះ ខ្ញុំបានឆ្លើយប្រាប់ទៅលើខាងស៊ើបអង្កេតអ៊ីចឹងមែន។

**ស៖** នៅពេលនេះ ខ្ញុំសួរចំណុចលម្អិតនៅក្នុងចម្លើយនេះ។ ដំបូងខ្ញុំសូមសួរសំណួរលោក ពាក់ព័ន្ធទៅនឹងអ្នកបើកឡាន ដែលលោកបានឆ្លើយថាក្រោយឆ្នាំ៧៩ អ្នកបើកឡានគាត់ប្រាប់ថា គាត់ដឹក សម្ភារៈយោធា<ពីតាហំ> ទៅទុកនៅភ្នំវាយចាប។ តើអ្នកបើកឡាននេះជានរណាដែរ?

**ឆ៖** បាទ អ្នកបើកឡានហ្នឹង តាមខ្ញុំដឹងគឺជាអ្នកដែលរស់នៅជាមួយគាត់ បាទ រស់នៅជាមួយ គាត់ផ្ទាល់ ជាតៃកុងឡានផង។ បាទ ហើយក៏ជាជំនិតនឹងគាត់ផ្ទាល់តែម្តង តែសព្វថ្ងៃនេះ គេបាត់មុខ បាត់មាត់យូរហើយ មិនដឹងជាទៅឯណា មកណាទេ អត់ដែលឃើញសោះ។

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

[១៤:៣០:០៥]

**ស៖** តើស្គាល់ឈ្មោះអ្នកបើកឡានហ្នឹងទេ?

**ឆ៖** អ្នកបើកឡានហ្នឹង គឺខ្ញុំស្គាល់។

**ស៖** តើលោកអាចប្រាប់ឈ្មោះ គាត់បានទេ?

**ឆ៖** ខ្ញុំអាចប្រាប់បាន ឈ្មោះ សាង តែ សាង ហ្នឹងគាត់ ដូចខ្ញុំបានប្រាប់អីចឹងថា គាត់បាត់មុខអត់ដែលឃើញទេ ក្រោយពី៧៩, ៨០គត់មក គឺបាត់មុខអត់ដែលឃើញទេ។ កាលនុ៎ង ខ្ញុំជួបគាត់នៅយើងភូមិស្នឹង ក្នុងស្រុកបាណន់ដែរ សព្វថ្ងៃនេះ។

**ស៖** នៅក្នុងចម្លើយដែលលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេត លោកបានលើកឡើងថាផែនការរបស់កងពលទាំងពីរនៅភូមិភាគពាយ័ព្យ ឲ្យវាយៗបកទៅខាង ប៉ុល ពត ត្រូវបែកការណ៍ ដោយសារតែមានភ្នាក់ងារពីមជ្ឈិមគេដឹងពីរឿងនេះ។ តើលោកអាចពន្យល់បន្ថែមត្រង់ចំណុចហ្នឹងបានដែរឬទេ? តើធ្វើដូចម្តេចទើបលោកដឹងថាផែនការហ្នឹងវាបែក? ហើយដោយសារតែមានភ្នាក់ងារហ្នឹងគេដឹង តើលោកអាចពន្យល់បន្ថែមទេ?

[១៤:៣១:៤០]

**ឆ៖** ត្រង់ចំណុចហ្នឹង ខ្ញុំសូមជម្រាបថា ខ្ញុំដឹងតាមរយៈរបស់កម្មាភិបាលដែលគេមកគ្រប់គ្រងនៅតំបន់ពាយ័ព្យហ្នឹង បាទ គេនៅក្នុងជួរជាប់ហ្នឹង គេថាបានព័ត៌មានពីនីរសារ តាញឹម ហ្នឹង ដែលមកធ្វើពី -- ធ្វើនីរសារ តាញឹម ហ្នឹង គាត់ គេថាគេបែកការណ៍ពីនីរសារតាញឹម ហ្នឹងរាយការណ៍ទៅមជ្ឈិមហ្នឹងបានជាគេមកបំផ្លាញផែនការហ្នឹងចោលទៅ។ គេចាប់បន្តបន្ទាប់ រហូតទាល់តែអស់ពីពាយ័ព្យហ្នឹងតែម្តង។

**ស៖** តើនីរសារ តាញឹម ហ្នឹងជាអ្នកណាដែរ?

**ឆ៖** អត់ស្គាល់នីរសារ តាញឹម ហ្នឹងគឺ ខ្ញុំមិនដែលបាននៅជាមួយ ឃើញតែទៅណានីរសារបួនប្រាំនាក់ទៅជាមួយ តែខ្ញុំមិនដែលទៅបាននៅជិតអី គ្រាន់តែធ្លាប់ស្គាល់គាត់ ហើយឃើញមុខគាត់ទៅរៀនសូត្រម្តងៗ។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរអីចេះវិញ <លោកបាននិយាយថា> លោកបានទទួលព័ត៌មានថា កងពលទាំងពីរហ្នឹង<មានផែនការ>ចង់វាយបកតបជាមួយ ប៉ុល ពត ប៉ុន្តែតើផែនការហ្នឹងៗ វាមានលក្ខណៈបែបណាដែរ? តើកងពលហ្នឹងមានគម្រោងធ្វើអ្វីដែរ? តើលោកដឹងទេថា កងពលទាំងពីរហ្នឹង

មានផែនការប្រុងធ្វើសកម្មភាពអ្វីដែរ ប្រឆាំងនឹង ប៉ុល ពត នោះ?

[១៤:៣៣:៤៦]

**ឆ៖** និយាយរួមត្រង់ព័ត៌មានហ្នឹង ចំណុចហ្នឹង ខ្ញុំក្រោយៗមកខ្ញុំដឹង ៗដែលគេប្រាប់ថា កងពលទាំងពីរមែនផែនការរៀបចំគម្រោងប្រុងវ៉ៃបក តែមិនទាន់មានគម្រោងអីឲ្យធំដុំ ឬក៏ខ្ញុំដឹងថា គេ -- វាមានខ្សែរយៈចាត់តាំងកម្លាំងបង្កប់យ៉ាងម៉េចអីយ៉ាងម៉េចទេ គឺវាអត់ទាន់មានទេ។ ពេលនុ៎ងឮថា ព័ត៌មានអ៊ីចឹងមក ក៏ឃើញគេចាប់រប៉ាត់រប៉ាយ បន្តបន្ទាប់តាំងពីពាយ័ព្យចាប់ពាយ័ព្យ និរតីចាប់ពាយ័ព្យអ៊ីចឹងមក បន្តបន្ទាប់គ្នាអ៊ីចឹងមក ក៏ឮព័ត៌មានហ្នឹងថា មកពីកម្លាំងកងពលទាំងពីរហ្នឹង ពីរកងពលហ្នឹងប្រុងធ្វើសកម្មភាពវ៉ៃបកមកលើ ប៉ុល ពត។ អ៊ីចឹងជាព័ត៌មានដែលខ្ញុំបានឮពីៗយោធាភូមិភាគ យោធាភាគហ្នឹងតែម្តង។

**ស៖** តើលោកចង់មានន័យបែបណាទៅពេលដែលលោកនិយាយថាកងទ័ពភូមិភាគ? តើអ្នកណាជាអ្នកផ្តល់ព័ត៌មាននេះប្រាប់លោក?

**ឆ៖** កម្លាំងទ័ព បាទ កម្លាំងទ័ពនៅក្នុងកងពលហ្នឹងដែលគេប្រាប់ខ្ញុំ។ គេថា រឿងហ្នឹងអ៊ីចឹងមែន បានគេចាប់អាដែងមេដឹកនាំអស់ គ្មានសល់។

**ស៖** តើលោកចាំឈ្មោះអ្នកដែលប្រាប់លោកទេ?

[១៤:៣៥:៤៣]

**ឆ៖** មិនអាចចាំបានទេ តុលាការ ព្រោះកាលនុ៎ងមនុស្សអ្នកនិយាយ វាទៅត្រង់នេះ វាឮគេថាអ៊ីចឹង ទៅត្រង់នោះឮគេថាអ៊ីចឹង។ វាមិនដឹងកំណត់ថាឈ្មោះណាអីឈ្មោះអ្នកណា។ ឥឡូវវាបាត់អស់ហើយ បាត់មនុស្សម្នាទៅណាមកណាអីអស់រលីងហើយ។ ហើយកាលនុ៎ង ក៏ចំណាស់ៗប្រហែលខ្ញុំហ្នឹង។ ហើយខ្ញុំអាយុហ្នឹង៦៦ហើយ។ អាខ្លះមិនដឹងទៅណាមកណា ងាប់អស់។ សល់ក៏តិចតួចណាស់។

**ស៖** ខ្ញុំយល់។ ប៉ុន្តែឥឡូវខ្ញុំសួរជាទូទៅអីចុះវិញ អ្នកដែលប្រាប់លោកអំពីផែនការដើម្បីវាយបកប្រឆាំង ប៉ុល ពត វិញនោះ តើពួកគាត់ជាសមាជិកនៅក្នុងកងពលលេខ១ លេខ២ ដែរទេ?

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ៗ។

**2-TCW-1037៖**

**ឆ៖** មិនមែនកម្លាំងនៅក្នុងជួរកងពលលេខ១ លេខ២ ហ្នឹងទេ គឺជាកម្លាំងចម្រុះរបស់កម្លាំងថ្មី

01385969



របស់ពីនិរតីទៅ គេនិយាយប្រាប់ខ្ញុំនៅពេលហ្នឹង។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ហើយនៅក្នុងចម្លើយដដែលហ្នឹង គឺលោក<និយាយអំពី សាន គឺ>អ្នកដឹកសម្ភារៈយោធាទៅភ្នំវាយចាប។ ប៉ុន្តែលោកក៏បានឆ្លើយផងដែរថា៖ “ទាហានមួយរូបទៀតប្រាប់ខ្ញុំថា បានឮមេដឹកនាំនិយាយនៅក្នុងការប្រជុំ គឺថា<បើ>មិនមានអ្វី<បានធ្វើចំពោះក្រុម>ខាងពាយ័ព្យទេ គឺ<ថាភូមិភាគនេះអាចនឹងធ្វើការបះបោរដូច>ខាងបូព៌ា<>។” តើទាហាន<ម្នាក់នេះ>ដែលស្តាប់ឮមេភូមិភាគពាយ័ព្យ<>និយាយ<ថា ភូមិភាគនេះអាចនឹងធ្វើការបះបោរដូចភូមិភាគ>បូព៌ាហ្នឹង<ជានរណា>?

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលើ៖**

គឺថាសំណួរគឺគាត់លើកដោយមិនត្រឹមត្រូវទេ គឺថាគាត់អានមកត្រឹមត្រូវ ក៏ប៉ុន្តែគាត់មិននិយាយថា គាត់ឮមេបញ្ជាការពាយ័ព្យ<ពិភាក្សាគ្នាអំពីរឿង>នោះទេ គឺគាត់<ថា គាត់>បានឮ<មេដឹកនាំ។ “បើមិនមានអ្វីបានធ្វើចំពោះក្រុមពាយ័ព្យទេ ភូមិភាគនេះអាចនឹងបះបោរ” -- សូមទោស -- > “ទាហានមួយរូបទៀតប្រាប់ខ្ញុំថាឮមេបញ្ជាការ មេដឹកនាំ--”

[១៤:៣៨:៣៤]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំនឹងសួរឡើងវិញ។ ឥឡូវនេះខ្ញុំនឹងអានអ្វីដែលលោកនិយាយឲ្យច្បាស់តែម្តង៖ “ទាហានម្នាក់ទៀតបានប្រាប់ខ្ញុំថាបានឮ<មេដឹកនាំ>និយាយនៅក្នុងការប្រជុំថា <បើ>មិនមាន<បានធ្វើចំពោះ>ក្រុមពាយ័ព្យ<ទេ ភូមិភាគនេះអាចនឹងបះបោរដូចភូមិភាគ>បូព៌ា<>”។ ដូច្នេះខ្ញុំចង់សួរថា តើទាហានរូបណាដែលប្រាប់លោកអំពីព័ត៌មាននេះ?

**2-TCW-1037៖**

**ឆ៖** ចម្លើយកន្លែងហ្នឹង ខ្ញុំដូចរាងភ្លេចហើយ។

**ស៖** មិនអីទេលោកសាក្សី។ ឥឡូវនេះខ្ញុំសូមសួរលោកបន្តទៅទៀត ហើយខ្ញុំនឹងនិយាយអំពីអ្វីដែលលោកបានឆ្លើយ<ជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា>នៅក្នុងឯកសារ E3/10666, អង់គ្លេសមានលេខ 01330557, ហើយខ្មែរមានលេខ 01326340។ គេសួរលោកថា៖ “តាមដែលលោកដឹង គេចាប់ខ្លួន វ៉ាញ ហ្នឹង តើគាត់មានបានរៀបចំអាវុធដើម្បីប្រឆាំងអង្គការទេ? ឆ្លើយ៖ ខ្ញុំអត់ដឹងទេ ប៉ុន្តែខ្ញុំបានឮអ្នកធ្វើការជាមួយខ្ញុំប្រាប់ខ្ញុំថាគាត់<បានបំពាក់>អាវុធ<ឲ្យកងកម្លាំងគាត់ដោយ>ខុសច្បាប់

ហើយគាត់ផ្លាស់ទី ហើយនិងដឹកជញ្ជូនទាហានដោយមិនត្រឹមត្រូវ គាត់<លាក់>អាវុធ<ជាមួយ>កងចល័តដើម្បីវាយប្រហារ។" សូមបញ្ចប់ការដកស្រង់។ លោកសាក្សី តើអ្នកធ្វើការជាមួយលោកណាម្នាក់ដែលប្រាប់លោកថា តាវ៉ាញ <បំពាក់>អាវុធ<ដល់កងកម្លាំងគាត់ដោយ>ខុសច្បាប់?

[១៤:៤០:៥២]

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

លោកប្រធាន ឥឡូវនេះគាត់និយាយអំពីបុគ្គលម្នាក់ទៀត ដូច្នេះគាត់គួរតែសួរជាសំណួរបើក ព្រោះវាជាបុគ្គលថ្មីដែលយើង ដែលចាំបាច់គួរតែសួរជាសំណួរបើក។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំគិតថាប្រហែលជាយើងកំពុងតែជជែកប្រធានបទដូចគ្នាមើលទៅ។ វាជាសំណួរបើកមែនទេ ខ្ញុំគ្រាន់តែអានទូវចម្លើយរបស់គាត់ ហើយខ្ញុំសួរថាតើសហការីរបស់គាត់ហ្នឹងជានរណា? ខ្ញុំកំពុងតែអានហើយ ហើយខ្ញុំគិតថាយើងកំពុងជជែកពីប្រធានបទដូចគ្នា។ ខ្ញុំគ្រាន់តែសួរថាតើសហការីរបស់គាត់ហ្នឹងជាអ្នកណា ដែល<ប្រាប់គាត់ថា វ៉ាញ> ហ្នឹង<បំពាក់អាវុធឲ្យ>កងកម្លាំង<គាត់ដោយ> ខុសច្បាប់<នោះ ដូច្នេះនេះជាសំណួរបើកហើយ>។ <>លោកសាក្សី ថាតើអ្នកណាប្រាប់លោកអំពីបញ្ហារបស់ <វ៉ាញ> នេះ?

**ប្រធានអង្គជំនុំ៖**

តើលោកអាចឆ្លើយបានហើយសំណួរហ្នឹង ហើយឈ្មោះ វ៉ាញ មិនមែន វ៉ាន ទេណា។

[១៤:៤២:០៤]

**2-TCW-1037៖**

**ឆ៖** បាទ ឈ្មោះ វ៉ាញ អ៊ីចឹងមែន មិនមែនឈ្មោះ វ៉ាន ទេ។ គឺឈ្មោះគាត់ឈ្មោះ វ៉ាញ។ វ៉ាញហ្នឹងគឺកាលនៅសង្គ្រាម មុនឆ្នាំ១៩៧៥ គាត់ជាគណៈតំបន់។ បាទ ដល់ក្រោយមកគឺខាងភាគហ្នឹងចាត់តាំងឲ្យគាត់មកគ្រប់គ្រងនៅទំនប់កង្ហូត អតីតទំនប់កង្ហូតសព្វថ្ងៃនេះ ក៏ឈ្មោះទំនប់កង្ហូតដែរ ប៉ុនខុសទីតាំងគ្នាបាទ ហើយកាលហ្នឹងធ្វើដោយកម្លាំងពលកម្ម ងាប់មនុស្សរាប់ៗរយរាប់ពាន់នាក់។ បាទ ហើយកម្លាំងចល័តរាប់ពាន់រាប់ម៉ឺននាក់ទៅធ្វើនៅកន្លែងហ្នឹង។ អ៊ីចឹងធ្វើទៅវាបរាជ័យ បាក់ទំនប់ បាក់អីម្តងពីរដងអ៊ីចឹង។

**ប្រធានអង្គជំនុំ៖**

មិនៗត្រូវនឹងសំណួរទេ ចាំស្តាប់សំណួរ។ ឥឡូវលោកមេធាវីសួរសំណួរគាត់សាជាថ្មីឡើងវិញ គាត់ច្រឡំហើយ ខ្ញុំបញ្ជាក់រឿងឈ្មោះ វ៉ាញ ឬមិនមែនឈ្មោះ វ៉ាន ទេ ដើម្បីកុំឲ្យលោកច្រឡំសំណួរ បុគ្គលដែលពាក់ព័ន្ធនឹងសំណួរនេះ។ គោលបំណងនៃការសួររបស់លោកមេធាវី មិនមែនសួរឲ្យលោកឆ្លើយពាក់ព័ន្ធជាមួយនឹងទំនប់ ឬក៏ កន្ទី កង្កួតនោះទេ ណ៎ះ!

[១៤:៤៣:៣៣]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមអរគុណ ចំពោះការជួយអន្តរាគមន៍លោកប្រធាន។ ខ្ញុំសួរសំណួរងាយទេ ខ្ញុំចង់សួរថា តើសហការីមួយណាដែលប្រាប់លោកអំពីឈ្មោះ វ៉ាញ ដែលថា វ៉ាញ ហ្នឹងរើសទ័ពដោយខុសច្បាប់ហ្នឹង តើអ្នកណាជាអ្នកប្រាប់លោក?

**2-TCW-1037៖**

**ឆ៖** បាទ អ្នកដែលប្រាប់ហ្នឹង គឺគេចាប់យកទៅបាត់ហើយ។ ឈ្មោះ តាស៊ុម ហ្នឹងគាត់ប្រាប់ខ្ញុំថា តាវ៉ាញ ហ្នឹងគេចាប់ហ្នឹង។ ដោយសារ តាវ៉ាញ ហ្នឹងគាត់បង្កើតកម្លាំងខុសច្បាប់មានអាវុធមានអីបំពាក់ឲ្យកងចល័ត។

**ប្រធានអង្គជំនុំ៖**

បាទៗអរគុណៗ។

បាទ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងអញ្ជើញគាត់ព្រមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះ នៅវេលាម៉ោងបី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៤ នាទី ដល់ម៉ោង ១៥:០៥ នាទី)*

[១៥:០៥:១០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយមុននឹងផ្តល់វេទិកាជូនទៅមេធាវីការពារក្តី អង្គជំនុំជម្រះសូមសួរទៅតំណាងសហព្រះរាជអាជ្ញាថា តើមានសំណើសុំអ្វីដែលមានបំណងលើកឡើងនូវសំណើសុំអ្វីដែលពាក់ព័ន្ធជាមួយនឹងដីកាសម្រេចផ្ទាល់មាត់កាលពីព្រឹកមិញដែរទេ?

**កញ្ញា សុង ឆវ័ន្ត៖**

សូមជម្រាបសួរលោកប្រធាន សូមអរគុណលោកប្រធាន។ ពាក់ព័ន្ធទៅនឹងដីកាសម្រេចផ្ទាល់មាត់លើឯកសារ E445/1 កាលពីព្រឹកមិញនេះ នៅក្នុងឯកសារដែលអង្គជំនុំជម្រះសម្រេចទទួលយកនិក្ខេបបទរបស់អ្នកជំនាញដែលនឹងមកផ្តល់សក្ខីកម្មនៅពេលខាងមុខនេះ គឺអ្នកជំនាញដែលមានរហស្សនាម TCE-98។ នៅក្នុងនិក្ខេបបទរបស់អ្នកជំនាញនៅត្រង់ទំព័រ ERN ជាភាសាអង់គ្លេស គឺដែលមានលេខ 01335031 អ្នកជំនាញធ្លាប់បានធ្វើការសម្ភាសជាមួយនឹងអតីតមហាក្សត្រ នរោត្តម សីហនុ និង អៀង សារី នៅក្នុងឆ្នាំ១៩៨៣ និង ១៩៨៥ ដែលនៅក្នុងកិច្ចសម្ភាសន៍នោះមានការកត់ត្រាដោយផ្ទាល់ដៃរបស់អ្នកជំនាញនៅក្នុងអំឡុងពេលសម្ភាស។ ហេតុដូច្នេះហើយសហព្រះរាជអាជ្ញាស្នើសុំឱ្យអង្គជំនុំជម្រះប្រាប់ទៅអ្នកជំនាញ ប្រសិនបើគាត់នៅមានឯកសារដែលជាកំណត់ត្រាផ្ទាល់ដៃនៅក្នុងអំឡុងពេលសម្ភាសនោះ ឱ្យគាត់ជួយយកមកនៅក្នុងពេលសវនាការផង ដោយសារសហព្រះរាជអាជ្ញាគិតថាប្រហែលជាកំណត់ត្រានោះមានផ្ទុកនូវព័ត៌មានសំខាន់ចំបាច់មួយចំនួន ដើម្បីជាភស្តុតាងសម្រាប់ស្វែងរកការពិតនៅក្នុងរឿងក្តីនេះ។

[១៥:០៧:១១]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយពាក់ព័ន្ធនឹង--

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំសូមសួរបញ្ជាក់ ខ្ញុំទើបតែស្តាប់ឮនាពេលនេះ។ តើខាងសហព្រះរាជអាជ្ញាចង់បានន័យថាចំណុចទី១ ការសម្ភាស ឬក៏កំណត់ហេតុសម្ភាសនោះ គឺជាប្រភពនៃនិក្ខេបបទរបស់គាត់ ឬក៏យ៉ាងម៉េចឬក៏ចំណុចហ្នឹងមានលើកឡើងនៅក្នុងឯកសារណាមួយបញ្ជាក់ត្រង់ចំណុចហ្នឹងដែរឬទេ?

**កញ្ញា សុង ឆវ័ន្ត៖**

ឆ្លើយតបទៅនឹងសំណួររបស់ចៅក្រម ហ្វេនស៍ យើងខ្ញុំមិនទាន់បានច្បាស់ថា តើកិច្ចសម្ភាសន៍ដែលគាត់ធ្វើនេះជាប្រភពឯកសារចាំបាច់នៅក្នុងការសរសេរនិក្ខេបបទគាត់ ឬក៏អត់នោះទេ។ ប៉ុន្តែនៅ

ក្នុងសៀវភៅដែលអ្នកនិពន្ធបានសរសេរឡើង ដោយមានឯកសារ ដែលមានលេខសម្គាល់ឯកសារ E445/1.1.1 នៅត្រង់ ERN ជាភាសាអង់គ្លេសហ្នឹង គឺមានលេខ 01335031 អ្នកនិពន្ធដែលជាអ្នកជំនាញនោះបាននិយាយទៅដល់កិច្ចសម្ភាសន៍មួយដែលគាត់ធ្លាប់ធ្វើជាមួយនឹងអតីតព្រះមហាក្សត្រ នរោត្តម សីហនុ និង លោក អៀង សារី នៅក្នុងកាលវិភាគពីរផ្សេងគ្នា។ ហើយគាត់បាននិយាយថា គាត់មានកំណត់ត្រានៅក្នុងអំឡុងពេលសម្ភាសនោះនៅផ្នែក ERN ដែលខ្ញុំបានលើកបង្ហាញមុននោះ។ អ៊ីចឹងហើយ យើងគិតថាប្រហែលជាកំណត់ត្រានោះមានផ្ទុកនូវព័ត៌មានសំខាន់មួយចំនួនដែលយើងអាចនឹងសាកសួរនៅពេលដែលគាត់មកផ្តល់សក្ខីកម្ម។

[១៥:០៨:៤៦]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងបានន័យថា ឥឡូវលោកស្រី -- កញ្ញាលើកឡើងថា វាជាប្រភពនៃឯកសារ<ដែលបានដាក់ចូលក្នុងសំណុំរឿង តើខ្ញុំយល់ត្រឹមត្រូវទេ ចំណារសរសេរដោយដៃនោះ?>។ សំណួរទី២ អ្នកជំនាញ <បានមកដល់ក្នុងប្រទេសនេះរួចហើយ> ឧទាហរណ៍ថា កំណត់ហេតុគាត់នៅទីនេះ អ៊ីចឹងថា តើមានបំណងចង់បង្ហាញឯកសារហ្នឹងទៅភាគី ឬក៏ចង់ផ្តោតជាមូលដ្ឋាននៅពេលសួរសំណួរ? អ្នកជំនាញហ្នឹងនឹងមកនៅទីនេះនៅថ្ងៃស្អែកហើយ។

**កញ្ញា សុង ឆវ័ន្ត៖**

ពួកយើងខ្ញុំកំពុងតែរៀបចំនូវសំណួរលម្អិតពាក់ព័ន្ធទៅនឹងបញ្ហានេះ គ្រាន់តែនៅក្នុងអំឡុងពេលបច្ចុប្បន្ននេះ យើងស្នើសុំឱ្យគាត់យកឯកសារដែលជាកំណត់ត្រាហ្នឹងភ្ជាប់មកជាមួយនៅក្នុងពេលសវនាការ។ យើងអាចនឹងសួរគាត់ទៅដល់ការសម្ភាសដែលគាត់បានធ្វើជាមួយនឹងអតីតព្រះមហាក្សត្រ និង លោក អៀង សារី នៅក្នុងអំឡុងពេលនៃកិច្ចសម្ភាសន៍ហ្នឹង ដោយសារតែវាជាកំណត់ត្រាផ្ទាល់ដៃនៅក្នុងអំឡុងពេលសម្ភាស។

[១៥:០៩:៤៨]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ដូច្នេះដើម្បីជួយឱ្យអ្នកជំនាញនេះគាត់នឹកឃើញ <ក្នុងករណីចាំបាច់> នៅពេលដែល<ចូលដល់ការសម្ភាស ដែលត្រូវបានបញ្ជាក់នៅក្នុងការបោះពុម្ពផ្សាយមួយរបស់>គាត់ <ដែលយើងបាន>បញ្ចូលជាភស្តុតាង<រួចហើយ>។ តើនេះជាហេតុផលស្នើសុំមកយកមកជាមួយ ឬក៏យ៉ាងម៉េចដែរ?

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**កញ្ញា សុង ឆវ័ន្ត៖**

ចាស វាជាផ្នែកមួយដែរដើម្បីជួយដល់ការចងចាំរបស់អ្នកជំនាញ ក៏ដូចជានៅក្នុងអំឡុងពេលណាមួយនៃការសួរសំណួរហ្នឹងលេចឡើងនូវភស្តុតាង ដែលមានទំនាក់ទំនងទៅនឹងអង្គហេតុដែលយើងអាចនឹងសួរនៅពេលអ្នកជំនាញមកផ្តល់សក្ខីកម្មនោះ។

**ប្រធានអង្គជំនុំ៖**

ចុះភាគីដទៃទៀតមានមតិយោបល់អ្វីទេលើសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញាបានលើកឡើងអម្បាញ់មិញនេះ?

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន ខាងមេធាវីនាំមុខមិនមានមតិចំពោះបញ្ហានេះទេ ទុកជូនអង្គជំនុំជម្រះជាអ្នកពិចារណាលើការទទួលយកសំណើនេះ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះក្រុមមេធាវីការពារក្តីយ៉ាងម៉េចដែរសំណើសុំរបស់សហព្រះរាជអាជ្ញា?

[១៥:១១:០៦]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមានលោកប្រធាន។ ខ្ញុំយល់មិនច្បាស់ ខ្ញុំតាមអត់ទាន់សំណើសុំពីខាងតំណាងសហព្រះរាជអាជ្ញា។ ហេតុអ្វីទើបតែដាក់សំណើសុំនាពេលនេះ? ដោយសារតែនិក្ខេបបទ ប្រសិនជាខ្ញុំចាំមិនខុសទេនៅចាំនោះគឺនិក្ខេបបទនេះត្រូវបានសរសេរ និងការពារនៅឆ្នាំ៨៥ <និង> ៨៦។ សៀវភៅរបស់អ្នកជំនាញ ហើយខ្ញុំមិនប្រាកដទេ ខ្ញុំត្រូវយកមកពិនិត្យមើលឡើងវិញ គឺ<សៀវភៅរបស់គាត់ គឺនៅក្នុង>ឆ្នាំ ៩៩ <ហើយគាត់ក៏បានយោងទៅលើកិច្ច>សម្ភាសន៍ជាមួយនឹងសម្តេច សីហនុ រួមជាមួយនឹង អៀង សារី។ <ដូច្នេះសៀវភៅរបស់គាត់ គឺបានធ្វើការបន្ថែមចំណុចមួយចំនួនពីលើនិក្ខេបបទរបស់គាត់។ ដូច្នេះ បើមានមធ្យោបាយផ្សេងទៀតជុំវិញបញ្ហានេះ នោះខ្ញុំនឹងអាចឃើញភាពសមហេតុផលនៅក្នុងនោះ។ ប៉ុន្តែពេលនេះការស្នើសុំកំណត់ហេតុគឺវាយឺតពេលខ្លាំងណាស់ ព្រោះថាកំណត់ហេតុនៃកិច្ចសម្ភាសន៍ទាំងនោះក៏បានយោងនៅក្នុង>សៀវភៅរបស់អ្នកជំនាញ <រួចហើយ។> ហើយខ្ញុំ<ប្រាកដណាស់ប៉ុន្តែខ្ញុំ>ត្រូវ<តែពិនិត្យ>សៀវភៅរបស់គាត់ដែលគាត់<>ឡើងវិញដើម្បីឲ្យច្បាស់ទៅលើចំណុចហ្នឹង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អ្វីដែលថ្មី អ្វីដែលចាប់អារម្មណ៍នៅក្នុងសៀវភៅរបស់គាត់ គឺ<>កំណត់ត្រាដែលគាត់យកមកចេញពីបណ្ណសាររបស់បណ្ណសារដ្ឋានរបស់រុស្ស៊ី <នេះជាអ្វីដែលថ្មី>។ ហើយចំពោះសម្ភាសជាមួយនឹងអៀង សារី និងព្រះបរមរតនកោដ្ឋសីហនុ<ដែលមាននៅក្នុងនិក្ខេបបទរបស់គាត់ ក៏យោងទៅនឹងសៀវភៅរបស់គាត់ដែលបោះពុម្ពឆ្នាំ១៩៩៩>នោះ<ដែរ> គឺខ្ញុំហាក់ដូចជាគិតថាសំណើសុំនេះ ដូចជាអត់មានលក្ខណៈសមហេតុផលនោះទេ<>។

[១៥:១២:៥៤]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<វាមិនមែន ដោយសារវាត្រូវបានរៀបចំដាក់សំណើ> យោងតាមវិធាន៨៧(៤)នោះ<ទេ> ដូច្នេះហើយទើបខ្ញុំសួរបញ្ជាក់អម្បាញ់មិញ។ <បើសិនវាគ្រាន់តែជាប្រភេទដើម្បីបញ្ជាក់ថាអ្នកជំនាញ> ចងចាំ<លម្អិតនូវកិច្ចសម្ភាសន៍ដែលសហព្រះរាជអាជ្ញាចង់ពិភាក្សានោះទេ នោះវាជាបញ្ហាមួយផ្សេង ប៉ុន្តែនេះជាអ្វីដែលខ្ញុំព្យាយាម>បញ្ជាក់បំភ្លឺអម្បាញ់មិញនេះ។ យ៉ាងណាក៏ដោយអ្វីដែលលោកលើកឡើងបានចូលក្នុងប្រតិចារឹករួចរាល់ហើយ។

**កញ្ញា អង់តា ហ្គីសសេ៖**

ក្នុងពេលឥឡូវនេះ លោកប្រធាន ខ្ញុំ អ្វីដែលខ្ញុំអាចធ្វើបាននោះ គឺៗខ្ញុំគ្រាន់តែចាំចម្លើយរបស់អ្នកជំនាញសុទ្ធនោះទេ ហើយយើងសុំឯកសារគាត់ ហើយគាត់មកដល់ស្រុកខ្មែរហើយនេះ។ <យើងសុំឱ្យអ្នកជំនាញផ្តល់ឯកសារ ដោយសារ>យើងក៏មិនដឹងថាព្រះរាជអាជ្ញាហ្នឹងសួរគាត់លើចំណុចអ្វី ហើយមិនដឹងថាឯកសារដែលគាត់សុំហ្នឹងអាចបង្ហាញការពិតបានឬក៏អត់នោះទេ។ អ៊ីចឹងបើយើងអាចធ្វើដូចពេលកន្លងមកទៅ <បើ>យើងស្តាប់ព្រះរាជអាជ្ញាសួរ<ហើយយើងឃើញថាវាមានប្រយោជន៍ ដើម្បីធ្វើការកត់សម្គាល់បន្ថែមពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់អ្នកជំនាញ នោះយើងនឹងអាចធ្វើសំណើសុំនៅពេលនោះ។ ខ្ញុំនឹងត្រៀមការកត់សម្គាល់របស់ខ្ញុំសម្រាប់ពេលនេះ។ វាហាក់ដូច>ជាយឺតពេលបន្តិច <ឬ>វាឆាប់ពេក <ក្នុងការធ្វើសំណើនៅពេលនេះ>។

[១៥:១៤:១៥]

**លោក វ៉ិចទ័រ កូប៉េ៖**

លោកប្រធាន ប្រសិនបើអនុញ្ញាត នៅពេលនេះ ខ្ញុំបានរកឃើញទំព័រ ERN ពាក់ព័ន្ធនៅក្នុងសៀវភៅរបស់<ម៉័ររីស>និពន្ធឆ្នាំ៩៩ <E3/9338>, <01001662> គឺនៅក្នុងនោះមានកិច្ចសម្ភាសន៍

ជាមួយនឹងព្រះបរមរតនកោដ្ឋសីហនុ ហើយសំណើសុំរបស់តំណាងសហព្រះរាជអាជ្ញា អត់មានមូលដ្ឋាននោះទេ លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះនឹងយកបញ្ហានេះទៅពិចារណា និងចេញសេចក្តីសម្រេចឆាប់ៗលើសំណើនេះ។

បាទតទៅនេះ ផ្តល់វេទិកាជូនទៅមេធាវីការពារក្តីដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

[១៥:១៥:០២]

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសង្ឃឹមថានឹងបន្ថែមពេលវេលា១៥ <ឬ២០>នាទីឲ្យមកយើងខ្ញុំដោយសារតែយើងបាត់បង់។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** មុនពេលសម្រាក លោកសាក្សី លោកបានលើកឡើងអំពីមនុស្សដែលគេប្រាប់អំពីឈ្មោះតាវ៉ាញ <ហើយលោកហៅគាត់ថា ស៊ុម។> តើអ្នកដែលប្រាប់លោកនោះ គឺជាមនុស្សតែមួយនៅក្នុងសៀវភៅ ក្នុងកំណត់ហេតុរបស់លោក ត្រង់<ចម្លើយ>លេខ២ នៅក្នុងឯកសារ E3/9580 ដែលលោកលើកឡើងថា៖ "នៅខែមីនា ឆ្នាំ៧៨ <ប្រធានកងរបស់ខ្ញុំ>គឺ ស៊ុម ត្រូវបានចាប់ខ្លួន។ <នៅពេលនោះខ្ញុំជាអនុរបស់គាត់>។ តើ ស៊ុម ហ្នឹងជាអ្នកប្រាប់លោកអំពី វ៉ាញ ដែលគាត់រៀបចំអាវុធ តើជាបុគ្គលហ្នឹងហើយដែលប្រាប់លោកអំពី វ៉ាញ ហ្នឹងមែនដែរឬទេ?

**2-TCW-1037៖**

**ឆ៖** បាទ បុគ្គលហ្នឹង។

[១៥:១៦:១៨]

**ស៖** តើ ស៊ុម មានបានប្រាប់លោកទេ តើគាត់ដឹងថា វ៉ាញ បំពាក់អាវុធទៅដល់កងទ័ពរបស់គាត់នោះ ដោយខុសច្បាប់នោះ តាមមធ្យោបាយណា ដោយរបៀបណាដែរ ដើម្បីធ្វើការវាយតប? តើ ស៊ុម ហ្នឹងដឹងថា វ៉ាញ ហ្នឹងរៀបចំបំពាក់អាវុធហ្នឹង ដោយរបៀបណាទៅ ដឹងពីប្រភពណាទៅ?

**ឆ៖** បាទ ចំណុចហ្នឹងខ្ញុំមិនដឹងថារបៀបណាទេ ព្រោះគាត់បាននិយាយអ៊ីចឹងក្រោយពេលដែល

គេចាប់ឈ្មោះ វ៉ាញ ហ្នឹងទៅហើយ។

**ស៖** តើលោកនៅនឹកឃើញចំណុចលម្អិតដែល ស៊ុម ប្រាប់លោកទេ តើគាត់បានប្រាប់លោកលម្អិតអ្វីខ្លះអំពីសកម្មភាពរបស់ វ៉ាញ ហ្នឹង?

**ឆ៖** តាមខ្ញុំដឹង ពីសកម្មភាពដូចបានជម្រាបខាងដើមអ៊ីចឹងថា ហេតុផលដែលគេចាប់គាត់ហ្នឹង គឺមូលហេតុថាគាត់ហ្នឹងបានរួមដៃ រួមជើងជាមួយក្រុមចលាចល ហើយបំពាក់អាវុធឲ្យចលាចល អ៊ីចឹងកម្លាំងបង្កប់នៅក្នុងហ្នឹងគេរកឃើញ ថាវាជារឿងខុសច្បាប់។

**ស៖** ខ្ញុំមិនចង់សួរលោក ការចោទប្រកាន់ទៅលើគាត់នោះទេ ក៏ប៉ុន្តែខ្ញុំចង់ដឹងនោះ ស៊ុម គាត់ប្រាប់លោក ថាគាត់ដឹងអំពី វ៉ាញ ហ្នឹង សកម្មភាពរបស់ វ៉ាញ<ធ្វើអ្វី>។ តាម<រយៈការសង្កេតផ្ទាល់ខ្លួនគាត់ តើ> វ៉ាញ ពាក់ព័ន្ធនឹងសកម្មភាពអ្វីខ្លះ?

[១៥:១៨:១៩]

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

<ខ្ញុំជំទាស់នឹងសំណួរនេះ ព្រោះ>សាក្សីបានប្រាប់ហើយថា គាត់មិនបានដឹង ស៊ុម ហ្នឹងព័ត៌មានហ្នឹងមកពីណានោះទេ។ ដូច្នេះបើសិនជាសួរឲ្យសាក្សីប្រាប់ថា តាមការសង្កេតរបស់គាត់ហ្នឹង ស៊ុម ហ្នឹងគាត់ប្រាប់យ៉ាងម៉េច នៅពេលនោះ ថាដឹងសកម្មភាពហ្នឹងយ៉ាងម៉េចនោះ គឺជាការសួរមួយដែលហួសពីការដឹងឮរបស់សាក្សីរូបនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមរៀបចំសំណួរឡើងវិញ ខ្ញុំតាមអត់ទាន់ទេអ្វីដែលលើកឡើងដោយខាងសហព្រះរាជអាជ្ញា។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សំណួរដែលខ្ញុំចង់សួរទៅកាន់លោក គឺព័ត៌មានលម្អិត <ថាតើ វ៉ាញ គាត់បានធ្វើអ្វី បើតាម> ស៊ុម ប្រាប់លោក? <>តើ ស៊ុម មានប្រាប់អំពីទីតាំងលាក់អាវុធដែរឬទេ? អ៊ីចឹងសូមលោកជួយពន្យល់លម្អិតមើល តើ ស៊ុម ហ្នឹងបាននិយាយអ្វីខ្លះអំពី<អ្វីដែល> វ៉ាញ <បានធ្វើ>នោះ?

[១៥:១៩:២២]

**2-TCW-1037៖**

**ឆ៖** បាទ កន្លែងហ្នឹង គឺខ្ញុំគ្មានដឹងលម្អិតអីទេ គ្រាន់តែឮគាត់និយាយប្រាប់ថា តាវ៉ាញ ដែលគេចាប់ទៅហ្នឹង គឺមូលហេតុត្រង់ថា បំពាក់អាវុធខុសច្បាប់ឲ្យកងចលាចល អ៊ីចឹងចំណុចហ្នឹងគឺជាចំណុច

សំខាន់។ ខ្ញុំដឹងតែប៉ុណ្ណឹង អត់មាននិយាយអីវែងឆ្ងាយទេ។

**ស៖** បាទ មិនជាថ្មីនោះទេ។ ត្រង់ចំណុចដដែលនេះ ខ្ញុំសូមឱ្យលោកមើលចម្លើយដែលលោកបានឆ្លើយប្រាប់អ្នកស៊ើបអង្កេតរបស់ខាងមជ្ឈមណ្ឌលឯកសារកម្ពុជា ឯកសារ E3/10666, អង់គ្លេស ERN គឺ 01330580, ខ្មែរ <01326355> គឺពាក់ព័ន្ធទៅនឹងកងពលធំដែលរៀបចំកងកម្លាំងវាយបក។ អ្វីដែលលោកនិយាយនោះ គឺលោកជាអ្នកឆ្លើយនៅពេលសម្ភាសនោះ។ "ក្រោយរំដោះឆ្នាំ៧៥ នយោបាយវាមានលក្ខណៈរំជើបរំជួល ខ្ញុំអន់ចិត្ត គ្មានអ្វីដែលខ្ញុំ -- យើងអាចធ្វើបាននោះទេ។ តាមដែលខ្ញុំដឹងកងពលខ្លះបានរៀបចំកម្លាំងវាយបកវិញ ក៏ប៉ុន្តែមិនអាចធ្វើទៅរួច។" តើលោកចង់បានន័យយ៉ាងម៉េចនៅពេលដែលលោកនិយាយថា នយោបាយនេះមានភាពច្របូកច្របល់?

**ឆ៖** បាទ កន្លែងហ្នឹង គឺខ្ញុំចង់និយាយថា នយោបាយមានការច្របូកច្របល់ ឬក៏ការប្រែប្រួល។ ពេលហ្នឹង ខ្ញុំបានដឹងខ្លះអំពីថ្នាក់ដឹកនាំកំពូលៗ ដូចជាថ្នាក់ភូមិភាគ ជាពិសេស តាកឹ ហៅ តាកន នេះ គាត់មកប្រាប់ខ្ញុំថា ឱ្យប្រយ័ត្នប្រយែងខ្លួន ព្រោះទឹកដីមិនស្រួលទេ នយោបាយប្រែប្រួលហើយ ត្រូវការពារខ្លួនឱ្យមែនទែន។ នេះជាចំណុច ត្រង់ហ្នឹងហើយដែលខ្ញុំឃើញថា សកម្មភាពអ្វីដែលកើតឡើងហ្នឹងវាសុទ្ធតែមានហេតុរបស់វាបាទ។

[១៥:២២:១៧]

**ស៖** តើ តាកឹ មាននិយាយប្រាប់លោកអំពីកងពលធំរៀបចំកងកម្លាំងដើម្បីវាយបក ប៉ុល ពត ដែរឬទេ?

**ឆ៖** បាទ អត់ទេ គាត់គ្រាន់តែមកប្រាប់ខ្ញុំថា ឱ្យខ្ញុំប្រុងប្រៀបប្រយ័ត្នប្រយែងខ្លួន ការពារខ្លួន ព្រោះនយោបាយប្រែប្រួលហើយ សភាពការណ៍មិនស្រួលទេសព្វថ្ងៃនេះ ឃើញស្រាប់ហើយបន្តិចចាប់អ្នកនេះ បន្តិចចាប់អ្នកនោះ។ គាត់ប្រាប់ខ្ញុំអ៊ីចឹង។ អត់មានដឹងអី ក្រៅពីហ្នឹងទៀតអត់ទេ។

**ស៖** នៅលើទំព័រដដែល ប៉ុន្តែខាងក្រោមបន្តិចលោកនិយាយថា "ខ្ញុំមិនដឹងថា តើផែនការហ្នឹងលេចចេញមកពីណានោះទេ។" ហើយលោកថា "ដំបូងប្រហែលជាផែនការហ្នឹងវាចំហជាសាធារណៈខាងពាយ័ព្យចាប់ពាយ័ព្យ។" តើលោកចង់បានន័យថាយ៉ាងម៉េចដែរ នៅពេលដែលលោកឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាយ៉ាងដូច្នេះ?

**ឆ៖** អង្គាល់ហ្នឹង ខ្ញុំធ្លាប់ឃើញថា អង្គាល់ហ្នឹងអត់ទាន់មាននិរតីអីចុះទៅគគ្រឹកគគ្រេងទេ។ បាទ គ្រាន់តែទៅធម្មតាៗអ៊ីចឹងទៅ ក្នុងក្រសួងមន្ទីរធំៗមួយចំនួន តែពេលនុ៎ង គឺមានពាយ័ព្យចាប់ពាយ័

01385979



ព្យ ដោយសារពីកងពល -- កងតូច កងធំអ៊ីចឹង ករណីពីនេះ ពីនោះអីវាចេះតែកើតមានអ៊ីចឹងទៅ។ ហើយដល់ក្រោយមក ស្រាប់តែផុតពីពាយ័ព្យចាប់ពាយ័ព្យ និរតីចាប់ពាយ័ព្យវិញ បន្តបន្ទាប់អ៊ីចឹង។

[១៥:២៤:៣១]

**ស៖** ខ្ញុំយល់។ នៅក្នុងចម្លើយរបស់លោកឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា លោកឆ្លើយថា "តាមលោកដឹង កងពលខ្លះរៀបចំកម្លាំងដើម្បីវាយបក។" តើព័ត៌មានហ្នឹងលោកដឹងនៅពេលនុ៎ងតែម្តងមុនពេលដែលខាងនិរតីទៅដល់ពាយ័ព្យ មែនដែរឬទេ?

**ឆ៖** ក្រោយពេលដែលនិរតីទៅដល់ពាយ័ព្យ បាទ ដែលគេចាប់ខ្លួនអស់ហើយ ចាប់ខ្លួនថ្នាក់ដឹកនាំកំពូលអស់ហើយ ថ្នាក់ភូមិភាគ ថ្នាក់តំបន់ ថ្នាក់អី ស្រុកមួយចំនួន វរសេនាតូច វរសេនាធំអីហ្នឹង ចង់អស់ហើយ អាហ្នឹងខ្ញុំដឹង តាមក្រោយទេ ដឹងនៅ--

**ប្រធានអង្គជំនុំ៖**

ដូចអត់មានសំឡេងខ្មែរ ឈប់ៗបញ្ហា ភាសាខ្មែរអត់មាន។

**អ្នកបកប្រែ៖**

អាឡូ! ឮទេ លោកប្រធាន? អាឡូ!

**ប្រធានអង្គជំនុំ៖**

សូមលោកឆ្លើយបញ្ជាក់ឡើងវិញ ចម្លើយរបស់លោកអំមិញឆ្លើយតបនឹងមេធាវី សំណួរចុងក្រោយអំមិញ គឺឆ្លើយដោយអត់មានភាសាខ្មែរហ្នឹង គឺនៅក្នុងប្រព័ន្ធចែកចាយសំឡេងលោកមកដល់ទេ។

[១៥:២៥:៥៦]

**2-TCW-1037៖**

**ឆ៖** បាទ ខ្ញុំសូមឆ្លើយឡើងវិញ ថាកាលនោះ ដែលតាមខ្ញុំឮ ខ្ញុំដឹងហ្នឹង គឺដឹងក្រោយពេលដែលគេចាប់ថ្នាក់ដឹកនាំកំពូលៗ ថ្នាក់ភូមិភាគ ថ្នាក់តំបន់ ស្រុកអីហ្នឹង មួយចំនួនហ្នឹង កងពល កងវរសេនាតូច-ធំហ្នឹង អស់មួយចំនួនធំទៅហើយ បានដឹងតាមក្រោយទេ អត់មានដឹងមុន មុននឹងទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** ខ្ញុំយល់ តើលោកខ្លួននេះ បានដឹងថា នៅពេលនោះ មុនដែលនិរតីទៅហ្នឹង លោកខ្លួនឯងនេះ មានដឹងផ្ទាល់ទេ ថាកងពលហ្នឹងបានរៀបចំកម្លាំងវាយបក?

**ឆ៖** មិនដឹងទេ បាទ។

**ស៖** ខ្ញុំសូមសួរលើប្រធានបទដដែល ក៏ប៉ុន្តែវាពាក់ព័ន្ធនឹងដែរ ចំណុចហ្នឹងដែរ E3/4202, អង់គ្លេស ERN គឺ <00757532> ហើយខ្មែរគឺ 00858342, បារាំង 00849437។ <> សៀវភៅរបស់លោក ថេត សម្បត្តិ។ លោកសាក្សី តើ ចាន់ សារុត ដែលជា ធ្លាប់ជាប្រធានពេទ្យ<តំបន់>នៅខេត្តបាត់ដំបង តើលោកស្គាល់ទេ ចាន់ សារុត?

**ឆ៖** ខ្ញុំអត់ស្គាល់ ចាន់ សារុត ទេ។

[១៥:២៨:០៥]

**ស៖** ខ្ញុំសូមអាន<សម្រង់នេះ៖ "ចាន់ សារុត> ជាប្រធានពេទ្យនៅតំបន់បាត់ដំបង បានឆ្លើយនៅក្នុងកិច្ចសម្ភាសន៍ថា នៅក្នុងកិច្ចប្រជុំមួយដែលលោកបានចូល -- គាត់បានចូលរួមនៅភូមិស្តៅ <ដើម្បីផ្តួលរំលំ> ប៉ុល ពត ហើយ<> រស់ ញឹម បាន<និយាយ>ថា <ការសម្លាត់គឺជាការចាំបាច់ពីព្រោះ>អ្នកណាដែលរកឃើញថា ជាអ្នកចូលរួមក្នុងផែនការនោះ នឹងយកទៅសម្លាប់ចោល។" តើលោកសាក្សីធ្លាប់ឮដែរឬទេ ធ្លាប់ឮផែនការដើម្បីផ្តួល ប៉ុល ពត <ទេ> ហើយនៅពេលនោះ រស់ ញឹម បាននិយាយនៅក្នុងប្រជុំ<>ថា <លេខាបានប្រគល់អំណាច?>

**ឆ៖** ខ្ញុំអត់ដែលឮទេ។

**ស៖** តើលោកធ្លាប់ឮ រស់ ញឹម បញ្ជាឲ្យ<សមាជិក>កងពលលេខ១ <ឬ>លេខ២ ប្រមូលលាក់អង្ករ អង្រឹង និងអាវុធ ត្រី ទុកដើម្បីផ្គត់ផ្គង់ និងជួយទៅដល់ខាងកងទ័ព ដែលបះបោរប្រឆាំងនឹងមជ្ឈិមដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលឮ អត់ដែលឃើញទេ។

[១៥:២៩:៥០]

**ស៖** តើលោកធ្លាប់ឮ <ថាកងទ័ពកងពលនៃភូមិភាគ>ពាយ័ព្យ <>លាក់ថ្នាំ<ពេទ្យ>ទុកនៅក្នុងឃ្លាំងដែរឬទេ?

**ឆ៖** ចំណុចហ្នឹង ខ្ញុំមិនឮទេ ក៏ប៉ុន្តែចំណុចមួយ ខ្ញុំគ្រាន់តែថា មានគេចោទថា លាក់ប្រេង យកប្រេងទៅចាក់អីចោលក្នុងទន្លេក្នុងអី អាហ្នឹងខ្ញុំធ្លាប់ឮ។

**ស៖** លោកបាននិយាយអំពីគេចោទ។ តើលោកបានធ្លាប់ដឹងព័ត៌មានដោយផ្ទាល់ខ្លួនឯងអំពី<សមាជិក>កងពល<លេខ១ ឬលេខ២>ដែលជាអ្នកចូលរួមនៅក្នុងផែនការហ្នឹង<ទេ>? តើលោកធ្លាប់បានទទួលព័ត៌មានដោយផ្ទាល់ខ្លួនឯងទេ?

**ផ៖** បាទ អត់ទេ ព្រោះខ្ញុំរស់នៅដាច់ដោយឡែក ឆ្ងាយពីគ្នា។

**ស៖** ខ្ញុំសូមប្រាប់លោក ហេតុអ្វីបានជាខ្ញុំភ្ញាក់ផ្អើលនៅពេលដែលខ្ញុំឮលោកដូច្នេះ។ លោកប្រធាន ខ្ញុំយោងលើឯកសារ E3/1358 គឺព័ត៌មាននេះមកពី<របាយការណ៍ហ្វែសបីស> អង់គ្លេស ERN 00168287។ វា<គឺជាការផ្តល់ព័ត៌មានពីមន្ត្រីយោធាជាន់ខ្ពស់ម្នាក់> មកពីខាងប្រទេសថៃបានប្រាប់ទៅខាងសារព័ត៌មានអន្តរជាតិ គឺភ្នាក់ងារ<សារព័ត៌មានបារាំង គឺ> អា.អេហ្វ.ប៉េ <ថ្ងៃទី១៩> ខែសីហា ឆ្នាំ៧៧ ដែលក្នុងនោះបានពិពណ៌នារាយការណ៍ថា "វរជនខាងយោធា<ថៃ បាននិយាយនៅថ្ងៃសុក្រ ថាមេដឹកនាំកម្ពុជាបានបង្ក្រាបការប៉ុនប៉ងធ្វើ>រដ្ឋប្រហារនៅក្នុងខែកុម្ភៈឆ្នាំនេះ។ ឧត្តមសេនីយ៍គ្រីយ៉ាំងសាក់ <ចាម៉ាណាន> ជាអគ្គសេនាធិការរងបានលើកឡើងថា អង្គការ<បដិវត្តន៍កម្ពុជា អង្គ-ការ>បានវាយ<កម្ទេច>ផែនការក្បត់ដែល<រៀប>ចំ<ឡើង>ថ្ងៃរំឭកខួបលើកទី២ នៃការគម្រប់ជ័យជម្នះរបស់ខ្មែរក្រហម<ថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៦៥" នៅក្នុងនេះនិយាយថា ៦៥ ប៉ុន្តែការពិតគឺ៧៥ទេ។> ដែលក្នុងនោះបានដកស្រង់នូវចារកម្មថៃលើកឡើងថា "<មេដឹកនាំកម្ពុជា>បានវាយផ្តួលខាងអ្នកដែលរៀបចំផែនការ រួមទាំងកម្ទេចទៅលើគ្រួសាររបស់ក្រុមទាំងអស់នោះផងដែរ។" <មានរបាយ-ការណ៍ផ្សេងៗទៀត ដែលបានបញ្ជាក់នៅក្នុងសៀវភៅរបស់ ឃៀរនិន> ដូច្នេះហើយនៅក្នុងឆ្នាំ៧៧នេះព័ត៌មានហ្នឹងគឺល្បីល្បាញណាស់ដែលថា នៅខាងពាយ័ព្យមានរៀបចំផែនការរដ្ឋប្រហារ<ដែលគ្រោងនឹងកើតឡើង>នៅថ្ងៃ១៧ មេសា ឆ្នាំ១៩៧៧ <ហើយត្រូវបានគេកម្ទេចចោល>។ តើលោក<យល់ពីការភ្ញាក់ផ្អើលរបស់ខ្ញុំ>ទេ?

[១៥:៣៣:២៨]

**លោក ចូសេហ្វ អេនទ្រូ ប៊ិយលើ៖**

ខ្ញុំជំទាស់ ៗទៅនឹងសំណួរ។ មេធាវីមកឆ្លើយខ្លួនឯងលើភស្តុតាង។ ប្រសិនបើចង់អានចំណុចដកស្រង់ ហើយសួរសំណួរជាក់លាក់នោះ មិនបញ្ហានោះទេ។ <បើគាត់មានសំណួរជាក់លាក់មកពី ឃៀរនិន ហើយគាត់ចង់សួរ គឺមិនអីទេ> ក៏ប៉ុន្តែ<ការ>ផ្តល់សក្ខី<ថាជាអ្វីដែល>ល្បីល្បាញ <ឬជាអ្វីដែលភស្តុតាងបង្ហាញនោះ ហើយសួរអំពីថាហេតុអ្វីបានជា>ភ្ញាក់ផ្អើល<នោះ វាមិនមែនជាព័ត៌មាន> ដែល<>សាក្សី<អាច>ឆ្លើយនោះទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនយល់ច្បាស់ ហេតុអ្វីខ្ញុំមិនអាចសួរសំណួរបែបហ្នឹងបាន?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

មេធាវី លោកមិនអាចសួរដូច្នេះបាននោះទេ។ លោកបានចង់សួរទៅសាក្សីថា តើយល់យ៉ាងម៉េច ដែលនៅពេលដែលលោកនិយាយថា លោកមានការភ្ញាក់ផ្អើល ហើយលោកអានចំណុចដកស្រង់<ពីរបាយការណ៍ចារកម្មនោះ>។ <នេះមិនមែនជាសំណួរអង្គហេតុទេ។ យកអង្គហេតុមកសួរមក។ ដូចព្រះរាជអាជ្ញាបាននិយាយ>អ៊ីចឹងគឺប្រសិនបើលោកចង់សួរ ដកស្រង់ចំណុចឲ្យបានជាក់លាក់ ហើយសួរសំណួរជាក់លាក់តែម្តង។ ប្រសិនបើសួរសាក្សីថា តើគាត់យល់យ៉ាងម៉េច ហើយគាត់ប្រតិកម្មយ៉ាងម៉េចទៅលើការភ្ញាក់ផ្អើលរបស់លោកនោះ មិនសមរម្យនោះទេ។

[១៥:៣៤:៤៨]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំមិនច្បាស់ថា តើខ្ញុំ<យល់នូវអ្វីដែលលោកស្រីចៅក្រម>និយាយ<>នោះទេ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ខ្ញុំបានលើកឡើងព័ត៌មានអន្តរជាតិ ដែលឧត្តមសេនីយ៍<យោធាថៃ>ម្នាក់គាត់អត្ថាធិប្បាយ ហើយអត្ថាធិប្បាយទៅដល់ពិភពលោកថា មានផែនការមួយប៉ងចង់រដ្ឋប្រហារ ធ្វើឡើងនៅថ្ងៃទី១៧ មេសា ឆ្នាំ៧៧។ តើលោកក្នុងពេលដែលលោកនៅពាយ័ព្យ ជាសមាជិកកងពលលេខ២នោះ ធ្លាប់មានដែលឮផែនការហ្នឹងដែរឬទេ?

**2-TCW-1037៖**

**ឆ៖** បាទ កាលឆ្នាំហ្នឹងខ្ញុំអត់ដែលឮទេ។ គ្រាប់តែក្រោយមកដែលកងទ័ពត្រូវបាក់បែក ខ្ចាត់ខ្ចាយ ចាប់ខ្លួនអស់ច្រើនហើយ បានខ្ញុំឮតាមរយៈកម្លាំងយោធាមួយចំនួនដែលនៅតាមសហករណ៍ នៅតាមតំបន់ខ្លះ គេនិយាយៗដូចដែលបានលើកឡើងខ្លះៗដែរ វាចូលនឹងសាច់រឿងថាប្រុងវ៉ៃបកវ៉ៃអីហ្នឹង។

**ស៖** ឥឡូវនេះ ខ្ញុំសូមអាននូវ<ឃ្លាទី១ នៃ>កថាខណ្ឌបន្ទាប់ឲ្យលោកស្តាប់បន្តទៀត ហើយខ្ញុំសូមបញ្ជាក់ថានេះគឺជាអ្វីដែលឧត្តមសេនីយ៍<នោះ>បាននិយាយនៅក្នុងខែ<សីហា> ៧៧ គឺថា៖ "<ការបះបោរត្រូវបានប្រមូលផ្តុំ>ទាំងរដ្ឋបាល <និងទាំងមេដឹកនាំ>យោធា<លាតសន្ធឹងមួយប៉ែកធំឆ្ពោះមក>ខាងពាយ័ព្យពីខាងខេត្តកំពង់ចាម រួមបញ្ចូលទាំង<ខេត្ត>កំពង់ធំ សៀមរាប ហើយនិងឧត្តរមានជ័យ។" ជន -- ខ្ញុំសូមបន្ត "ជនភៀសខ្លួនមកពីតំបន់ទាំងអស់នេះបានចូលទៅក្នុងប្រទេសថៃ <គឺចេញមកពីជម្លោះនៅក្នុងជួរ>ខ្មែរក្រហម។" សូមបញ្ចប់ការដកស្រង់។ លោកសាក្សី <មនុស្ស>ដូចជា

តាក្តែង, រស់ ញឹម, តាខៀវ ជាដើម គាត់ត្រូវបានគេចាប់ខ្លួនប្រហែលជា ៨ខែក្រោយមក។ តើលោកដឹងទេ តើលោកដឹងអំពីហេតុការណ៍នេះមុនពេលដែល រស់ ញឹម ចាប់ខ្លួនដែរឬទេ? ខ្ញុំចង់សួរអ៊ីចេះ តើមុនពេលដែល រស់ ញឹម ត្រូវបានគេចាប់ខ្លួន តើលោកដឹងអំពីអ្វីខ្លះទាក់ទងទៅនឹងគម្រោងធ្វើរដ្ឋប្រហារ ឬក៏គម្រោងវាយប្រហារផ្នែកយោធានេះ?

[១៥:៣៧:៣៧]

**ឆ៖** បាទ កាលហ្នឹងខ្ញុំមិនៗដឹងទេ ព្រោះខ្ញុំនៅទន្លេ ខ្ញុំនៅគ្រប់គ្រងកម្លាំងនេសាទប្រហែលជា បី៣០០នាក់ជាង ៤០០នាក់នោះ គឺអត់បានដឹងពីសភាពការណ៍ម៉េចៗទេ ព្រោះក្នុងនោះ គឺកាលហ្នឹងពួកខ្ញុំហ្នឹងក៏ក្រោមការស៊ើបអង្កេតរបស់គិញបង្កប់របស់ថ្នាក់លើដែរ។ អ៊ីចឹងខ្ញុំមិនៗបានទទួលព័ត៌មានហ្នឹងទេ។

**ស៖** មិនអីទេលោកសាក្សី។ ឥឡូវនេះខ្ញុំសូមសួរបន្តទៅទៀត។ លោកប្រធានខ្ញុំសូមអនុញ្ញាតបង្ហាញរូបថតមួយ គឺខ្ញុំបានធ្វើ<សារអេឡិចត្រូនិច>មុននេះបន្តិចទៅមន្ត្រីច្បាប់។ ហើយខ្ញុំសូមអនុញ្ញាតពីលោកប្រធានដើម្បីដាក់បង្ហាញនៅលើអេក្រង់ គឺបង្ហាញអំពីរូបថត E3/3481, ERN មានលេខ P00440815 គឺមានរូបថតមនុស្សបីនាក់ សូមលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត ហើយផ្នែកខាងសោតទស្សន៍ចាក់ផ្សាយរូបថតនោះនៅលើអេក្រង់ទូរទស្សន៍ផង។

[១៥:៣៩:៣០]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើលោកស្គាល់រូបមនុស្សនៅខាងស្តាំដៃនេះទេ?

**2-TCW-1037៖**

**ឆ៖** មិនស្គាល់ទេ។

**ស៖** តើលោកធ្លាប់ឮសមាជិកគណៈមជ្ឈិម <ឬសមាជិកគណៈអចិន្ត្រៃយ៍>ឈ្មោះ វន វ៉េត ទេ?

**ឆ៖** បាទ អត់ឮផង។ ខ្ញុំទៅដឹងណាដល់គណៈមជ្ឈិម។

**ស៖** អ៊ីចឹងមានន័យថា លោកក៏មិនដែលឮអំពី វន វ៉េត ចូលរួមក្នុងការប្រជុំ គឺក្នុងការប្រជុំដែល

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

តាញឹម បញ្ជាឲ្យមេបញ្ជាការរបស់គាត់ហ្នឹងធ្វើការបះបោរប្រឆាំងដែរ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំអត់ដែលបានចូលប្រជុំទេ។

**ស៖** តើលោកធ្លាប់ឮឈ្មោះ សោ ភឹម ទេ?

**ឆ៖** ចំពោះ សោ ភឹម ខ្ញុំឮឈ្មោះ តែខ្ញុំស្រពេចស្រពិល វាដូច កាលហ្នឹងដូចឃើញម្ដងទៅជិះៗ អូប័រពីផ្សារលើទៅទន្លេសាបឃើញទៅជាមួយ តាញឹម មុនពេលដែលគេចាប់ខ្លួន តាញឹមហ្នឹង។ បាទ ឃើញចូលទៅធ្វើទស្សនកិច្ចនៅតាមដងទន្លេសាប។

[១៥:៤១:១៨]

**ស៖** តើលោកធ្លាប់ឃើញ តាញឹម ហើយនិង សោ ភឹម នៅជាមួយគ្នាទេ?

**ឆ៖** កាលហ្នឹងអត់ដឹងថា គាត់ទៅរយៈពេលប៉ុន្មានថ្ងៃ គ្រាន់តែឃើញគាត់ជិះកាណូតទៅជាមួយគ្នាហ្នឹងឃើញដើរធ្វើការអីចុះទៅទន្លេហ្នឹង ព្រោះអង្គាល់ហ្នឹងខ្ញុំនៅខាងទន្លេសាបហ្នឹង។

**ស៖** តើលោកដឹងទេ ហេតុអ្វីបានជាពួកគាត់ធ្វើដំណើរជាមួយគ្នា?

**ឆ៖** មិនដឹងដែរ កាលនុ៎ងគ្រាន់តែខាងក្រសួងភូមិភាគហ្នឹង សេនាធិការហ្នឹង គាត់គ្រាន់តែឲ្យព័ត៌មានមកថា ឲ្យរៀបចំទូកកាណូតអីហ្នឹងឲ្យមានរបៀបរបបចង មានរបៀបអែបៗតាមច្រាំង ព្រោះថ្នាក់លើបានចុះទៅធ្វើទស្សនកិច្ចនៅតាមដងទន្លេហ្នឹង តាមដងស្ទឹង តាំងពីបាត់ដំបងហ្នឹងទៅ។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** នៅក្នុងសំណួរចម្លើយ <A6> របស់លោកគឺ <E3/9850> គឺលោកនិយាយថា "តាញឹម <ត្រូវបានចាប់ខ្លួននៅពេលដំណាលគ្នានឹងលេខាភូមិភាគបូព៌ា> សោ ភឹម"។ តើលោកធ្វើយ៉ាងណាដឹងអំពីចំណុចទាំងអស់នេះ?

**ឆ៖** ខ្ញុំដឹងអង្គាល់នុ៎ង ខ្ញុំដឹងឃើញគាត់ដើរធ្វើការជាមួយគ្នាហ្នឹងរយៈពេលមួយថ្ងៃពីរថ្ងៃហ្នឹង តែរយៈពេលយូរប៉ុន្មានតទៀតគឺអត់ដឹងទេ ឃើញមុខម្ដងហ្នឹង ផុតពីហ្នឹងមកក៏បាត់ៗ សោ ភឹម ទៅ ហើយក្រោយមកយូរដែរ ក៏ៗឮថាគេចាប់ខ្លួន តាញឹម ទៀត។ អ៊ីចឹងរឿងអ្វីឲ្យជ្រៅជាងហ្នឹង គឺខ្ញុំមិនដឹងដែរ។

[១៥:៤៣:៣៦]

**ស៖** ខ្ញុំយល់។ ឥឡូវនេះ ខ្ញុំចង់សួរលោកអំពីមនុស្សម្នាក់ដែលយើងពិភាក្សាគ្នាមុនពេលឈប់សម្រាក។ ខ្ញុំបានបង្ហាញរូបថតឲ្យលោកមើលនៅលើអេក្រង់។ ខ្ញុំមិនប្រាកដថា លោកចាំរូបថតនោះ ឬ

ក៏អត់ ប្រហែលជាមេធាវីប្រឹក្សាអាចជួយបង្ហាញរូបថតឲ្យលោកមើលម្តងទៀតបាន។ លោកសាក្សីនៅក្នុង<ចម្លើយរបស់លោកជាមួយ>មជ្ឈមណ្ឌលឯកសារកម្ពុជា គឺ<E3/10666> អង់គ្លេសមានលេខ 01330510, ខ្មែរមានលេខ 01326309 គឺលោកបាននិយាយអំពី តា<ទាត់> គឺគេសួរថា "តើមេបញ្ជាការដែលគ្រប់គ្រងភ្នំវាយចាបឈ្មោះអី? លោកឆ្លើយថា តា<ទាត់>។" តើ តា<ទាត់> ដែលលោកនិយាយនៅក្នុងឯកសារមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹងដូចគ្នានឹង<>រូបថតហ្នឹងដែរអត់ទេ?

**ឆ៖** តាទាត់? តាទួត?

**ស៖** សូមទោសប្រហែលជា តាទាត់។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ជាការល្អ ប្រសិនបើសហការីខ្មែរ គាត់អានឈ្មោះនេះ។

[១៥:៤៥:០៧]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** គឺ តាទាត់។ ខ្ញុំគិតថាដោយសារតែខ្ញុំមានពេលវេលាតិច ខ្ញុំសួរអ៊ីចឹងចេះវិញ។ លោកបាននិយាយអំពីមនុស្សម្នាក់ដែលគ្រប់គ្រងនៅភ្នំវាយចាបគឺ តាទាត់។ ដូច្នេះខ្ញុំចង់សួរថា តាទាត់ ជាអ្នកដែលមើលភ្នំវាយចាបហ្នឹង គឺដូចគ្នានឹងមនុស្សម្នាក់នៅក្នុងរូបថតនោះទេ?

**2-TCW-1037៖**

**ឆ៖** តាទាត់ ហ្នឹងគឺត្រូវជាឪពុករបស់ ទាត់ ធឿត ហ្នឹង បាទ ព្រោះនេះខ្ញុំសង្ស័យថា ទាត់ ធឿត ហ្នឹងដែរ ប៉ុន្តែកាលហ្នឹងគាត់ កាលដែលមុនដែលខូចនេះ រាងដូចចាស់ជាងនេះ ឥឡូវហ្នឹងមើលដូចក្មេង ហើយរាងជ្រះជាងមុន។

**ស៖** ឥឡូវនេះ យើងកុំនិយាយអំពីឈ្មោះវិញ ឥឡូវយើងនិយាយអំពីអ្នកដែលគ្រប់គ្រងទៅលើភ្នំវាយចាប ការដ្ឋានភ្នំវាយចាប។ តើមនុស្សម្នាក់ហ្នឹងគឺជាមនុស្សតែមួយដូចនៅក្នុងរូបថតនោះមែនទេ?

**ឆ៖** តាទាត់ គាត់គ្រប់គ្រងកាលពីសម័យសង្គ្រាម ឆ្នាំ៧០ មក៧៣ បាទ គាត់ជាមូលដ្ឋានរបស់ខ្មែរក្រហមនៅកន្លែងហ្នឹង ការកកើតខ្មែរក្រហម កសាងកម្លាំងទ័ពអី គឺនៅភ្នំវាយចាបហ្នឹង។ គឺតាទាត់ហ្នឹង គាត់ជាអ្នកគ្រប់គ្រងនៅៗភ្នំហ្នឹង នៅកម្លាំងខ្មែរក្រហមដែលនៅលើហ្នឹង កាលពីសម័យហ្នឹង តែក្រោយមក គាត់អត់មានគ្រប់គ្រងអីទេ ព្រោះគាត់ខូចយូរហើយ។

[១៥:៤៧:២៨]

**ស៖** ឥឡូវនេះគឺថាខ្ញុំឈានដល់ចំណុចមួយដើម្បីបញ្ចាក់ជាកំណត់ត្រាប្រតិចារឹក។ គឺយើងមានមន្ទិលមួយចំនួនទាក់ទងទៅនឹងថាតើអ្នកដែលផ្ដល់សក្ខីកម្ម កាលពីខែមិថុនា <២០១៥> នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូលនោះជាអ្នកណា? ដោយសារផ្អែកទៅលើសក្ខីកម្ម<របស់សាក្សីរូបនេះនៅ>ថ្ងៃនេះ <ហើយនិងសាក្សីមុនហ្នឹង គឺ>ធ្វើឱ្យយើងមានមន្ទិលសង្ស័យ<ថា> មនុស្សដែលនៅក្នុងរូបថតនោះ គឺជា ទាត់ ឬក៏ <ហំ។> យ៉ាងណាក៏ដោយ ខ្ញុំសូមបន្តទៅផ្នែកចុងក្រោយនៃសំណួររបស់ខ្ញុំ។ លោកសាក្សីនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយរបស់ លោកៗបាននិយាយអំពីខ្មែរស តើខ្មែរសហ្នឹងជាអ្នកណាដែរ?

**ឆ៖** តាមខ្ញុំដឹងខ្មែរសហ្នឹង គេហៅថាពួកអ្នកដែលរត់ពីសហករណ៍ រើបម្រះពីអាដែងរបបបីឆ្នាំប្រាំបីខែហ្នឹង រត់ទៅបង្កើតកម្លាំង លួចកាំភ្លើង រួចលួចអីពីកន្លែងសហករណ៍ ពីកន្លែងអីណាមួយហ្នឹងទៅៗបង្កើតវ៉ៃបកមកលើអាដែងរបបហ្នឹងឯង របបពាឆ្នាំហ្នឹងឯង។ ជាពិសេសវ៉ៃមកលើអាដែងកម្លាំងនិរតីហ្នឹងហ្នង ដូចជាសត្រូវងាប់រស់ជាមួយគ្នាយ៉ាងម៉េច ព្រោះកាលហ្នឹងឱ្យតែចាប់បាននិរតីគឺអត់រស់ទេ គឺអារកទាំងរស់បណ្ដោយ អានេះតាមខ្ញុំដឹង។

**ស៖** ហើយអ្នកដែលលោកនិយាយថាខ្មែរសនោះ គឺមិនមែនជាកងពល១, ២ទេ<> មែនទេ?

[១៥:៤៩:៤០]

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរនោះ ព្រោះថាទី១ ខ្ញុំគិតថាវាជាសំណួរនាំមុខ ហើយទី២ គឺថាខ្ញុំមិនប្រាកដថា សាក្សីគាត់<ទើប>បានផ្ដល់សក្ខីកម្មបែបនេះ<រួចហើយ>។ ខ្ញុំគ្រាន់តែចង់ស្នើសុំឱ្យមេធាវីសួរសំណួរដែលមានលក្ខណៈបើកចំហជាងទាក់ទងទៅនឹង<ទាហានទាំងអស់នេះ>ដែលសាក្សីទើបតែនិយាយ<ថា គឺកើតចេញពីចលនា>ខ្មែរស។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំនឹងកែសំណួររបស់ខ្ញុំឡើងវិញ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី លោកស្ថិតនៅក្នុងកងពលលេខ២។ តើកងទ័ពដែលនៅក្នុងកងពល១ <ឬកងទ័ពនៃ>កងពល២នោះ ស្ថិតនៅក្នុងក្រុមខ្មែរសដែរឬទេ? តើពួកទាហានទាំងពីរកងពលហ្នឹងត្រូវបានគេចាត់ទុកថា ជាខ្មែរសដែរឬទេ? ឬមួយក៏គេហៅតែអ្នកដែលចាកចេញពីកងចល័តទេ ថាខ្មែរស?

**2-TCW-1037៖**

**ឆ៖** បាទ តាមខ្ញុំដឹង កាលនោះ គឺដែលខ្មែរស ដែលគេបង្កើតបន្តិចបន្តួចហ្នឹង មួយក្រុម គ្នាប្អូនដប់ ម្ភៃនាក់អីហ្នឹង គឺមិនមានច្រើនទេ មានតែប៉ុណ្ណឹង គឺវាចម្រុះចេញពីប្រជាពលរដ្ឋ ១៨ មេសា ផង ១៧ មេសាផង ខ្លះចេញពីជួរកងទ័ពហ្នឹងផង។ នេះតាមដែលខ្ញុំក្ដាប់បាន។

**ស៖** គឺថា សំណួរចុងក្រោយរបស់ខ្ញុំ លោកសាក្សី គឺជាសំណួរដែលសួរអំពីរចនាសម្ព័ន្ធរបស់កងពលលេខ១ និងលេខ២។ លោកបាននិយាយអំពីមេបញ្ជាការរបស់លោក ឈ្មោះ <ក្លែង> ហើយនិង <រ៉េន> ប៉ុន្តែខ្ញុំចាំថា លោកក៏បាននិយាយ<ថា លោកក៏ស្គាល់>មេបញ្ជាការកងពលធំលេខ១ ឈ្មោះ <ឈន ដែរ> តើអ៊ីចឹងមែនទេ?

[១៥:៥២:០៤]

**លោក លីវ សុវណ្ណា៖**

លោកប្រធានសុំអនុញ្ញាតអានជាភាសាខ្មែរ។ "កងពលលេខ១ គាត់ឈ្មោះ ឈនៗ។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** តើជាការត្រឹមត្រូវទេ ដែលលោកនិយាយថា លោកស្គាល់ឈ្មោះ ឈន នេះ?

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

ខ្ញុំចង់ឲ្យមានការបញ្ជាក់បន្ថែម។ <តើយើងអាចសុំយោងអំពី>តួនាទី<របស់គាត់>ជា<មេបញ្ជាការ>កងពលលេខ១ <បានដែរ ឬទេ?>

**លោក វ៉ិចទ័រ កូប៉េ៖**

គឺឯកសារ E3/1170 ខ្ញុំបាននិយាយរួចមកហើយ គឺនៅក្នុង<អង្គការលេខ>ដែលនិយាយអំពីឈ្មោះ ឈន។

**លោក ចូសេហ្វ អេនគ្រូ ប៊ិយលី៖**

ប៉ុន្តែនៅក្នុងហ្នឹង គឺជាសមាជិកទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

គឺជាសមាជិក<នៅក្នុងគណៈ>កងពល<លេខ១>។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី តើជាការត្រឹមត្រូវទេ ដែលថា លោកស្គាល់ឈ្មោះ ឈន នេះ?

[១៥:៥៣:០៤]

**2-TCW-1037៖**

**ឆ៖** បាទ ឈ្មោះ ឈន នេះគឺខ្ញុំស្គាល់ច្បាស់ណាស់។ គឺត្រឹមត្រូវឈ្មោះ ឈន អ៊ីចឹងមែន។ ហើយមិនដឹងថា តួនាទីគាត់មិនមែនជាប្រធានកងពលអីទេ គាត់កាលមុន គឺគាត់ជាប្រធានវរសេនាធំ ដល់ក្រោយមកមិនដឹងសេនាធិការចាត់តាំងឲ្យគាត់ទៅជាកងពលយ៉ាងម៉េច ក៏ខ្ញុំអត់ដឹងដែរ។

**ស៖** ខ្ញុំយល់។ តើឈ្មោះ ឈន នេះ មានឋានៈប្រហែលគ្នា ឬក៏ដូចគ្នានឹងឈ្មោះ រ៉េន មកពីកងពលធំលេខ ២ ទេ?

**ឆ៖** ក្រោមឈ្មោះ រ៉េន ទេ អត់មានស្មើនឹងឈ្មោះ រ៉េន ទេ។

**ស៖** ទាក់ទងទៅនឹងឋានានុក្រម ឬក៏ឋានន្តរសក្តិ តើ ឈន ហើយនិង រ៉េន មានឋានន្តរសក្តិយ៉ាងដូចម្តេចដែរ?

**ឆ៖** បាទ កាលហ្នឹង ដូចមិនដែលឮថា សក្តិប៉ុន្មានផង គ្រាន់តែថា ក្នុងឋានៈជាកងពល វរសេនាធំ វរសេនាតូចអីប៉ុណ្ណឹង អត់មានឮថា អ៊ូ! ស័ក្តិប៉ុណ្ណេះ ស័ក្តិប៉ុណ្ណោះដូចសព្វថ្ងៃអីអត់ទេ។

**ស៖** ប្រហែលជាខ្ញុំអានមិនត្រឹមត្រូវមើលទៅ ប៉ុន្តែលោកនិយាយថា រ៉េន ជាមេបញ្ជាការកងពលធំលេខ២ ជាមេបញ្ជាការរបស់លោក ប៉ុន្តែឥឡូវនេះ ខ្ញុំចង់សួរអ៊ីចេះ។ ទាក់ទងទៅនឹងឋានានុក្រមនៅក្នុងរចនាសម្ព័ន្ធយោធាវិញ តើ ឈន ហើយនិង រ៉េន ហ្នឹង តើគាត់មានឋានានុក្រម ឬក៏ឋានន្តរសក្តិអ្វីដែរ?

**ឆ៖** ឋានានុក្រមខាងយោធាទេ តែឋានៈគាត់ តួនាទីក្នុងអង្គភាពកងពល ឬក៏គាត់នៅក្នុងវរសេនាធំ អានេះអត់ចាំបាន -- អ៊ំនែ! អត់ដឹងច្បាស់។

[១៥:៥៥:៤៩]

**ស៖** ចំណុចចុងក្រោយរបស់ខ្ញុំ តើលោកធ្លាប់ឃើញ ឈន ហើយនិង រ៉េន នៅជាមួយគ្នាទេ? ឬក៏ថាធ្លាប់ឃើញ ឈន ហើយនិង រ៉េន <នៅក្នុងកងអនុសេនាធំរបស់> វ៉ាញ ដែរឬទេ?

**ឆ៖** និយាយរួមទៅមិនសូវបានជួបគ្នានឹង តាវ៉ាញ ទេ។ បើ តារ៉េន និង ឈន ហ្នឹងគាត់បានជួបគ្នាញឹកញាប់នៅក្នុងខេត្ត ឬក៏ពេលប្រជុំកងពលអីម្តងៗហ្នឹង គាត់ធ្លាប់ជួបគ្នារាល់លើក។

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះ អង្គជំនុំជម្រះផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី ហើយអង្គជំនុំជម្រះនឹងពន្យារពេលរហូតដល់ទៅម៉ោងបួននិងដប់នាទីទើបសម្រាកនៅរសៀលនេះ។

**លោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ចូសេហ្វ អេនឌ្រូ ប៊ិយលី៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំគឺជាតំណាងសហព្រះរាជអាជ្ញា ហើយខ្ញុំនិងសួរសំណួរខ្ញុំក្នុងនាមសហព្រះរាជអាជ្ញា នៅថ្ងៃនេះ ហើយនិងនៅថ្ងៃស្អែកព្រឹក។ តើលោកអាចប្រាប់តុលាការបានទេថា នៅពេលដែលលោកនៅក្មេងនោះ តើលោកធ្លាប់ឆ្លងកាត់ការសិក្សាដល់ថ្នាក់ណាដែរ?

**2-TCW-1037៖**

**ឆ៖** បាទ កាលនៅពីក្មេង ខ្ញុំមិនដែលបានសិក្សាឲ្យជ្រៅជ្រះទេ សូម្បីតែរៀនសូត្រ គឺរៀនសាលាវត្ត។ ចេញពីសាលាវត្តមកក៏រៀនសាលារាជការហ្នឹងបានរយៈពេលកន្លះឆ្នាំ ចូលថ្នាក់ទី៩ ហ្នឹងរៀនមិនចប់ផង ទើបតែបានប៉ុន្មានខែហ្នឹងក៏កើតទឹកដីប្រែប្រួល បែកបាក់ រតាត់រតាយរហូតទៅ រស់នៅក្នុងព្រៃរហូតដល់មកឆ្នាំ១៩៧៥ហ្នឹងបានមកឃើញស្រុក ឃើញភូមិម្តង ផុតពីហ្នឹងមកក៏រស់នៅតាមស្រុកតាមភូមិផ្សេងៗក្នុងខេត្តបាត់ដំបងហ្នឹង បាទ។

[១៥:៥៨:៤១]

**ស៖** តើពេលដែលលោកនៅក្មេងនុំង លោករៀនបានប៉ុន្មានឆ្នាំដែរ?

**ឆ៖** ខ្ញុំរៀនបានពីរឆ្នាំជាង ពីរឆ្នាំកន្លះ។

**ស៖** តើលោកឈប់រៀននៅពេលណាដែរ?

**ឆ៖** ខ្ញុំឈប់រៀននៅឆ្នាំ១៩៦៥។

**ស៖** មុននេះ លោកប្រាប់ថា លោកចូលខ្មែរក្រហមនៅឆ្នាំ៧០។ ដូច្នេះ ចន្លោះពីឆ្នាំ៦៥ ដល់៧០ ហ្នឹងលោកធ្វើអ្វីដែរ?

**ឆ៖** ពីឆ្នាំ៦៥ ដល់ឆ្នាំ៧០ ហ្នឹង ខ្ញុំនៅធ្វើស្រែ ធ្វើចម្ការនៅស្រុកកំណើត។

**ស៖** តើនៅពេលណាដែលលោកដឹង<ថា លោកបានក្លាយទៅជាសមាជិករបស់>ចលនាបដិវត្តន៍ខ្មែរក្រហម នៅក្នុងតំបន់របស់លោកនោះ?

**ឆ៖** ខ្ញុំដឹងចលនាអំពីបដិវត្តន៍ ធ្វើខ្មែរក្រហមនៅតំបន់ហ្នឹង គឺខ្ញុំដឹងពី១៩៦៨។

**ស៖** នៅពេលដែលលោកចូលរួមចលនានោះ តើលោកចូលរួម តើលោកចូលធ្វើជាទាហានដើម្បីវាយជាមួយកងកម្លាំងលន់ នល់ មែនទេ?

**ឆ៖** បាទ កាលនុ៎ង ខ្ញុំចូលក្នុងចលនាឆ្នាំខ្មែរក្រហមហ្នឹង គឺនៅឆ្នាំ១៩៧០ វ៉ៃទាហានលន់ នល់។

**ស៖** បើតាមខ្ញុំយល់ពីសក្ខីកម្មរបស់លោក គឺឆ្នាំ៧៣ លោកបានចាកចេញពីទាហាន ហើយចូលទៅខាងភស្តុភារ និងសេដ្ឋកិច្ច អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន។ ឆ្នាំ៧៣ ខ្ញុំឈប់ពីទាហានហើយ។

[១៦:០១:៣៥]

**ស៖** តើនៅពេលនុ៎ងឬ ដែលលោកចូលទៅខាងផ្នែកភស្តុភារសេដ្ឋកិច្ចដែលមានមូលដ្ឋាននៅភ្នំវាយចាបនោះ មែនទេ?

**ឆ៖** បាទ មិនមែនទេ។ គឺចូលទៅភ័ស្តុភារសេដ្ឋកិច្ចហ្នឹង គឺខ្ញុំមិនមែននៅវាយចាបទេ ព្រោះបានចេញពីវាយចាបហ្នឹង ច្រើនឆ្នាំហើយ។ ព្រោះនៅរស់នៅលើភ្នំវាយចាបហ្នឹង ខ្ញុំរស់នៅឆ្នាំ៧០ មកដល់ឆ្នាំ៧១។

**ស៖** អ៊ីចឹង តើនៅពេលដែលលោកចូលខាងសេដ្ឋកិច្ចហ្នឹង តើ<លោកមានមូលដ្ឋាននៅ>កន្លែងណាដែរ?

**ឆ៖** ចូលសេដ្ឋកិច្ចហ្នឹង ខ្ញុំចូលសេដ្ឋកិច្ចកងទ័ពភាគ នៅតំបន់២។

**ស៖** នៅពេលដែលលោកចូលផ្នែកសេដ្ឋកិច្ចហ្នឹង តើលោកមានតួនាទី ឬក៏មានឋានៈអ្វីដែរទេ? <តើលោកមានតួនាទក្នុងកងសេដ្ឋកិច្ចនោះទេ?>

**ឆ៖** ខ្ញុំមានឋានៈស្មើនឹងកងវរសេនាតូច ហើយមានតួនាទីដឹកនាំស្បៀងអាហារ ប្រដាប់អាវុធដឹកជញ្ជូនទៅឲ្យទ័ពដែលឈរជើងនៅខាងមុខ។

[១៦:០៣:៤៣]

**ស៖** តើលោកធ្លាប់ស្ថិតនៅក្នុង នៅក្រោមកងកម្លាំងរបស់ភូមិភាគដែរទេ នៅមុនឆ្នាំ៧៥?

**ឆ៖** មុនឆ្នាំ៧៥ ខ្ញុំស្ថិតនៅក្រោមកម្លាំងរបស់ភាគពាយ័ព្យ។

**ស៖** ឥឡូវនេះ ខ្ញុំសូមអាននូវសម្រង់ពីមជ្ឈមណ្ឌលឯកសារកម្ពុជារបស់លោក <ថាតើវាត្រូវគ្នានឹងអ្វីដែលលោកទើបតែប្រាប់យើងនេះដែរទេ> គឺ <E3/10666>, អង់គ្លេសមានលេខ 01330525 ដល់ 26, ខ្មែរមានលេខ 01326319 គឺថាគេសួរលោកថា “នៅក្នុងឆ្នាំ៧១ ដល់៧២ <តើ>គេដំឡើងលោកទៅតំបន់<>២<នៅ>? គឺលោកនិយាយថា <បាទ។ ហើយគេសួរបន្ត នៅឆ្នាំណាដែលគេដំឡើងលោកទៅជាកងទ័ពភូមិភាគ? លោកឆ្លើយថា> នៅឆ្នាំ៧៣ <ចុង៧២ ដើម>៧៣ ខ្ញុំទៅរស់នៅក្នុងភូមិភាគជាមួយនឹងកងទ័ពរបស់ភូមិភាគ”។ តើវាត្រឹមត្រូវទេ?

**ឆ៖** ខ្ញុំសុំឆ្លើយថា កាលដំបូងយើងបង្កើតទ័ពភាគ អត់ទាន់មានកងពល បាទ។ អ៊ីចឹងនៅក្នុងជួរអង្គភាពភាគហ្នឹងគឺវាមានភារកិច្ច មានការងារសេដ្ឋកិច្ច វាមានការដឹកជញ្ជូន មានការគ្រប់គ្រងភ័ស្តុភារស្បៀងសម្ភារៈអីទាំងអស់ហ្នឹង គឺខ្ញុំឈប់ពីទ័ពមក ឲ្យមកនៅខាងក្រោយហ្នឹង ខ្ញុំគ្រប់គ្រងផ្នែកខាងហ្នឹង គឺមាននៅក្នុងក្រោមការគ្រប់គ្រងរបស់ភាគដដែលទេ។

**ស៖** ឥឡូវនេះ យើងនិយាយអំពីក្រោយថ្ងៃ១៧ មេសា ៧៥ តើលោកមានតួនាទីអ្វីដែរ នៅពេលនោះ?

**ឆ៖** និយាយពីថ្ងៃក្រោយឆ្នាំ៧៥ ខ្ញុំមានតួនាទីជាសេដ្ឋកិច្ចដដែល បាទនៅធ្វើការងារខាងហ្នឹងដដែល ខាងគ្រប់គ្រង ខាងស្បៀងអាហារ និងឃ្លាំងគ្រប់រំសេវអីហ្នឹង ហើយនិងកម្លាំងនេសាទចុះទៅទន្លេសាបអីហ្នឹង។

[១៦:០៦:៤៣]

**ស៖** តើលោកមានតួនាទីជាអនុប្រធានផ្នែកសេដ្ឋកិច្ច<នៃកងពលលេខ២>ដែរឬទេ?<តើលោកត្រូវបាន>គេដំឡើងឋានៈ<ហ្នឹង>នៅឆ្នាំ៧៥?

**ឆ៖** បាទ ខ្ញុំជាអនុប្រធានខាងសេដ្ឋកិច្ចយោធា។

**ស៖** ចុះប្រធានសេដ្ឋកិច្ចយោធាដែលជាមេរបស់លោកហ្នឹងគឺ តា<ស៊ុម> មែនទេ គឺ តា<ស៊ុម> ដែលោកបាននិយាយមុនហ្នឹងមែនទេ?

**ឆ៖** បាទ មិនមែនឈ្មោះ សំ ទេឈ្មោះ ស៊ុម – ឈ្មោះ ស៊ុម។

**ស៖** សូមទោសដែលខ្ញុំអានឈ្មោះគាត់ខុស។ លោកបាននិយាយថា គេផ្ទេរលោកទៅខាងនេសាទវិញ។ ដូច្នេះខ្ញុំចង់សួរថា តើគេផ្ទេរលោកទៅខាងនេសាទនៅពេលណាដែរ?

**ឆ៖** ពេលនុំងគេផ្ទេរខ្ញុំទៅខាងនេសាទនៅឆ្នាំ១៩៧៦។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើលោកមានតួនាទីអ្វីដែរ នៅពេលដែលគេផ្ទេរលោកទៅខាងនេសាទហ្នឹង? តើលោកនៅរក្សាតួនាទីជាអនុប្រធានផ្នែកសេដ្ឋកិច្ចដដែល ឬមួយក៏យ៉ាងម៉េច?

**ឆ៖** បាទ កាលហ្នឹង គេរក្សាខ្ញុំជាអនុប្រធានដដែល។

**ស៖** តើលោកអាចប្រាប់តុលាការបានទេ ថាតើកងនេសាទហ្នឹងគេធ្វើការងារអ្វីខ្លះ?

**ឆ៖** តាមដែលខ្ញុំចាំ កងនេសាទកាលនោះគេធ្វើការងារគិតតែពីរឿងរកត្រី ធ្វើប្រហុក ធ្វើប្រឡាក់អីចឹងទៅ រកត្រីទាំងស្រស់ ទាំងគ្រាម ទាំងអីហ្នឹង បញ្ជូនផ្តល់ឲ្យកងពលលេខ១ និងលេខ២ហ្នឹងតែម្តង ហើយនិងតាមក្រសួងមន្ទីររបស់ភាគ។

[១៦:០៩:១៤]

**ស៖** អីចឹងត្រីដែលកងរបស់លោកចាប់ហ្នឹង គេទុកសម្រាប់តែទាហានទេ ឬមួយក៏គេបញ្ជូនទៅឲ្យប្រជាជនស៊ីវិល ឬក៏អ្នកដទៃនៅក្នុងភូមិភាគពាយ័ព្យដែរ?

**ឆ៖** អត់មានឲ្យស៊ីវិលទេ ឲ្យតែខាងផ្នែកទ័ព ខាងភូមិភាគ ព្រោះតំបន់គេមានកម្លាំងគេផ្សេង។ ហើយខាងស្រុក និងតំបន់ហ្នឹង គេមានកម្លាំងគេរកផ្សេង។ អីចឹងខាងភាគហ្នឹង គេរកសម្រាប់ផ្គត់ផ្គង់ខាងកម្លាំងកងពលរបស់ភាគ ហើយនិងក្រសួងមន្ទីររបស់ភាគហ្នឹង។

**ប្រធានអង្គជំនុំ៖**

អរគុណៗ បានហើយ។

បាទ ហើយមុននឹងផ្អាកសវនាការនៅរសៀលនេះ អង្គជំនុំជម្រះសូមជម្រាបជូនដល់ភាគីទាំងអស់បានជ្រាបថា អង្គជំនុំជម្រះបានចាត់ការលើសំណើសុំរបស់សហព្រះរាជអាជ្ញា ដែលបានធ្វើសំណើកាលពីវេលាម៉ោងមួយ និងសាមសិបនាទីរសៀលនេះ ដោយបានចាប់មន្ត្រីច្បាប់របស់ខ្លួន គឺកញ្ញា ម៉ាដាលេណា ធ្វើទំនាក់ទំនងជាមួយនឹងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ឲ្យគាត់សូមទៅអ្នកជំនាញ 2-TCW-98 ឲ្យយកឯកសារទាំងនោះមកជាមួយផងប្រសិនបើមាន នៅពេលដែលគាត់មកផ្តល់សក្ខីកម្មនៅទីនេះនៅរសៀលថ្ងៃស្អែក។ សូមភាគីជ្រាប។

បាទ សវនាការនៅថ្ងៃនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី១៨ ខែតុលា ឆ្នាំ ២០១៦ ដែលនឹងចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការបន្តសក្ខីកម្មសាក្សី 2-TCW-1037 បញ្ចប់ ហើយនិងផ្តើមស្តាប់សក្ខីកម្មអ្នកជំនាញដែលមាន

របស្សនាម 2-TCW-98 សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោកសាក្សី សវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សី នៅមិនទាន់ចប់នៅឡើយទេអង្គជំនុំជម្រះកោះអញ្ជើញលោកឲ្យមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ហើយអង្គជំនុំជម្រះក៏សូមអរគុណលោក មឿន សុវណ្ណ មេធាវីប្រឹក្សាសាក្សី អង្គជំនុំជម្រះកោះអញ្ជើញលោកមកបន្តប្រឹក្សាសាក្សីរូបនេះនៅថ្ងៃស្អែកទៀតដែរ។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីនេះវិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញនៅថ្ងៃស្អែក។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែកឲ្យមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:១២នាទី)*